UNDP

*Empowered lives.*
*Resilient nations.*

# កិច្ចគាំពារសង្គមដើម្បីបញ្ចប់ភាពទីទាល់ក្រ នៅប្រទេសកម្ពុជា

## ការវិភាគសមតាទូទៅ អំពីផលប៉ះពាល់សេដ្ឋកិច្ច និងភាពទីទាល់ក្រ

ខែធ្នូ ឆ្នាំ២០១៧










# បុព្វកថា

**ដោយលោក នីក ប៊េរេសហ្វត (Nick Beresford) នាយក កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) ប្រចាំប្រទេសកម្ពុជា**

កម្ពុជា គឺជាប្រទេសមួយដែលឆ្លងកាត់ការផ្លាស់ប្តូរជាច្រើន និងជាប្រទេសដែលមានប្រាក់ចំណូលមធ្យមថ្មីថ្មោង ដែលមានប្រជាជនមានជីវភាពមធ្យមខ្វះបទពិសោធន៍ និងប្រាស្រ័យទៅលើសេដ្ឋកិច្ចដែលកំពុងរីកចម្រើនយ៉ាងគំហុក និងការផ្លាស់ប្តូរជាខ្លាំងដែលជម្រុញដោយដំណើរការគូនៃឧស្សាហូបនីយកម្មនិងនគរូបនីយកម្ម និងដោយទំនើបភាវូបនីយកម្មសង្គម។ នេះគឺជាពេលវេលានឱកាស ក៏ប៉ុន្តែវាក៏ជាដំណើរជ្រួលច្រាល់ មិនរៀបរយ និងងាយរងគ្រោះមួយផងដែរ។ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនេះនាំមកនូវហានិភ័យ រួមជាមួយឱកាស និងគំលាតនៅពេលអនាគត។ ប្រជាជនកម្ពុជាមួយភាគធំ គឺស្ថិតនៅពីលើខ្សែបន្ទាត់នៃភាពទីទាល់ក្រតែបន្តិចប៉ុណ្ណោះ រីឯសេវាកម្មសាធារណៈគឺមានភាពប្រឈមដើម្បីឆ្លើយតបនឹងកំណើននៃតម្រូវការ ចំណែកឯគំលាតផ្សេងគ្នានៃសេដ្ឋកិច្ចក៏អាចជម្រុញឱ្យមានវិសមភាពផងដែរ។

ខណៈពេលដែលការផ្លាស់ប្តូរជាវិជ្ជមានទាំងនេះមានភាពជឿនលឿន ជាមួយនឹងភាពប្រសើរឡើងនៃជីវភាពរស់នៅ និងការកាត់បន្ថយទីទាល់ក្រមួយផ្នែកធំនោះ ប្រជាជនកម្ពុជាភាគច្រើនក៏នៅតែរស់នៅក្នុងភាពទីទាល់ក្រនៅឡើយ។ ប្រជាជនមួយផ្នែកធំនៅក្នុងប្រទេស ទទួលបានប្រយោជន៍តិចតួចពីការពង្រីកសេដ្ឋកិច្ច និងការកែលម្អលើសេវាសាធារណៈទាំងនេះ។ ការគាំទ្រលើផ្នែកសមភាព ជីវភាពគ្រួសារ និងសហគមន៍ និងការការពារក្រៅប្រព័ន្ធ កំពុងស្ថិតនៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភ។

នៅក្នុងបរិបទនេះ កិច្ចគាំពារសង្គមដែលគាំទ្រដោយរដ្ឋដែលមានប្រសិទ្ធភាព និងប្រសិទ្ធផល គឺជាកំណែទម្រង់ដែលត្រូវបានរំពឹងទុកជាយូរមកហើយ។ ដំណើរផ្លាស់ប្តូរសង្គម និងសេវាកម្មគាំទ្រ គឺមានសារសំខាន់ណាស់ក្នុងការកាត់បន្ថយហានិភ័យ ការបង្កើននិងការទ្រទ្រង់ជីវភាពរស់នៅ ក៏ដូចជាការបំពេញភារកិច្ចលុបបំបាត់ភាពទីទាល់ក្រផងដែរ។ វាជាការលើកទឹកចិត្តមួយយ៉ាងសំខាន់ ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់នូវតម្រូវការទាំងនេះ និងសក្តានុពលនៃកិច្ចគាំពារសង្គម ដើម្បីផ្តល់នូវសេដ្ឋកិច្ចទំនើបកម្ម និងយុត្តិធម៌ និងបានកំណត់នូវរបៀបវារៈកំណែទម្រង់ដែលមហិច្ឆតាដ៏ធំនៅក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលបានចាប់ផ្តើមកាលពីដើមឆ្នាំនេះ។

ការផ្តោតការយកចិត្តទុកដាក់នាពេលនេះ គឺផ្តោតទៅលើការពិនិត្យអំពីរបៀបធ្វើយ៉ាងណាឱ្យរបៀបវារៈនេះដាក់ចេញជាការអនុវត្តជាក់ស្តែង។ របាយការណ៍ដែលផ្តល់ជូននេះ គឺបង្ហាញនូវការយល់ដឹងអំពីការប្រមូលផ្តុំនូវគំរូ និងគោលនយោបាយទាំងឡាយដោយផ្អែកលើគោលវិធីបញ្ចប់ភាពទីទាល់ក្រ ដែលមានគោលបំណងដោះស្រាយភាពទីទាល់ក្រ និងភាពងាយរងគ្រោះ ដោយផ្តល់នូវធនទ្រព្យដែលមានផលិតភាពជំនួសឱ្យការផ្តល់តែជាសាច់ប្រាក់ដល់គ្រួសារក្រីក្រ។ កិច្ចការទាំងនេះ មានបំណងដើម្បីទទួលបានផលចំណេញពីផលិតភាព ដែលជួយជនក្រីក្រឱ្យជួយខ្លួនឯង ដើម្បីធានានិរន្តភាពចាកផុតពីភាពទីទាល់ក្រ។ គោលវិធីបញ្ចប់ភាពទីទាល់ក្រ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅតាមបណ្តាប្រទេសដទៃទៀតដែលមានបរិបទប្រហាក់ប្រហែលគ្នា គឺបានបង្ហាញពីតម្លៃនៃគោលវិធីទាំងនោះ ជាពិសេសនៅក្នុងការកាត់បន្ថយភាពទីទាល់ក្រ និងការពង្រឹងជីវភាព ប៉ុន្តែចំណុចសំខាន់នោះ គឺការជម្រុញសេដ្ឋកិច្ចទាំងថ្នាក់តំបន់ និងថ្នាក់ជាតិ។ អ្នកស្រាវជ្រាវ ក៏បង្ហាញផងដែរថា ការប្រើបច្ចេកទេសគំរូមធ្យ័តក៏អាចជាគំរូសម្រាប់ប្រទេសកម្ពុជាផងដែរ។ ជាមួយនឹងភាពច្នៃប្រឌិត ពួកគេក៏បានរកឃើញថា តាមរយៈការសម្របសម្រួលកម្មវិធីទាំងនេះ បូកជាមួយនឹងការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធ និងវិធានការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានផ្សេងៗ ផលប្រយោជន៍អាចកើនឡើងច្រើនក្នុងសន្ទុះមួយដែលគួរឲ្យគត់សម្គាល់។

ខណៈដែលគោលវិធីបញ្ចប់ភាពទីទាល់ក្រ ត្រូវបានគេទទួលស្គាល់ថា ជាវិធីមួយក្នុងចំណោមការបង្កើតថ្មីជាច្រើន រួមទាំងវដ្ត នៃការផ្តល់សាច់ប្រាក់ដែលអាចត្រូវបានគេប្រើប្រាស់នៅពេលគម្រោងគោលនយោបាយជាតិគាំពារសង្គមត្រូវបានដាក់ចេញ គោល-វិធីបញ្ចប់ភាពទីទាល់ក្រគឺជាជម្រើសដ៏ជោគជ័យមួយសម្រាប់ដោះស្រាយភាពទីទាល់ក្រនិងភាពងាយរងគ្រោះរបស់ប្រជាជនដែលមានអាយុអាចធ្វើការបាន។ យូអិនឌីភី ប្រចាំនៅកម្ពុជា និងដៃគូអភិវឌ្ឍន៍ដទៃទៀត ក៏ប្រើប្រាស់គោលវិធីទាំងនេះ និងគោលវិធីផ្សេងៗទៀត ក្នុងការផ្តល់ប្រព័ន្ធគាំពារសង្គមទំនើប និងសមស្របសម្រាប់ប្រទេសកម្ពុជា។

**នីក ប៊ែរេសហ្វត**
នាយក យូអិនឌីភី ប្រចាំប្រទេសកម្ពុជា
ខែធ្នូ ឆ្នាំ២០១៧

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានបង្កើតឡើងដោយ យូអិនឌីភី ប្រចាំនៅកម្ពុជា សរសេរឡើងដោយអ្នកស្រីបណ្ឌិត Stephanie Levy មកពីសាលាសេដ្ឋកិច្ចទីក្រុងឡុងដ៍ (LSE) ហើយឯកសារនេះគឺជាការសិក្សាស្រាវជ្រាវរបស់អ្នកស្រី។

អ្នកស្រាវជ្រាវទទួលស្គាល់ថា ការសរសេរនិងការវិភាគនេះ គឺបានមកពីការចូលរួមចំណែក និងគាំទ្រជាខ្លាំងពីសំណាក់ Laurent Pipitone, Robin Burgess, Oriana Bandiera, Sherman Robinson និង Francesca Erdelmann ហើយនិង Sovannarith Hang, Marisa Foraci, Napoleon Navarro, Nick Beresford និង Richard Marshall (បុគ្គលិកនៃយូអិនឌីភីកម្ពុជា)។ អ្នកស្រីសូមថ្លែងអំណរគុណចំពោះ Nadim Ahmad និង Guannan Miao នៃអគ្គលេខាធិការដ្ឋានស្ថិតិរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) ដែលបានផ្តល់នូវទិន្នន័យ និងការគាំទ្រដ៏មានសារសំខាន់។

អ្នកស្រាវជ្រាវក៏សូមថ្លែងអំណរគុណផងដែរ ដល់មតិយោបល់ និងសំណើររបស់អ្នកចូលរួមក្នុងសិក្ខាសាលា និងបទបង្ហាញ ដែលបានធ្វើឡើងដោយ យូអិនឌីភី នៅរាជធានីភ្នំពេញ នាខែមីនា ឆ្នាំ២០១៧។



# អក្សរកាត់ដែលត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ

| | |
|---|---|
| CGE | គំរូគណនាសមតាទូទៅ |
| SAM | ម៉ាទ្រីសគណនេយ្យសង្គម |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (ហៅកាត់ថា យូអិនឌីភី) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| LSE | សាលាសេដ្ឋកិច្ចទីក្រុងឡុងដ៍ |
| CT/ CTs | ការឧបត្ថម្ភសាច់ប្រាក់ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| OECD | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| FFS | សាលាកសិករ |
| I/O | ធាតុចូល/ធាតុចេញ (តារាង) |
| DANIDA | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| TFP | កត្តាផលិតភាពសរុប |
| CPI | សន្ទស្សន៍តម្លៃទំនិញ |
| GDP | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) |

# មាតិកា

**បុព្វកថា** ..... ៣
**សេចក្តីថ្លែងអំណរគុណ** ..... ៥
**អក្សរកាត់ដែលត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ** ..... ៦
**ខ្លឹមសារសង្ខេប** ..... ៨
ភាពប្រឈម និង ឱកាស ..... ៨
គោលវិធីបញ្ចប់ភាពទីទាល់ក្រ ..... ៨
គោលវិធី និង វិធីសាស្ត្រវិភាគ ..... ៩
លទ្ធផល និង សារគោលនយោបាយ ..... ៩
**គោលបំណង** ..... ១១
**ផ្នែកទី១៖ បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រក្នុងបរិបទប្រទេសកម្ពុជា** ..... ១៣
បរិបទកិច្ចគាំពារសង្គមនៅកម្ពុជា ..... ១៣
កំណើនវិស័យកសិកម្មជាចលករមួយក្នុងការកាត់បន្ថយភាពទីទាល់ក្រ ..... ១៤
វិធីសាស្ត្របណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ..... ១៦
គំរូគណនាសមតាទូទៅ ..... ២០
**ផ្នែកទី២៖ ការរៀបចំគំរូបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រសម្រាប់គ្រួសារក្រីក្រខ្លាំងក្នុងប្រទេសកម្ពុជា** ..... ២០
ទិន្នន័យដែលត្រូវបានប្រើប្រាស់ក្នុងការសិក្សានេះ ..... ២១
ការផ្សារភ្ជាប់គ្រួសារទៅនឹងសេដ្ឋកិច្ច ក្នុងមូលដ្ឋានរបស់ពួកគេ៖ ភាពច្នៃប្រឌិតនៃការធ្វើសំណាក... ២៤
**ផ្នែកទី៣៖ លទ្ធផលនៃលំហាត់អនុវត្តតាមលើផលប៉ះពាល់ និងលទ្ធភាពបញ្ចប់ភាពទីទាល់ក្រ** ..... ២៦
សំណុំនៃលំហាត់អនុវត្តតាម ..... ២៦
លំហាត់អនុវត្តតាមខ្នាតតូច និងផលប៉ះពាល់មកលើភាពទីទាល់ក្រ ..... ៣០
លទ្ធផលពីលំហាត់អនុវត្តតាម ..... ៣០
ការពន្យល់អំពីប្រសិទ្ធភាពរយៈពេលវែងនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ..... ៣៧
គន្លឹះពិចារណាសំខាន់ៗ និងមធ្យោបាយសម្រាប់ការស្រាវជ្រាវបន្ត ..... ៤៤
**ផ្នែកទី៤៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍គោលនយោបាយ** ..... ៤៥
**គន្ថនិទ្ទេស** ..... ៤៨
**ឧបសម្ព័ន្ធ** ..... ៥០

# ខ្លឹមសារសង្ខេប

## ភាពប្រឈម និង ឱកាស

ប្រទេសកម្ពុជាបានជួបប្រទះការធ្លាក់ចុះយ៉ាងគំហុកក្នុងស្ថានភាពទីទាល់ក្រអស់រយៈពេលជាងពីរទសវត្សរ៍មកនេះ ហើយដែលភាគច្រើនគឺដោយសារតែការអភិវឌ្ឍជនបទប្រកបដោយនិរន្តភាពនៅក្នុងប្រទេស ដែលប្រជាជនក្រីក្រប្រហែល ៩០% រស់នៅទីជនបទ។ ក្នុងរយៈពេលនេះ វិស័យកសិកម្ម កម្ពុជា គឺជាកម្លាំងចលករដ៏សំខាន់មួយនៃកំណើនបរិយាប័ន្ន ហើយបានបង្ហាញពីសក្តានុពលសំខាន់បន្ថែមទៀត ដើម្បីជួយគ្រួសារជាច្រើននៅទីជនបទចេញពីភាពទីទាល់ក្រ។ វិស័យកសិកម្មមានការកើនរហ័សនៅក្នុងតំបន់ចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ ២០១២ ដោយមានអត្រាកំណើនជាមធ្យម ៩.៦% ក្នុងមួយឆ្នាំ។ ទោះបីជាយ៉ាងណា ដោយសារតែផលិតកម្មយឺតយ៉ាវ សំណួរជាច្រើនត្រូវបានលើកឡើងថា តើការធ្លាក់ចុះនៃនិន្នាការកំណើនសេដ្ឋកិច្ចនេះ អាចនឹងប៉ះពាល់ដល់ជីវភាពរបស់មនុស្សរាប់លាននាក់ ដែលនៅតែមានហានិភ័យខ្ពស់ចំពោះការប្រែប្រួលនៃប្រាក់ចំណូលរបស់ពួកគេឬយ៉ាងណា។

ការកាត់បន្ថយភាពទីទាល់ក្រនៅកម្ពុជាភាគច្រើន គឺដោយសារតែមានឱកាសថ្មីៗ សម្រាប់គ្រួសារក្រីក្រដែលមានប្រាក់ចំណូលជិតបន្ទាត់ភាពទីទាល់ក្រ។ ក្នុងករណីដែលភាពទីទាល់ក្រកាន់តែកើនឡើងធ្ងន់ធ្ងរ ការរីកចម្រើនសេដ្ឋកិច្ចកាន់តែទូលំទូលាយ ដែលមិនសូវបានជួយកែប្រែជីវភាពឱ្យប្រសើរឡើងនោះឡើយ។ ភាពទីទាល់ក្រនៅតែបន្តកើតមានមកដល់សព្វថ្ងៃនៅតាមតំបន់ដាច់ស្រយាល ដែលគ្រួសារទីទាល់ក្រដែលមានលទ្ធភាពតិចតួចទទួលបានធនធានមានផលិតភាពរស់នៅ គឺកាន់តែពិបាក និងតម្រូវឱ្យមានការគាំទ្រយ៉ាងសកម្មឲ្យពួកគេចាកចេញពីភាពទីទាល់ក្រ។ លក្ខណៈនៃទម្រង់ភាពទីទាល់ក្រទាំងនេះ និងភាពជាក់លាក់នៃសេដ្ឋកិច្ចកម្ពុជា ពង្រឹងតម្រូវការនៃគោលវិធីគ្រប់ជ្រុងជ្រោយនៃកិច្ចគាំពារសង្គម ដែលទទួលស្គាល់ និងដោះស្រាយការគំរាមកំហែង និងឱកាសផ្សេងគ្នា ដែលតែងតែជួបប្រទះដោយគ្រួសារជាច្រើនដែលមានជីវភាពទីទាល់ក្របំផុតនៅទីជនបទ។

## គោលវិធីបញ្ចប់ភាពទីទាល់ក្រ

ការសិក្សានេះ បង្ហាញអំពីគោលវិធីរបស់សកម្មជនក្នុងកិច្ចគាំពារសង្គម តាមរយៈអន្តរាគមន៍ដែលមានសក្តានុពល ដើម្បីដោះស្រាយបញ្ហាភាពទីទាល់ក្រ តាមរយៈការលើកឡើងពីពហុទិដ្ឋភាពនៃសេដ្ឋកិច្ចអបរិយាប័ន្នរបស់ជនទីទាល់ក្រនៅទីជនបទក្នុងប្រទេសកម្ពុជា។ វាបានស្វែងយល់ពីសក្តានុពលនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដែលមានរួមបញ្ចូលទាំងការផ្តល់ទ្រព្យផលិត ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការទូទាត់សាច់ប្រាក់។

ដោយផ្អែកលើគំនិតថា សាច់ប្រាក់តែម្យ៉ាងអាចមិនគ្រប់គ្រាន់ ដើម្បីជួយអ្នកទទួលផលក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្របានដាក់រួមបញ្ចូលគ្នានូវវិធានការបំពេញបន្ថែម ដែលចំណុចនីមួយៗកំណត់ទិដ្ឋភាពជាក់លាក់ ឬ មូលហេតុនៃភាពទីទាល់ក្រនៅកម្រិតគ្រួសារ។ អសុក្រិតភាពនៃទីផ្សារ និងឧបសគ្គចំពោះសកម្មភាពផលិតកម្ម បានរាំងស្ទះដល់ការអភិវឌ្ឍប្រកប និងរាំងស្ទះដល់បរិយាប័ន្នរបស់ជនក្រីក្រទៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ការផ្តល់ទ្រព្យផលិតទៅប្រជាទីទាល់ក្រនៅតាមទីជនបទ គឺទំនងជាផ្តល់ការគាំទ្រដល់បរិយាប័ន្នក្នុងការអភិវឌ្ឍជនបទ ក៏ដូចជាជួយទ្រទ្រង់កំណើនលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យនេះនាពេលថ្មីៗផងដែរ។ ដូចគ្នានេះដែរ ការផ្លាស់ប្តូរជំនាញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធដើម្បីដោះស្រាយបញ្ហាកង្វះខាតធនធានមនុស្ស ដែលត្រូវបានទទួលស្គាល់ជាយូរមកហើយថាជាការទប់ស្កាត់ផលិតកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមទីជនបទក្នុងប្រទេសកម្ពុជា។ បទពិសោធន៍ដែលទទួលបានក្នុងបរិយាកាសប្រតិបត្តិការប្រហាក់

ប្រហែលគ្នា និងភ័ស្តុតាងជាក់ស្តែងថ្មីមួយ គាំទ្រដល់ការទទួលស្គាល់គោលវិធីបញ្ចប់ភាពទីទាល់ក្រ គឺជាឧបករណ៍ដ៏មានប្រសិទ្ធផលដើម្បីលុបបំបាត់ភាពទីទាល់ក្រ។

## គោលវិធី និង វិធីសាស្ត្រវិភាគ

ការសិក្សានេះ បង្កើតឧបករណ៍វិភាគបែបបរិមាណមួយ ដែលបង្ហាញពីផលប៉ះពាល់នៃអន្តរាគមន៍ទាំងនោះទៅលើភាពទីទាល់ក្រ និងការបែងចែកប្រាក់ចំណូល ប៉ុន្តែក៏វិភាគទៅលើផលប៉ះពាល់នៃទីផ្សារក្នុងស្រុកតាមរយៈផលិតកម្មភាព និងពាណិជ្ជកម្ម និងពីការប៉ាន់ប្រមាណផលប៉ះពាល់ម៉ាក្រូសេដ្ឋកិច្ចជាស៊េរី។ សមាសធាតុម៉ាក្រូសេដ្ឋកិច្ចនៃឧបករណ៍នេះ មានគំរូគណនាសមតាទូទៅ (Computable General Equilibrium - CGE) ដែលបានបង្កើតឡើងដើម្បីបង្ហាញពីសេដ្ឋកិច្ចកម្ពុជា។ ដើម្បីអនុញ្ញាតឱ្យមានការវិភាគអំពីផលប៉ះពាល់ផ្នែកគោលនយោបាយ រចនាសម្ព័ន្ធមីក្រូសេដ្ឋកិច្ចរបស់គំរូគណនាសមតាទូទៅពីមុន ត្រូវបានកែសម្រួលដើម្បីរួមបញ្ចូលគំរូផលិតកម្មជាក់លាក់ សម្រាប់គ្រួសារនៅក្នុងក្របខណ្ឌសមតាទូទៅ។ ចំណុចនេះ អាចធ្វើឱ្យមានការតភ្ជាប់គ្រួសារគោលដៅទៅនឹងសេដ្ឋកិច្ចក្នុងស្រុករបស់ពួកគេ ដូច្នេះហើយ ការវិភាគពីផលត្រលប់នៃវិធានការការពារសង្គម ក្រៅពីផលប៉ះពាល់របស់ពួកគេទៅលើភាពទីទាល់ក្រ។ បន្ទាប់មកបណ្តុំនៃការអនុវត្តតាមខ្នាតតូច ត្រូវបានបង្កើតឡើងដោយផ្អែកលើទិន្នន័យពីការស្ទង់មតិគ្រួសារ ដែលឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងគ្រួសារផ្សេងៗគ្នានៃការបែងចែកប្រាក់ចំណូល ឥរិយាបថទាយជ្ជទាននៅក្នុងកត្តាផលិតកម្ម និងការពឹងផ្អែកលើទីផ្សារក្នុងស្រុកដើម្បីប្រើប្រាស់ និងដើម្បីបង្កើតប្រាក់ចំណូល។

ការសិក្សានេះ គឺបញ្ជាក់ពីបណ្តុំនៃបែបផែនជាច្រើនដែលតំណាងឱ្យអន្តរាគមន៍នានា ដែលអាចត្រូវបានពិចារណាដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួន ដើម្បីគាំទ្រដល់គ្រួសារដែលរស់នៅក្នុងភាពទីទាល់ក្រ។ វិធីសាស្ត្រនេះមានគោលដៅតាមដានផលប៉ះពាល់នៃអន្តរាគមន៍ទាំងនេះនៅថ្នាក់មូលដ្ឋាន វិភាគពីឥទ្ធិពលភ្លាមៗ និងបន្ទាប់បន្សំរបស់វាទៅលើទីផ្សារ និងពាណិជ្ជកម្ម យល់ដឹងអំពីទំនាក់ទំនងនៃការបែងចែកប្រាក់ចំណូល លទ្ធផលនៃការកាត់បន្ថយភាពទីទាល់ក្រ និងផលប៉ះពាល់ទៅលើសមាសធាតុម៉ាក្រូសេដ្ឋកិច្ចរួមទាំងកំណើនសេដ្ឋកិច្ច។

## លទ្ធផល និង សារគោលនយោបាយ

លទ្ធផល បង្ហាញពីប្រសិទ្ធភាពនៃអន្តរាគមន៍ ដែលរួមបញ្ចូលការផ្តល់ទ្រព្យផលិតភាពលើ ការកាត់បន្ថយភាពទីទាល់ក្រ។ តាមរយៈសណ្ឋានភាពទីទាល់ក្រនៅទីជនបទ និងសក្តានុពល ដែលបានបង្កើតឡើងយ៉ាងល្អនៃការគាំទ្រដោយផ្ទាល់លើវិស័យកសិកម្ម បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រផ្តល់នូវអត្ថប្រយោជន៍ជាច្រើន លើកម្មវិធីឧបត្ថម្ភសាច់ប្រាក់ធម្មតា។ របាយការណ៍នេះ ពិភាក្សាពីការដោះដូរគ្នារវាងជម្រើសនីមួយៗនៃគោលនយោបាយទាំងនេះ ទាំងទស្សនៈស្តីពីភាពទីទាល់ក្រ និងផលប៉ះពាល់ទូទៅលើសេដ្ឋកិច្ច។ ការស្រាវជ្រាវរកឃើញថា ខណៈដែលអន្តរាគមន៍សុវត្ថិភាពធម្មតាតែមួយអាចកាត់បន្ថយភាពទីទាល់ក្រ វាមិនត្រូវបានបញ្ជាក់ថាវាអាចជម្រុញសេដ្ឋកិច្ចបានឡើយ តែផ្ទុយទៅវិញ គឺទៅលើរាល់អន្តរាគមន៍បញ្ចប់ភាពទីទាល់ក្រទាំងអស់បាន ទាំងកាត់បន្ថយភាពទីទាល់ក្រ និងជម្រុញកំណើនសេដ្ឋកិច្ច។ លើសពីនេះទៀត ប្រតិបត្តិការដ៏ល្អបំផុត គឺកម្មវិធីទាំងឡាយដែលរួមបញ្ចូលគ្នានូវការគាំពារសង្គម ដើម្បីបញ្ចប់ភាពទីទាល់ក្រ ជាមួយនឹងការវិនិយោគសាធារណៈ ទៅលើហេដ្ឋារចនាសម្ព័ន្ធជនបទ និងការអភិវឌ្ឍកសិកម្ម។

លទ្ធផលនៃការសិក្សានេះ ក៏បង្ហាញផងដែរថា កម្មវិធីទាំងនេះទំនងជាអាចលើកស្ទួយបរិយាប័ន្ននៃគ្រួសារអ្នកទទួលផលនៅក្នុងសេដ្ឋកិច្ចមូលដ្ឋានរបស់ពួកគេ ដែលជាចំណែកដ៏សំខាន់នៃប្រាក់ចំណូលថ្មីរបស់ពួកគេ ដែលបានមកពីសកម្មភាពផលិតកម្មដែលត្រូវបានជម្រុញដោយគម្រោងបញ្ចប់ភាពទីទាល់ក្រ។ លទ្ធផលនេះ គឺផ្ទុយពីទឡ្ហីករណ៍អាស្រ័យភាពដែលជួនកាលទាក់ទងទៅនឹងគម្រោងគាំពារសង្គម ហើយដែលការយល់ឃើញបែបអវិជ្ជមានរបស់ពួកគេថា ជាកម្មវិធីជំនួយ។ អន្តរាគមន៍បញ្ចប់ភាពទីទាល់ក្រ ផ្តល់នូវមធ្យោបាយនៃការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច និងដែលមានរយៈពេលយូរអង្វែងដល់អ្នកទីទាល់ក្រ និងធានាបាននូវច្រកចេញរបស់ពួកគេពីភាពទីទាល់ក្រ។

លទ្ធផលនៃការអនុវត្តតាមទាំងអស់ ក៏បង្ហាញផងដែរថា ទាំងផលប៉ះពាល់នៃភាពទីទាល់ក្រ និងកំណើនសេដ្ឋកិច្ច ទំនងជាមានរយៈពេលលើសពីអំឡុងពេលអនុវត្តកម្មវិធី ដោយសារឥទ្ធិពលជាកាត្តាលីករនៃទ្រព្យផលិត និងជំនាញវិជ្ជាជីវៈនៅតែមានបន្ត បើទោះជាកម្មវិធីបានបញ្ចប់។ ការរកឃើញទាំងនេះ បានពង្រឹងតម្រូវការក្នុងការទទួលយកទស្សនៈវែងឆ្ងាយ ដើម្បីចាប់យកប្រសិទ្ធិផលពេញលេញនៃគោលវិធី បញ្ចប់ភាពទីទាល់ក្រ និងប៉ាន់ប្រមាណផលប្រយោជន៍ ដែលទាក់ទងទៅនឹងការចំណាយទាំងឡាយរបស់ពួកគេ។ វាក៏បង្ហាញពីភាពពាក់ព័ន្ធនៃគោលវិធីបញ្ចប់ភាពទីទាល់ក្រ ដើម្បីផ្តល់អំណាចផ្នែកសេដ្ឋកិច្ចដល់គ្រួសារដែលអាចចូលរួមក្នុងសកម្មភាពផលិតកម្ម ដោយមិនចាំបាច់សង្ស័យអំពីតម្រូវការផ្តល់សាច់ប្រាក់ សម្រាប់គ្រួសារដែលមិនបានទទួល។ កម្មវិធីបញ្ចប់ភាពទីទាល់ក្រ មានតួនាទីសំខាន់ជាសក្តានុពលក្នុងការដាក់ចេញនូវកំណែទម្រង់កិច្ចគាំពារសង្គមនៅក្នុងប្រទេសកម្ពុជា ដូចមានចែងនៅក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ( NSPPF ) ។



# គោលបំណង

បើយោងតាមរបាយការណ៍ពីភាពទីទាល់ក្រនាពេលថ្មីៗនេះ (ធនាគារពិភពលោក ឆ្នាំ២០១៧) ភាពទីទាល់ក្រនៅកម្ពុជាបានថយចុះយ៉ាងឆាប់រហ័ស និងជាបន្តបន្ទាប់ក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ ប្រមាណពី៥៣% នៅក្នុងឆ្នាំ២០០៤ មកនៅក្រោម១៣.៥% នៅឆ្នាំ២០១៤។ បើទោះបីជាប្រជាជនទាំងនេះ មិនត្រូវបានរាប់បញ្ចូលក្នុងកម្រិតភាពទីទាល់ក្រ បើយោងតាមខ្សែបន្ទាត់ភាពទីទាល់ក្រជាតិ គ្រួសាររាប់លានគ្រួសារនៅតែស្ថិតនៅក្នុងស្ថានភាពលំបាក ដែលបណ្តាលមកពីភាពមិនប្រក្រតីផ្នែកហិរញ្ញវត្ថុ និងតម្រូវការកិច្ចគាំពារសង្គម។ សព្វថ្ងៃនេះ មានការយល់ដឹងកើនឡើងច្រើនរវាងអ្នកអនុវត្ត និងអ្នកស្រាវជ្រាវ ទៅលើប្រសិទ្ធភាពនៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ (CTs) ដើម្បីផ្តល់នូវសំណាញ់សុវត្ថិភាពរហ័ស និងការពាររបរចិញ្ចឹមជីវិតរបស់ប្រជាក្រីក្រ ហើយមានកំណើនគួរឲ្យចាប់អារម្មណ៍នៃចំនួនប្រទេសកំពុងអភិវឌ្ឍន៍ដែលបានអនុវត្តជោគជ័យតាមរយៈកម្មវិធីនេះ ក្នុងការបង្កើតនូវការគាំពារសង្គមប្រកបទៅដោយសុវត្ថិភាព។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធីឧបត្ថម្ភសាច់ប្រាក់តែម្យ៉ាង ក៏ប្រហែលជាមិនគ្រប់គ្រាន់សម្រាប់លើកកម្ពស់សកម្មភាពបង្កើតប្រាក់ចំណូលរបស់អ្នកទទួលផល និងធ្វើឲ្យជីវភាពរបស់ពួកគេប្រសើរឡើងនោះទេ។ ការវិនិយោគលើធនធានមនុស្ស និងសម្ភារៈ បូករួមនឹងការឧបត្ថម្ភសាច់ប្រាក់ គឺជាមធ្យោបាយដ៏មានសក្តានុពលដើម្បីពង្រឹងជីវភាពរស់នៅរបស់អ្នកទទួលផលប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព។ គំរូបញ្ចប់ភាពទីទាល់ក្រ ដែលសំដៅដល់ការរួមបញ្ចូលគ្នានូវការឧបត្ថម្ភសាច់ប្រាក់ ការបណ្តុះបណ្តាល និងការផ្តល់ទ្រព្យផលិតត្រូវបានសាកល្បងនៅក្នុងប្រទេសជាច្រើននាឆ្នាំកន្លងទៅ។ ផលប៉ះពាល់របស់វា ត្រូវបានជឿថា លើសពីការឧបត្ថម្ភសាច់ប្រាក់តែម្យ៉ាងក្នុងរយៈពេលវែង ដែលវាក៏ផ្តល់នូវមធ្យោបាយដើម្បីដោះស្រាយបុព្វហេតុនៃភាពទីទាល់ក្រ ដល់គ្រួសារដែលអាចចូលរួមក្នុងសកម្មភាពផលិតកម្ម។ ថ្វីត្បិតវាមានការចំណាយខ្ពស់ក្នុងរយៈពេលខ្លីយ៉ាងណាក្តី ក៏បណ្តុំអន្តរាគមន៍ទាំងនេះនៅតែថា វាអាចជួយពង្រឹងការបន្សាំឲ្យមានភាពប្រសើរឡើង និងអាចរំដោះខ្លួនចេញពីបន្ទាត់ភាពទីទាល់ក្រ ប្រកបដោយប្រសិទ្ធភាព (Banerjee et al ឆ្នាំ២០១៥)។

តើមានឥទ្ធិពលអ្វីខ្លះ ដែលអាចរំពឹងថានឹងកើតឡើង ប្រសិនបើអន្តរាគមន៍ដូចនេះត្រូវបានអនុវត្ត នៅក្នុងប្រទេសកម្ពុជា? តើមានអត្ថប្រយោជន៍អ្វីខ្លះពីអន្តរាគមន៍ទាំងនេះ បើធៀបទៅនឹងការផ្តល់សាច់ប្រាក់តែម្យ៉ាង? នៅក្នុងសេដ្ឋកិច្ចកសិកម្មរបស់ប្រទេសកម្ពុជា តើការផ្តល់ទ្រព្យផលិតឲ្យដល់ប្រជាក្រីក្រនៅតាមទីជនបទ គឺជាការដាក់បញ្ចូលពួកគេទៅក្នុងការអភិវឌ្ឍជនបទ និងលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋានរបស់ពួកគេ ទន្ទឹមនឹងការសម្រេចបាន នូវកំណើនឆាប់រហ័សនៃវិស័យកសិកម្មកន្លងមកនេះដែរឬទេ? តើមានការរៀបចំអន្តរាគមន៍ភាពទីទាល់ក្របំពេញបន្ថែមនៅតាមមូលដ្ឋាន ដែលអាចផ្តល់អំណះអំណាងនៃភាពត្រឹមត្រូវសម្រាប់គូសគ្រោងបទអន្តរាគមន៍កាត់បន្ថយភាពទីទាល់ក្រ ដែលមានចំណុចប្រសព្វជាមួយគោលនយោបាយអភិវឌ្ឍន៍ជនបទនៅថ្នាក់មូលដ្ឋានដែរឬទេ? ឯកសារសិក្សានេះ មានគោលបំណងបង្ហាញពីអំណះអំណាងឆ្លើយតបទៅនឹងសំណួរទាំងអស់នេះ ក្នុងបរិបទសេដ្ឋកិច្ច និងភាពទីទាល់ក្រនៅប្រទេសកម្ពុជា។

សមាសភាគទី១នៃការសិក្សានេះ ផ្តោតទៅលើការកំណត់ និងតាមដានផលប៉ះពាល់អំពីការឧបត្ថម្ភប្រាក់ និងវិធានទាំងឡាយ ដែលអាចកើតមានចំពោះភាពទីទាល់ក្រ ក៏ដូចជាសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ដើម្បីធ្វើដូច្នេះបាន ការសិក្សានេះ បង្កើតនូវគំរូគណនាសមតាទូទៅមួយ (CGE) ដែលរៀបរាប់ពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា និងទំនាក់ទំនងជាមួយនឹងភ្នាក់ងារសេដ្ឋកិច្ចរបស់ខ្លួន។ បណ្តុំនៃការអនុវត្តតាមមួយ ត្រូវបានធ្វើឡើងដើម្បីតំណាងឲ្យវិធានទាំងឡាយ ដែល យូអិនឌីភីប្រចាំនៅកម្ពុជា ពិចារណាក្នុងការជួយគាំទ្រដល់ប្រទេសកម្ពុជានៅតាមទីជនបទ។ ការវិភាគលទ្ធផលអនុវត្តតាមទាំងនេះ អាចឲ្យយើងកំណត់បាននូវមធ្យោបាយសំខាន់ៗ ដើម្បីឲ្យដឹងថា អន្តរាគមន៍មួយណាដែលមានផលប៉ះពាល់ទៅដល់អ្នកទទួលផលក្នុងវិស័យសេដ្ឋកិច្ចតាមមូលដ្ឋាន ទន្ទឹម

ទៅនឹងការវាស់ស្ទង់ផលប៉ះពាល់ដោយផ្ទាល់ ឬ ដោយប្រយោលទៅលើវិស័យដែលមានផលិតភាព ពាណិជ្ជកម្ម និងវិស័យដែលនឹងមានកំណើនក្នុងប្រទេស។ វិធីសាស្ត្រគំរូអនុវត្តតាមខ្នាតតូច ត្រូវបានប្រើដើម្បីវិភាគផលប៉ះពាល់សំខាន់ៗ ដែលកើតមានលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាក្រីក្រ ដោយយោងទៅតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្ររបស់ពួកគេ ព្រមទាំងវត្តមានរបស់ខ្លួនក្នុងទីផ្សារនៅតាមទីជនបទ។ តាមរយៈការប្រើប្រាស់ទិន្នន័យអង្កេតគ្រួសារ ការសិក្សានេះក៏ធ្វើការវិភាគអំពីការបែងចែកចំណូលរបៀបថ្មីមួយ រវាងប្រជាក្រីក្រនៅតាមទីជនបទនិងទីក្រុង ប៉ាន់ស្មាននូវសក្តានុពលនៃការកាត់បន្ថយភាពទីទាល់ក្រ នៃអន្តរាគមន៍នីមួយៗ និងពិភាក្សាអំពីជំនួញក្រោយដំណាក់កាលទីមួយនៃការអនុវត្តកម្មវិធី។ សមាសភាគទី២នៃការសិក្សានេះ គឺផ្តោតទៅលើការបំពេញឲ្យគ្នារវាង បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា។ ដោយសារតែ ៩០% នៃប្រជាទីទាល់ក្រនៅកម្ពុជារស់នៅតាមទីជនបទ ដូច្នេះ ជីវភាពរបស់ពួកគេគឺពឹងផ្អែកលើទីផ្សារនៅជនបទ។ ការជួយគាំទ្រទីផ្សារ ទន្ទឹមគ្នាទៅនឹងការអនុវត្តសង្គហទានសង្គម អាចជួយលើកកម្ពស់ប្រសិទ្ធភាព ទាំងវិធានការ និងការសហការគ្នានៅកម្រិតមូលដ្ឋានឲ្យកាន់តែប្រសើរឡើង។

ការវិភាគលទ្ធផលនៃការអនុវត្តតាម បានផ្តល់ជាអំណះអំណាងជាក់ស្តែង ដើម្បីការរៀបចំអន្តរាគមន៍ និងការប្រើប្រាស់មូលនិធិ ប្រកបដោយប្រសិទ្ធភាពដើម្បីជាប្រយោជន៍ដល់ជនទីទាល់ក្រ ទន្ទឹមទៅនឹងការចូលរួមក្នុងសេដ្ឋកិច្ច និងការសហការគ្នាប្រកបដោយ សក្តានុពលនៅថ្នាក់មូលដ្ឋាន។ លទ្ធផលបានបង្ហាញថា បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ផ្តល់នូវវិសាលភាពធំធេង សម្រាប់ការដោះស្រាយបុព្វហេតុនៃភាពទីទាល់ក្រ ទន្ទឹមទៅនឹងការជម្រុញសេដ្ឋកិច្ចមូលដ្ឋានរបស់អ្នកទទួលផល។ ត្បិតគំរូទាំងនេះ មានការចំណាយច្រើនក្នុងរយៈពេលខ្លីយ៉ាងណាក្តី ក៏ប៉ុន្តែការអនុវត្តត្រឹមរយៈពេលពីរឆ្នាំប៉ុណ្ណោះ នឹងផ្តល់អត្ថប្រយោជន៍លើសពីអត្ថប្រយោជន៍នៃការឧបត្ថម្ភសាច់ប្រាក់។ បន្ថែមពីលើការកាត់បន្ថយភាពទីទាល់ក្រដ៏គួរឲ្យកត់សម្គាល់ ការបញ្ចូលគ្នារវាងការឧបត្ថម្ភសាច់ប្រាក់ និងការផ្តល់ទ្រព្យផលិត អាចធ្វើឲ្យអ្នកចូលរួមបង្កើតបានចំណូលដោយខ្លួនឯងពីសកម្មភាពមានផលិតភាពទាំងនោះ ហើយជាការចូលរួមចំណែកក្នុងសេដ្ឋកិច្ច ក្នុងមូលដ្ឋានរបស់ពួកគេ និងប្រែក្លាយខ្លួនពីស្ថានភាពជាអ្នកទទួលជំនួយ ទៅជាអ្នកបង្កើតទ្រព្យសម្បត្តិដោយខ្លួនឯង។ លទ្ធផលនៃការសិក្សានេះ ក៏បង្ហាញផងដែរថា ការរួមបញ្ចូលគ្នារវាងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ជាមួយនឹងគោលនយោបាយកំណើនវិស័យកសិកម្ម អាចជាចលករដ៏សំខាន់មួយសម្រាប់កំណើនសេដ្ឋកិច្ច និងជួយរក្សាបាននូវនិន្នាការដ៏ខ្លាំងលើការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពទីទាល់ក្រនាពេលបច្ចុប្បន្ននេះ។

របាយការណ៍នេះ ត្រូវបានរៀបចំឡើងក្នុងទម្រង់ដូចខាងក្រោម។ ផ្នែកទី១ បង្ហាញពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ គោលបំណង និងលទ្ធផលការស្រាវជ្រាវមានស្រាប់ អំពីផលប៉ះពាល់រហ័ស និងយូរអង្វែង។ បន្ទាប់មក យើងពិភាក្សាអំពីសក្តានុពល ដែលពាក់ព័ន្ធទៅនឹងគ្រួសារទីទាល់ក្រក្នុងបរិបទសេដ្ឋកិច្ច និងកម្រិតភាពទីទាល់ក្រនៅប្រទេសកម្ពុជា។ ផ្នែកទី២ ណែនាំអំពីវិធីសាស្ត្រសម្រាប់វិភាគផលប៉ះពាល់សំខាន់ៗនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដែលកើតមានលើជនទីទាល់ក្រ ដោយពន្យល់ពីអ្វីដែលជាគំរូសមតាទូទៅ និងមូលហេតុដែលបញ្ជាក់ថា វាជាមធ្យោបាយវិភាគមួយឆ្លើយតបទៅនឹងសំណួរដែលបានរៀបរាប់នៅខាងលើ។ បន្ថែមពីនេះ ក្នុងផ្នែកនេះក៏មានការបរិយាយអំពីសំនុំទិន្នន័យ សម្មតិកម្មគំរូ និងភាពជាក់លាក់ផងដែរ។ សំណុំការអនុវត្តតាម ត្រូវបានរៀបចំឡើង ដើម្បីចាប់យកនូវផលប៉ះពាល់សំខាន់ៗពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រផ្សេងៗ ក៏ដូចជាធ្វើការសាកល្បងនូវការបំពេញឲ្យគ្នា ឬ ការថ្លឹងថ្លែង រវាងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍ជនបទ។ ផ្នែកទី៣ ពិភាក្សាពីលទ្ធផលអនុវត្តតាម និងបង្ហាញការវិភាគស៊ីជម្រៅអំពីផលប៉ះពាល់លើភាពទីទាល់ក្រ ទៅតាមសេណារីយ៉ូនីមួយៗ តាមរយៈការអនុវត្តតាមខ្នាតតូច ដោយផ្អែកលើទិន្នន័យអង្កេតគ្រួសារដែលមានស្រាប់។ របាយការណ៍នេះធ្វើការសន្និដ្ឋាន តាមរយៈការពិភាក្សាអំពីគោលនយោបាយដោយផ្អែកលើលទ្ធផល និងធ្វើការណែនាំអំពីកត្តាសេដ្ឋកិច្ច ដែលគួរតែត្រូវបានយកទៅគិតគូរសម្រាប់ការរៀបចំអន្តរាគមន៍ ដើម្បីបញ្ចប់ភាពទីទាល់ក្រនៅប្រទេសកម្ពុជា។

# ផ្នែកទី ១ បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រក្នុងបរិបទប្រទេសកម្ពុជា

## បរិបទកិច្ចគាំពារសង្គមនៅកម្ពុជា

ភាពទីទាល់ក្រនៅប្រទេសកម្ពុជា មានការថយចុះយ៉ាងឆាប់រហ័សគិតពីឆ្នាំ២០០៤មក ដោយសារតែមានការអភិវឌ្ឍជនបទជាបន្តបន្ទាប់ក្នុងប្រទេស ដែល៩០%នៃប្រជាជនក្រីក្រគឺរស់នៅតាមទីជនបទ។ យោងតាមដៃគូអភិវឌ្ឍន៍កម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០១៥ និង ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១២) ការរីកចម្រើននៃវិស័យកសិកម្ម គឺជាកត្តាសំខាន់ជាងគេក្នុងការកាត់បន្ថយភាពទីទាល់ក្រនាទសវត្សរ៍ចុងក្រោយនេះ។ ឱកាសសេដ្ឋកិច្ចថ្មីៗ និងការកើនឡើងនូវប្រាក់ឈ្នួលនៅតាមទីជនបទ បានធ្វើឲ្យកំណើនសេដ្ឋកិច្ចជួយទៅក្នុងការកាត់បន្ថយភាពទីទាល់ក្រប្រកបទៅដោយចិរភាព និងធ្វើឲ្យជីវភាពរស់នៅតាមទីជនបទមានភាពប្រសើរឡើង។ ទោះជាយ៉ាងណាក៏ដោយ មានចំណុចជាច្រើននៅតែជាបញ្ហាប្រឈមដល់ការរក្សាបាននូវនិរន្តភាពនៃដំណើរការសង្គម និងសេដ្ឋកិច្ចដ៏គួរឲ្យកត់សម្គាល់នេះ៖

- ប្រជាជនជាច្រើនក្នុងចំណោមអ្នកមានកម្រិតចំណូល និងការប្រើប្រាស់កើនឡើង និងមិនស្ថិតក្នុងភាពទីទាល់ក្រ គឺនៅតែស្ថិតនៅកៀកទៅនឹងចំណុចបន្ទាត់នៃភាពទីទាល់ក្រនៅឡើយ។ ដូច្នេះ មានប្រជាជនរាប់លានអ្នកកំពុងស្ថិតនៅក្នុងភាពងាយរងគ្រោះខ្លាំងទៅនឹងវិបត្តិ និងភាពតានតឹងផ្នែកហិរញ្ញវត្ថុ។ ធនាគារពិភពលោក (ឆ្នាំ២០១៥) បានប៉ាន់ស្មានថា ប្រសិនបើគេដកប្រាក់ចំនួន ០.៣០ដុល្លារពីចំណូលក្នុងមួយថ្ងៃរបស់គ្រួសារ ដែលស្ថិតលើបន្ទាត់ភាពទីទាល់ក្រ "នោះនឹងធ្វើឲ្យប្រជាជនកម្ពុជាប្រមាណ ៣លាននាក់ ធ្លាក់ទៅក្នុងភាពទីទាល់ក្រវិញ និងបណ្តាលឲ្យអត្រាភាពទីទាល់ក្រកើនដល់៤០%"។
- ភាពងាយរងគ្រោះ គឺជាធម្មតាមានអត្រាខ្ពស់ក្នុងចំណោមគ្រួសារដែលមានមេគ្រួសារជាស្ត្រី ហើយស្ត្រីមានផលវិបាកដោយសារតែឱកាសសេដ្ឋកិច្ចសម្រាប់ពួកគាត់ នៅមានកម្រិត និងពិបាកក្នុងការទទួលបានទ្រព្យផលិត។



- ភាពខុសគ្នាតាមតំបន់ គឺនៅតែបន្តកើតមានតាមបណ្តាខេត្តនៅកម្ពុជា៖ តំបន់ដាច់ស្រយាលដែលមានការខ្វះខាតខាងអំណោយទានធនធានធម្មជាតិ និងកង្វះការផ្តល់ទំនិញនិងសេវាសាធារណៈ គឺជាតំបន់ដែលមានអត្រាភាពទីទាល់ក្រខ្ពស់។
- ដោយសារតែភាពទីទាល់ក្រដែលធ្លាក់ចុះយ៉ាងឆាប់រហ័សបានកើតមានឡើងជាញឹកញយ ការកាត់បន្ថយភាពទីទាល់ក្រនៅកម្ពុជាកន្លងមកនេះ គឺអាចមកពីការចូលរួមចំណែកខ្ពស់ពីចំណូលរបស់ជនក្រីក្រ ខណៈដែលបញ្ហាភាពទីទាល់ក្រដែលលំបាកៗ គឺនៅតែចាំបាច់ត្រូវដោះស្រាយ។ គ្រួសារស្ថិតនៅក្រោមភាពទីទាល់ក្រ ប៉ុន្តែមិនឆ្ងាយពីបន្ទាត់នៃភាពទីទាល់ក្រ គឺជាអ្នកដែលទទួលបានប្រយោជន៍ដំបូងគេពីការអភិវឌ្ឍសេដ្ឋកិច្ច ខណៈដែលគ្រួសាររស់នៅតំបន់ឆ្ងាយៗ ឬ ពិបាកទទួលបានទ្រព្យផលិត គឺមានភាពពិបាក

ក្នុងការចាកចេញពីភាពទីទាល់ក្រ (ពេលខ្លះការប្រៀបធៀបរវាង "ផ្លែឈើដើមខ្ពស់" និង "ដើមទាប"ត្រូវបានប្រើប្រាស់ដើម្បីពន្យល់ពីលក្ខណៈនៃការកាត់បន្ថយភាពទីទាល់ក្រ)។

- ថ្វីបើមានការខិតខំប្រឹងប្រែងជាច្រើនក៏ដោយ ក៏ការផ្តល់គោលនយោបាយគាំពារសង្គមរបស់កម្ពុជា នៅតែមានលក្ខណៈខ្វះខាត ហើយការដោះស្រាយបញ្ហាភាពទីទាល់ក្រនៅកម្ពុជានៅតែជាបញ្ហាប្រឈមរហូត លុះត្រាតែសំណាញ់សុវត្ថិភាពត្រូវបានផ្តល់ប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជា (RGC) ថ្មីៗនេះបានអនុម័តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPPF) ដែលផ្តល់នូវផែនការសម្រាប់ការអភិវឌ្ឍប្រព័ន្ធជានាប់រៀងសង្គម និងកម្មវិធីជំនួយសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ។ នេះក៏ជាឱកាសក្នុងការបង្កើតការគាំពារសង្គម ដែលប្រកបដោយប្រសិទ្ធភាពតាមរយៈបណ្តុំនៃកម្មវិធី និងគោលនយោបាយថ្មីៗ រាប់បញ្ចូលទាំងវិធីសាស្ត្រ ដែលត្រូវបានសាកល្បងក្នុងរបាយការណ៍នេះផងដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) ដែលបានដឹកនាំការបង្កើតឡើងនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ បានគូសបញ្ជាក់ពីសារសំខាន់នៃការបង្កើតប្រព័ន្ធគាំពារសង្គមដែលទំនើប និងជំណើការទៅមុខ និងដែលវាអាចជួយដោះស្រាយភាពងាយរងគ្រោះ និងភាពទីទាល់ក្របាន គឺអាចបង្កើតបានក្នុងតម្លៃសមរម្យ ហើយមានប្រសិទ្ធភាព និងផ្តល់បាននូវផលប្រយោជន៍សេដ្ឋកិច្ចយ៉ាងទូលំទូលាយ។

វិបត្តិ និងភាពគានតឹងផ្នែកហិរញ្ញវត្ថុលើគ្រួសារ ដែលស្ថិតនៅក្រោម និងលើបន្ទាត់ភាពទីទាល់ក្របន្តិច នឹងកាន់តែមានភាពលំបាកឡើង ដោយសារកង្វះខាតមូលដ្ឋានគាំពារសង្គម។ បើយោងតាមធនាគារអភិវឌ្ឍន៍អាស៊ីបានបង្ហាញថា ប្រជាជនទីទាល់ក្រនៅកម្ពុជាត្រឹមតែ២%ប៉ុណ្ណោះ ដែលទទួលបានសំណាញ់សុវត្ថិភាពសង្គម។ បើធ្វើការប្រៀបធៀបទៅ ចំណែកប្រជាជនទីទាល់ក្របំផុតនៅតាមបណ្តាប្រទេសនៅអាស៊ីខាងកើត គឺមានប្រមាណ៥៣% ហើយបើគិតជាមធ្យម គឺឈានដល់៤៩% ដែលនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍទាំងអស់ (ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៣)។ សន្ទស្សន៍គាំពារសង្គមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានជួយដល់ដំណើរការវាស់ស្ទង់ និងត្រួតពិនិត្យនៅក្នុងតំបន់ បានចាត់ប្រទេសកម្ពុជាក្នុងចំណាត់ថ្នាក់ទី៣៤ ក្នុងចំណោម៣៥ប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ចំណាយជាក់ស្តែងរបស់កម្ពុជាលើកិច្ចគាំពារសង្គម សម្រាប់អ្នកទទួលផលគោលដៅម្នាក់ ស្មើនឹង ២% នៃប្រាក់ចំណាយដែលត្រូវការ ដើម្បីគ្របដណ្តប់បានលើប្រជាជនទីទាល់ក្រ។

ដូច្នេះ វាជាតម្រូវការយ៉ាងច្បាស់ និងសំខាន់បំផុត ក្នុងការបង្កើតការគាំពារសង្គមនៅកម្ពុជា តាមរយៈការផ្តល់សំណាញ់សុវត្ថិភាព ដែលអនុញ្ញាតឲ្យជនទីទាល់ក្រទទួលបាននូវតម្រូវការប្រើប្រាស់ និងការគាំពារជីវភាពរបស់ពួកគេ។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលមានស្រាប់នៅកម្ពុជាអាចជួយកំណត់អត្តសញ្ញាណ និងដៅយកអ្នកទទួលផលពីកម្មវិធីទាំងនេះបាន។ លើសពីនេះទៅទៀត ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPF) ផ្តល់ជាយុទ្ធសាស្ត្រគោលនយោបាយ ដើម្បីរក្សាបាននូវនិន្នាការកាត់បន្ថយភាពទីទាល់ក្រ និងដោះស្រាយបញ្ហាភាពស្មុគស្មាញនៃភាពទីទាល់ក្រ ដែលស្ថិតនៅតាមខេត្តដែលលំបាក ទីតាំងនៅឆ្ងាយ និងដាច់ស្រយាល។ សំណើរដែលបានបង្ហាញក្នុងការសិក្សានេះ មានបំណងផ្តល់ជាព័ត៌មាន ដើម្បីអនុវត្តកំណែទម្រង់ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។

## កំណើនវិស័យកសិកម្មជាចលករមួយក្នុងការកាត់បន្ថយភាពទីទាល់ក្រ

ក្នុងទសវត្សរ៍ចុងក្រោយនេះ វិស័យកសិកម្ម គឺជាចលករដ៏រឹងមាំមួយ ដែលជួយធ្វើឲ្យមានការរីកចម្រើននៅកម្ពុជា និងជាសក្តានុពលដ៏សំខាន់ ក្នុងការធ្វើឲ្យគ្រួសារនៅតាមទីជនបទចាកចេញពីភាពទីទាល់ក្រ។ គោលបំណងក្នុងការសិក្សានេះ អាចឲ្យយើងយល់បានថា ការផ្តល់ធនធានមនុស្ស និងសម្ភារៈជួយដល់ផលិតកម្មកសិកម្ម មានអត្ថប្រយោជន៍ច្រើនជាងការផ្តល់ជាសាច់ប្រាក់ ក្នុងការដោះស្រាយបញ្ហាភាពទីទាល់ក្រ ជាពិសេសនៅកន្លែងដែលពិបាកដោះស្រាយ។

នៅចន្លោះឆ្នាំ២០០៤ និង ២០១២ វិស័យកសិកម្មនៅកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូររចនាសម្ព័ន្ធសំខាន់មួយ គឺពី

ការធ្វើកសិកម្ម ដើម្បីចិញ្ចឹមជីវិតតាមបែបប្រពៃណីទៅជាកសិពាណិជ្ជកម្មទំនើប (ធនាគារពិភពលោក ឆ្នាំ២០១៥)។ វាជាវិស័យកសិកម្ម ដែលមានកំណើនខ្លាំងជាងគេក្នុងតំបន់នៅអំឡុងឆ្នាំ២០០២-២០១២ជាមួយនឹងអត្រាកំណើនប្រហែល ៩.៦% ក្នុងមួយឆ្នាំ។ ការពង្រីកដីកសិកម្ម ការប្រើប្រាស់គ្រឿងម៉ាស៊ីន ការធ្វើពិធីកម្មដំណាំ ប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ជី និងគ្រាប់ពូជកែច្នៃ ជាកត្តាដែលធ្វើឲ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធកសិកម្មនៅកម្ពុជាក្នុងអំឡុងពេលនោះ។ ជាលទ្ធផល កត្តាផលិតកម្មកសិកម្មកាន់តែមានប្រសិទ្ធភាព ហើយទិន្នផលដំណាំបានកើនឡើងយ៉ាងឆាប់រហ័សឆ្ពោះទៅរកមធ្យមភាគក្នុងតំបន់។ តម្លៃកសិកម្មខ្ពស់ បានធ្វើឲ្យមានការកើនឡើងនូវការប្រើប្រាស់ឧបករណ៍ទំនើប និងនាំឲ្យកសិករសម្របទៅនឹងបច្ចេកវិទ្យាថ្មីៗ ដោយសារផលចំណេញរំពឹងទុករបស់ពួកគេបានកើនឡើង។

ទោះជាយ៉ាងណាក៏ដោយ ក្នុងស្ថានភាពផលិតកម្មមានការធ្លាក់ចុះនាពេលថ្មីៗនេះ ចម្ងល់ត្រូវបានលើកឡើងថាតើកំណើនរបស់វិស័យកសិកម្មអាចបន្ត ដោយគ្មានការជ្រោមជ្រែងគ្រប់ជ្រុងជ្រោយពីសាធារណៈដែរឬយ៉ាងណា។ ការចុះខ្សោយនិន្នាការកំណើនវិស័យកសិកម្ម អាចបណ្តាលឲ្យជីវភាពរស់នៅរបស់ប្រជាជនរាប់លាននាក់ ដែលជាជនងាយរងគ្រោះ មានការផ្លាស់ប្តូរតិចតួចដល់ចំណូលរបស់ពួកគេ។ ដើម្បីរក្សាបាននូវនិន្នាការកាត់បន្ថយភាពទីទាល់ក្របច្ចុប្បន្ននេះ ការចូលរួមដោយត្រឹមត្រូវ ទៅក្នុងដំណើរការនៃការផ្លាស់ប្តូររចនាសម្ព័ន្ធត្រូវការបន្តរក្សាឲ្យបាន។ ខណៈដែលកំណើនវិស័យកសិកម្មដ៏មានសារសំខាន់ផ្តល់នូវឱកាសបង្កើតចំណូល និងកាត់បន្ថយភាពទីទាល់ក្រសម្រាប់ឆ្នាំបន្តបន្ទាប់ទៀត ការសម្រេចចិត្តលើគោលនយោបាយត្រូវធ្វើឡើង ហើយជំនួយសាធារណៈប្រកបដោយប្រសិទ្ធភាព ត្រូវអនុវត្តដើម្បីឲ្យកម្ពុជាធ្វើដំណើរលើផ្លូវត្រឹមត្រូវបន្តទៀត (ធនាគារពិភពលោក ឆ្នាំ២០១៥)។

យុទ្ធសាស្ត្រគាំពារសង្គមគ្រប់ជ្រុងជ្រោយ គួរទទួលស្គាល់ និងដោះស្រាយកត្តាគំរាមកំហែងដល់ជីវភាពរស់នៅរបស់គ្រួសារនៅតាមជនបទទាំងនោះ។ សម្រាប់កសិករជាច្រើន ដែលស្ថិតនៅកម្រិតទាបបំផុតនៃការបែងចែកប្រាក់ចំណូល ការអនុវត្តវិធានការដែលគាំទ្រ និងពង្រឹងសកម្មភាពរកចំណូលរបស់ពួកគេក្លាយជាវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាព ដែលអាចការពារជីវភាពរស់នៅរបស់ពួកគេ។ ភាពងាយរងគ្រោះមានកម្រិតខ្ពស់សម្រាប់កសិករដែលមានស្រែចម្ការតូច មានកម្រិតដើមទុនតិច ផលិតភាពទាប និងពឹងផ្អែកច្រើនទៅលើបច្ចេកទេសតាមបែបប្រពៃណី។ កសិករទាំងនេះ ទទួលផលប្រយោជន៍ពីការឡើងថ្លៃកសិផល ដូច្នេះតម្លៃនៃផលិតកម្មបានប្រសើរឡើង ប៉ុន្តែផលិតភាពដី និងពលកម្មរបស់ពួកគេ នៅតែទាបជាងមធ្យមភាគរបស់ប្រទេស (ធនាគារពិភពលោក ឆ្នាំ២០១៥)។ ដូចនេះ "បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ" គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ ដើម្បីឲ្យកសិករទាំងនេះមានសមត្ថភាពផលិតប្រសើរឡើង និងប្រកបដោយប្រសិទ្ធភាព។

នៅក្នុងការសិក្សានេះ យើងនឹងស្វែងរកសក្តានុពលនៃវិធានការទាំងនេះ តាមរយៈមធ្យោបាយដូចខាងក្រោម៖

១. ការផ្តល់ទ្រព្យផលិត ដែលជាសមាសភាគសំខាន់ក្នុងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដល់កសិករខ្នាតតូចចំនួន ១លាននាក់ ធ្វើឲ្យមានការទិញយកនូវឧបករណ៍កសិកម្ម សត្វចិញ្ចឹម បង្កើនដើមទុន ក៏ដូចជាផលិតភាពពលកម្ម និងដី ដែលស្ថិតនៅក្រោមមធ្យមភាគថ្នាក់ជាតិ។
២. ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួយដល់ផលិតភាពពលកម្ម និងបង្កើនទិន្នផល។
៣. ការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម និងទំនិញសាធារណៈ គឺជាការបំពេញឲ្យបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ។
៤. ការវិនិយោគសាធារណៈលើប្រព័ន្ធផ្លូវ និងការដឹកជញ្ជូន ដែលជាវិធានការបំពេញបន្ថែម ដើម្បីធ្វើឲ្យដំណើរការទីផ្សារនៅតាមទីជនបទមានភាពប្រសើរឡើង។

កង្វះខាតសេវាហិរញ្ញវត្ថុសម្រាប់គ្រួសារ នៅតាមទីជនបទជារឿយៗនៅប្រទេសកម្ពុជាត្រូវបានគេចង្អុលបង្ហាញថា គឺជាមូលហេតុនៃការខកខានឱកាសវិនិយោគ និងរារាំងការអនុវត្តបច្ចេកវិទ្យាថ្មីៗ។ នៅក្នុងបរិបទនៃវិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រ ការស្រាវជ្រាវបង្ហាញថា អ្នកចូលរួមមានទំនោរជ្រើសយកការសត្វចិញ្ចឹម ជាជាងឧបករណ៍កសិកម្ម។ បើជម្រើសទាំងនេះត្រូវបានផ្តល់ឲ្យ យើងគ្មានអំណះអំណាងណា ដើម្បីបញ្ជាក់ថាគ្រួសារនៅកម្ពុជាជ្រើសរើសយកជម្រើសណានោះទេ។ អាស្រ័យ

លើទំហំស្រែ ចម្ការ និងដីរបស់ពួកគេ កសិករកម្ពុជាពឹងផ្អែកលើបណ្ដុំឧបករណ៍ខុសៗគ្នា ដែលបណ្ដុំយន្ដការបញ្ចប់ភាពទីទាល់ក្រអាចផ្ដល់ឲ្យបាន ដូចជា៖ ប្រព័ន្ធស្រោចស្រព និងគ្រប់គ្រងទឹក ឧបករណ៍សាបព្រោះគ្រាប់ពូជ ឧបករណ៍ភ្ជួររាស់គោយន្ដ។ ការផ្ដល់ទ្រព្យផលិតដោយផ្ទាល់ដល់កសិករ ដោយឲ្យពួកគេជ្រើសរើសទ្រព្យដែលពួកគេនឹងទទួលបាន អាចជួយដោះស្រាយឧបសគ្គនេះ និងធ្វើឲ្យមានភាពបត់បែនក្នុងកម្រិតសេដ្ឋកិច្ចខ្នាតតូច។

កង្វះខាតទីផ្សារ និងឧបសគ្គសនៃសកម្មភាពផលិតភាពធ្វើឲ្យរាំងស្ទះដល់ការដាក់បញ្ចូលជនក្រីក្រទៅក្នុងការអភិវឌ្ឍនិងចរន្ដសេដ្ឋកិច្ច។ ទោះបីការឧបត្ថម្ភសាច់ប្រាក់ ត្រូវបានគេអះអាងថា មានប្រសិទ្ធភាពដល់ការប្រើប្រាស់របស់ប្រជាជនក្រីក្រ ប៉ុន្ដែផលប៉ះពាល់របស់វាក្នុងការធ្វើឲ្យមានសកម្មភាពនិងទ្រព្យផលិតភាព ត្រូវបានចាត់ទុកក្នុងកម្រិតមធ្យម។ អ្នកទទួលផលកាន់តែក្រីក្រ វាកាន់តែលំបាកក្នុងការផ្ដល់ឲ្យដើម្បីឲ្យមានការវិនិយោគប្រកបដោយផលិតភាព។ ប្រសិនបើសេដ្ឋកិច្ចមូលដ្ឋាន មានឧបសគ្គក្នុងការដាក់បញ្ចូលភាពទីទាល់ក្រទៅក្នុងចរន្ដសេដ្ឋកិច្ច ឬ រាំងមិនឲ្យកើតមានឱកាសវិនិយោគ នោះកម្មវិធីសំណាញ់សុវត្ថិភាពតែម្យ៉ាង មិនអាចបញ្ចប់ភាពទីទាល់ក្របានទេ។ ដើម្បីឲ្យអ្នកទទួលផលឈប់ពឹងផ្អែកលើកម្មវិធីគាំពារសង្គម សមាហរណកម្មសេដ្ឋកិច្ចសម្រាប់ប្រជាជនទីទាល់ក្រពិតជាសំខាន់ ដើម្បីកាត់បន្ថយភាពទីទាល់ក្របានយូរអង្វែងនិងមានប្រសិទ្ធភាព។

ក្នុងបរិបទនេះ បណ្ដុំយន្ដការបញ្ចប់ភាពទីទាល់ក្រ ទំនងផ្ដល់អត្ថប្រយោជន៍សេដ្ឋកិច្ចជាច្រើន ដល់ជនដែលស្ថិតក្នុងវ័យធ្វើការ និងគ្រួសារដែលមានកាយសម្បទាគ្រប់គ្រាន់ ដែលអាចចូលរួមក្នុងសកម្មភាពមានផលិតភាពបាន។ ដើម្បីឲ្យមានការគាំពារសង្គមដល់អ្នកដែលមិនស្ថិតនៅក្នុងវ័យធ្វើការ ឬមានកាយសម្បទាមិនគ្រប់គ្រាន់ គេគួរដាក់គោលដៅយុទ្ធសាស្ត្រគាំពារសង្គម ដោយមិនទុកអ្នកណាម្នាក់ចោលនោះទេ។ ដូច្នេះវិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រ គួរតែត្រូវបានពិចារណាជាជម្រើសគោលនយោបាយមួយនៅក្នុងគ្រប់កម្មវិធី ដើម្បីដោះស្រាយតម្រូវការចិញ្ចឹមជីវិតរបស់ជនងាយរងគ្រោះបំផុត។ វិធីសាស្ត្រនេះ មានដាក់បញ្ចូលក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPF) ដែលទើបនឹងត្រូវបានអនុម័តថ្មីៗ។

អន្ដរាគមន៍ដែលរួមបញ្ចូលរវាងសំណាញ់សុវត្ថិភាពជាមួយការផ្ដល់ទ្រព្យផលិត និងការអភិវឌ្ឍជំនាញ មានសក្ដានុពលដើម្បីដោះស្រាយឧបសគ្គទាំងនេះ។ ដោយសេដ្ឋកិច្ចក្នុងមូលដ្ឋាន ជះឥទ្ធិពលដល់សមត្ថភាពរកចំណូលតាមគ្រួសារ ការរៀបចំអន្ដរាគមន៍ល្អអាចដោះស្រាយ ទាំងតម្រូវការប្រើប្រាស់ តម្រូវការសម្ភារៈ ព្រមទាំងធនធានមនុស្ស និងធ្វើឲ្យជីវភាពរស់នៅរបស់អ្នកទទួលផលប្រសើរឡើងក្នុងរយៈពេលវែង។

បណ្ដុំយន្ដការបញ្ចប់ភាពទីទាល់ក្រ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលបំណង៖ ការឧបត្ថម្ភបានគ្រប់ជ្រុងជ្រោយ អាចបំពេញតម្រូវការរហ័សសម្រាប់ជនទីទាល់ក្រ និងបង្កើនការរកចំណូលរបស់ពួកគេ។ សំណាញ់សុវត្ថិភាពគឺជាសមាសភាគសំខាន់មួយនៃគំរូបញ្ចប់ភាពទីទាល់ក្រ ហើយសំណាញ់សុវត្ថិភាពនេះ មានបំណងធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចសម្រាប់ជនក្រីក្រ មានភាពប្រសើរឡើង តាមរយៈឱកាសសេដ្ឋកិច្ច ការផ្ដល់ទ្រព្យផលិត ជំនាញ និងសមាហរណកម្ម ដែលកាន់តែប្រសើរដោយស្របទៅនឹងចរន្ដសេដ្ឋកិច្ចក្នុងមូលដ្ឋាន។

## វិធីសាស្ត្របណ្ដុំយន្ដការភាពទីទាល់ក្រ

គំរូបញ្ចប់ភាពទីទាល់ក្រ គឺជាកម្មវិធីចម្រុះ ដែលមានបំណងធ្វើឲ្យជនទីទាល់កក្រចាកចេញពីភាពទីទាល់ក្រ។ គំរូនេះ មាននៅក្នុងវិធានការបំពេញបន្ថែម ដោយវិធានការនីមួយៗមានបញ្ជាក់ពីទំហំខ្នាត ឬ មូលហេតុដ៏ជាក់លាក់នៃភាពទីទាល់ក្រនៅកម្រិតគ្រួសារ។ ‘ធាតុផ្សំសំខាន់ៗ’ ទាំងប្រាំរបស់គំរូនេះមាន៖ ការកំណត់ជនទីទាល់ក្រខ្លាំងជាគោលដៅ ការជួយគាំទ្រដល់ការប្រើប្រាស់របស់ពួកគេ ការផ្ដល់ទ្រព្យផលិត ការផ្ដល់ជំនាញ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការជួយគាំទ្រដល់ការសន្សំរបស់ពួកគេ តាមរយៈការបណ្ដុះបណ្ដាលផ្នែកហិរញ្ញវត្ថុ និងសេវា (CGAP ឆ្នាំ២០១១)។

វិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រនេះ គឺពឹងផ្អែកលើការផ្ដល់ដោយផ្ទាល់ ដើម្បីដោះស្រាយការមិនដាក់បញ្ចូលនៃជនទីទាល់ក្រទៅក្នុងបរិស្ថានសេដ្ឋកិច្ចសង្គមរបស់ពួកគេ ដែលការមិនដាក់បញ្ចូលនេះមានជាច្រើនទម្រង់។ ដើម្បីជួយដល់ការប្រើប្រាស់ និងតម្រូវការចិញ្ចឹមជីវិតរបស់ពួកគេ បណ្ដុំយន្ដការ

បញ្ចប់ភាពទីទាល់ក្រ មានផ្តល់កម្មវិធីដល់អ្នកចូលរួមនូវសំណាញ់សុវត្ថិភាព ក្នុងទម្រង់ជាការផ្តល់សាច់ប្រាក់ប្រចាំខែ ឬ ជាសម្ភារៈ។ ដើម្បីលើកកម្ពស់ជំនាញវិជ្ជាជីវៈរបស់ពួកគេ បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ មានផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការណែនាំទៀងទាត់។ ដើម្បីដោះស្រាយការមិនដាក់បញ្ចូលជនទីទាល់ក្រទៅក្នុងទ្រព្យផលិត និងក្នុងសេវាហិរញ្ញវត្ថុ បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ នឹងផ្តល់ទ្រព្យផលិត ដែលអាចឲ្យពួកគេអភិវឌ្ឍ ឬ បង្កើតចំណូល និងពង្រឹងសកម្មភាពមានផលិតភាពរបស់ពួកគេ។ គោលបំណងនៃវិធីសាស្ត្រទាំងអស់នេះ គឺដើម្បីឲ្យអ្នកចូលរួមអាចចាកចេញពីអន្ទាក់នៃភាពទីទាល់ក្រ និងធានាបានយូរអង្វែងនូវជីវភាពរស់នៅរបស់ពួកគេ។

ទោះបីជាបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រនេះ ត្រូវចំណាយខ្ពស់ជាងសំណាញ់សុវត្ថិភាពជាសាច់ប្រាក់តែម៉្យាងក្តី វានឹងធ្វើឲ្យគ្រួសារទីទាល់ក្រអាចបង្កើតចំណូល តាមរយៈការមានមុខរបរផ្ទាល់ខ្លួន និងជាលទ្ធផលពួកគេនឹងមិនត្រូវការកិច្ចគាំពារសង្គមទៀតនោះទេ។

វិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រ ត្រូវបានបំផុសគំនិតដោយកម្មវិធីដែលរៀបចំឡើងដោយ BRAC នៅប្រទេសបង់ក្លាដេស។ BRAC គឺជាអង្គការអភិវឌ្ឍន៍ក្រៅរដ្ឋាភិបាលធំជាងគេនៅលើពិភពលោក មានមូលដ្ឋាននៅក្នុងប្រទេសបង់ក្លាដេស និងប្រតិបត្តិការនៅ ១១ប្រទេស ក្នុងទ្វីបអាស៊ី-អាហ្វ្រិក និងតំបន់ការាបៀន។ យុទ្ធសាស្ត្រ ផ្តល់សិទ្ធអំណាចតាមរយៈការផ្តល់ទ្រព្យផលិត និងជំនាញដល់ពួកគេ បង្កើតបានជាកម្មវិធី និងប្រមើជាប្រយោជន៍ដល់ជនទីទាល់ក្រច្រើនជាង ១០០លាននាក់ ក្នុងបណ្តាប្រទេសទាំងនោះ។ គិតត្រឹមពេលនេះ វិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រ ត្រូវបានអង្គការនានាអនុវត្តតាមបានជាង ១០ឆ្នាំរួចទៅហើយ តាមរយៈកម្មវិធីជាង៤០ នៅជុំវិញពិភពលោក។ ក្នុងករណីភាគច្រើន អង្គការមិនមែនរដ្ឋាភិបាល ដូចជា Trickle Up, Village Enterprise ឬ គម្រោង Boma Project សហការជាមួយមូលនិធិ អ្នកផ្តល់សេវាហិរញ្ញវត្ថុ និងរដ្ឋាភិបាលក្នុងស្រុក ដើម្បីអនុវត្ត និងផ្តល់ហិរញ្ញប្បទានដល់គម្រោងរបស់ពួកគេ។ ចំណាប់អារម្មណ៍លើវិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រនេះ គឺកើតឡើងតាមរយៈរដ្ឋាភិបាលដែលស្វែងរកការរួមបញ្ចូលនូវវិធីបញ្ចប់ភាពទីទាល់ក្រ ទៅក្នុងកម្មវិធីគាំពារសង្គមដែលមានស្រាប់របស់ពួកគេ។ បច្ចុប្បន្នប្រទេសដែលមានកំណើនប្រជាជនទីទាល់ក្រកាន់តែច្រើន ដូចជា៖ ប្រទេសកេនយ៉ា ប្រទេសប៉េរូ ប្រទេសហៃទី និងប្រទេសកូឡុំប៊ី កំពុងពិចារណាលើ វិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រនេះ។ ស្រដៀងគ្នានេះដែរ អង្គភាពស្រាវជ្រាវនិងរៀបចំគោលនយោបាយ (Innovations for Poverty Action) គឺត្រូវបានដាក់បញ្ចូលឲ្យពាក់ព័ន្ធ ក្នុងការរៀបចំកម្មវិធីបន្សាំកិច្ចគាំពារសង្គម ក្នុងប្រទេសប៊ូគីណាហ្វាសូ ប្រទេសឆាដ ប្រទេសម៉ាលី ប្រទេសម៉ូរីតានៀ ប្រទេសនីហ្សេរ និងប្រទេសសេណេហ្គាល់។ បើទោះជា ថ្លៃចំណាយនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ខ្ពស់ជាងកម្មវិធីគាំពារសង្គមធម្មតាក្តី ទិដ្ឋភាពនៃការចាកចេញពីភាពទីទាល់ក្រ (ដែលមិនចាំបាច់មានតម្រូវការសំណាញ់សុវត្ថិភាពនៅរយៈពេលវែង) និងការចូលរួមចំណែកក្នុងសេដ្ឋកិច្ចមូលដ្ឋាន គឺជាអត្ថប្រយោជន៍ដែលមិនអាចប្រកែកបាន មិនថាទាំងទំហំថវិកាមានកម្រិត ឬ ភាពទីទាល់ក្រមានទំហំធំយ៉ាងណាក៏ដោយ។

អំអាងលើការស្រាវជ្រាវជាក់ស្តែងអំពីផលប៉ះពាល់សេដ្ឋកិច្ចនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ បានបង្ហាញថា វាបានចាប់ផ្តើមផ្តល់នូវអំណះអំណាងនៃប្រសិទ្ធភាពរបស់វា។ បើយោងតាមការសិក្សា និងការចែករំលែកសំខាន់ៗ ក្នុងការជជែកដេញដោលបច្ចុប្បន្ននេះ របស់ Banerjee et al. (២០១៥) ដែលបានតាមដានអំពី ប្រសិទ្ធភាពនៃវិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រ តាមរយៈការពិសោធន៍នៅក្នុង៦ប្រទេស។ ពួកគេបានធ្វើការកំណត់ បណ្តុំនៃផលប៉ះពាល់ច្រើន និងយូរអង្វែងដែលកើតមានឡើងតាមបណ្តាកម្មវិធីសិក្សាទាំងនោះ។ ដើម្បីធ្វើដូច្នេះបាន ពួកគេបានប៉ាន់ស្មានពីបម្រែបម្រួលសូចនាករសុខុមាលភាពសំខាន់ៗនៅក្នុងរយៈពេលពីរផ្សេងគ្នា៖ មួយ គឺនៅពេលភ្លាមៗបន្ទាប់ពីកម្មវិធីបានបញ្ចប់ និងមួយទៀត គឺមួយឆ្នាំបន្ទាប់។ វាមានភាពប្រសើរឡើងគួរឲ្យកត់សម្គាល់ទៅលើការប្រើប្រាស់សម្រាប់មនុស្សម្នាក់ សន្តិសុខស្បៀងអាហារ និងតម្លៃទ្រព្យសម្បត្តិគ្រួសារ ក្នុងគ្រប់ប្រទេសដែលបានពិសោធន៍ទាំងអស់ នៅចុងបញ្ចប់នៃរយៈពេលអនុវត្តកម្មវិធី ហើយជាលទ្ធផលនៅចុងឆ្នាំ បន្ទាប់មកក៏បង្ហាញពីភាពប្រសើរឡើង

ផងដែរក្នុងករណីសិក្សាភាគច្រើន។ ទោះបីជាសូចនាករសុខុមាលភាពមិនមែនសេដ្ឋកិច្ចមួយចំនួន ដូចជា៖ សុខភាពផ្លូវចិត្តមិនមានដំណើរការបន្តក្រោយកម្មវិធីបញ្ចប់យ៉ាងណាក្តី ការស្រាវជ្រាវបានសន្និដ្ឋានថា វិធីសាស្ត្របញ្ចប់ពីភាពទីទាល់ក្រមានប្រសិទ្ធភាពបន្តរហូតក្នុងគ្រប់បរិបទ ហើយក៏បានសន្និដ្ឋានដែរថា ផលប៉ះពាល់ពីការផ្តល់សិទ្ធអំណាចដល់អ្នកចូលរួមអាចនៅបន្តរហូតដល់៧ឆ្នាំ ក្រោយគម្រោងបានបញ្ចប់។ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា ការស្រាវជ្រាវត្រូវធ្វើបន្តទៀត ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ អំពីសមាសភាគនៃបណ្តុំយន្តការដែលបង្កើតបានលទ្ធផល។ ពួកគេ ក៏ត្រូវការការតាមដានផលប៉ះពាល់លើអ្នកដែលមិនបានចូលរួមក្នុងសហគមន៍ផងដែរ។ ការសិក្សានេះ ផ្តោតលើទំហំព្រមទាំងវិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រ។

នៅក្នុងរូបភាពនៃបរិបទដែលបានពិភាក្សា នៅផ្នែកមុន បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រដែលពាក់ព័ន្ធ គឺមានលក្ខណៈខ្លាំងក្លានៅកម្ពុជា។ វិស័យកសិកម្ម បាននិងកំពុងជាចលករយ៉ាងសំខាន់មួយ ក្នុងការកាត់បន្ថយភាពទីទាល់ក្រ ក្នុងទសវត្សរ៍ចុងក្រោយ។ វិស័យនេះផ្តល់ឲ្យជនក្រីក្រនៅតាមទីជនបទនូវកម្មវិធីចម្រុះ ដែលដោះស្រាយដោយផ្ទាល់លើការទទួលបាននូវទ្រព្យផលិត ជំនាញ និងបរិយាប័ន្នក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេ។ តើផលប៉ះពាល់សេដ្ឋកិច្ចនិងសង្គមអ្វីខ្លះ ដែលអាចកើតឡើងពីអន្តរាគមន៍ទាំងនេះ? តើវិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រផ្តល់អត្ថប្រយោជន៍អ្វីខ្លះ? បើធៀបទៅនឹងកម្មវិធីគាំពារដោយការឧបត្ថម្ភសាច់ប្រាក់ ? តើវាបំពេញបន្ថែមលើរឿងអ្វីខ្លះដល់គោលនយោបាយអភិវឌ្ឍន៍ជនបទ? តើមានការថ្លឹងថ្លែងអ្វីខ្លះ ដែលអ្នករៀបចំ និងអ្នកអនុវត្តគោលនយោបាយគួរពិចារណា នៅពេលរៀបចំកម្មវិធីគាំពារសង្គមដែលមានជម្រើសសមាសភាគអំណោយច្រើន? ក្នុងបរិបទប្រទេសកម្ពុជា ដើម្បីបង្ហាញអំណះអំណាង និងឆ្លើយសំណួរទាំងនេះ យើងរៀបចំវិធីសាស្ត្រមួយ ដែលយោងតាមបរិបទសេដ្ឋកិច្ចសង្គម និងតាមលទ្ធផលពីការស្រាវជ្រាវដែលមានស្រាប់អំពីប្រធានបទទាំងនេះ។

វិធីសាស្ត្ររបស់យើង គឺពឹងផ្អែកទៅលើការធ្វើគំរូសមតាទូទៅ ផ្ទុយទៅនឹងការសិក្សាដែលមានស្រាប់ដែលភាគច្រើនពឹងផ្អែកតាមរយៈការសាកល្បងដោយចៃដន្យ (RCTs)។ ជម្រើសមធ្យោបាយវិភាគនេះមានចំណុចដោះដូរមួយចំនួន៖

- គំរូរបស់យើងគ្របដណ្តប់លើធាតុផ្សំសំខាន់ៗចំនួន៤ ក្នុងចំណោមធាតុផ្សំសំខាន់ៗ ទាំង៥ រួមមាន៖ ការកំណត់ជនក្រីក្រខ្លាំងជាគោលដៅ ការជួយគាំទ្រការប្រើប្រាស់ ការផ្តល់ទ្រព្យ និងការផ្តល់ជំនាញ។ ក្របខ័ណ្ឌរបស់យើង គឺមិនរាប់បញ្ចូល ការផ្តល់មធ្យោបាយសន្សំសម្រាប់គ្រួសារគោលដៅនោះទេ ដោយសារតែផលប៉ះពាល់សេដ្ឋកិច្ចយូរអង្វែងរបស់ពួកគេ មិនអាចប្រើប្រាស់វិធីសាស្ត្រនេះទៅវាស់វែងបានឡើយ។ ដោយសារក្នុងរយៈពេលខ្លីការផ្តល់មធ្យោបាយសន្សំ មិនមានផលប៉ះពាល់ខ្លាំងលើភាពទីទាល់ក្រ និងបរិយាប័ន្នសេដ្ឋកិច្ច ផលប៉ះពាល់បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ នៅតែអាចត្រូវបានដោះស្រាយ និងតាមដានបាន។
- ផ្ទុយពីការវាយតម្លៃគម្រោងតាមរយៈការសាកល្បងដោយចៃដន្យ (RCTs) យើងតាមដាន និងវាស់ស្ទង់ផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលទៅលើសេដ្ឋកិច្ចមូលដ្ឋានលើអ្នកមិនទទួលផល និងលើកំណើនសេដ្ឋកិច្ចតាមរយៈការធ្វើអន្តរកម្មទីផ្សារ។ ដូច្នេះ វិធីសាស្ត្ររបស់យើងអនុវត្តទាំងលើមីក្រូ និងម៉ាក្រូសេដ្ឋកិច្ច។ បរិយាប័ន្ន និងការចូលរួមរបស់អ្នកទទួលផល នឹងត្រូវបានដោះស្រាយ តាមរយៈការចូលរួម និងសកម្មភាពផលិតភាពរបស់អ្នកចូលរួមក្នុងទីផ្សារតាមមូលដ្ឋាន។

យុទ្ធសាស្ត្រវិភាគរបស់យើងផ្តល់ជម្រើសបន្ថែម លើសពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រទូទៅ ព្រោះវាបើកចំហឲ្យអ្នកចូលរួម អាចជ្រើសរើសទ្រព្យផលិតដោយខ្លួនឯងបាន។ នៅក្នុងបរិបទកម្ពុជា គឺពុំមានការរារាំងដល់ការផ្តល់ធនធានជាសត្វចិញ្ចឹមឡើយ។ ផលិតកម្មដំណាំនេះ គឺជាកត្តាជម្រុញដ៏សំខាន់ដល់សមិទ្ធិផលនៅក្នុងការអភិវឌ្ឍជនបទនាពេលថ្មីៗនេះ និងគាំទ្រដល់ការបង្កើនដើមទុន ផលិតភាពដីនិងពលកម្ម និងការសម្របតាមបច្ចេកវិទ្យាដែលជាអាទិភាព ដើម្បីទ្រទ្រង់វឌ្ឍនភាពនេះ។ ប្រសិនបើកម្មវិធីចម្រុះមួយ ត្រូវបានបង្កើនឡើងសម្រាប់ប្រជាជនកម្ពុជារាប់សែននាក់ (បើមិនលើសពីនេះ) នៅតាមទីជនបទនៃប្រទេសកម្ពុជា នោះការផ្តល់ទ្រព្យ

ផលិត និងដី នឹងមានភាពខុសគ្នាទៅតាមអ្នកទទួលផល[៤]។ វាជាការសមហេតុផលក្នុងការផ្តល់សត្វមាន់ ឬ សត្វពពែទៅដល់គ្រួសារដែលគ្មានដី និងផ្តល់ជម្រើសច្រើនដល់អ្នកដែលមានដី និងរបរចិញ្ចឹមជីវិតស្រាប់។ ការអនុវត្តតាមនៃការសិក្សានេះ អនុញ្ញាតឲ្យអ្នកចូលរួមធ្វើការជ្រើសរើសឧបករណ៍កសិកម្ម។ ដោយសារតែផលិតកម្មកសិផល និងសត្វចិញ្ចឹម ត្រូវបានដាក់បញ្ចូលក្នុងទិន្នន័យបច្ចេកវិទ្យាផលិតកម្មរបស់ OECD (ឧទាហរណ៍នៅក្នុងតារាងធាតុចូល-លទ្ធផល) ផលិតកម្មកសិផល និងសត្វចិញ្ចឹមនេះ ក៏ត្រូវបានដាក់បញ្ចូលនៅក្នុងគំរូគណនាសមតាទូទៅរបស់យើងផងដែរ។ ដោយហេតុផលដូចនេះ ការជ្រើសរើសទ្រព្យផលិតដោយអ្នកទទួលផល នឹងមិនប៉ះពាល់ដល់លទ្ធផលវិភាគទេ ដែលករណីការជ្រើសរើសទាំងពីរនេះ នឹងបង្កើនដើមទុនផលិតកសិទំនិញដូចគ្នា។

ការសិក្សានេះ ផ្តល់នូវការបរិយាយយ៉ាងលម្អិតអំពីអត្ថប្រយោជន៍ប្រកបដោយសក្តានុពល និងការថ្លឹងថ្លែង ដែលអាចត្រូវបានរំពឹងទុកពីការផ្តល់ធនធាននានា ទៅកាន់ប្រជាជនក្រីក្របំផុតនៅកម្ពុជា។ វាអាចចាត់ទុកជាមូលដ្ឋានក្នុងការផ្តល់អនុសាសន៍គោលនយោបាយ ដែលអាចអនុវត្ត និងបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍របស់ខ្លួន។ ថ្វីបើបណ្តុំយន្តការនៅក្នុងការសិក្សានេះ ទាមទារឲ្យមានសមត្ថភាពនៅតាមស្ថាប័នក៏ដោយ ក៏បណ្តុំយន្តការទាំងនេះ មានលក្ខណៈសាមញ្ញជាងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រទូទៅ ហើយមូលនិធិដែលប្រើសម្រាប់បណ្តុំយន្តការទាំងនេះ គឺស្ថិតនៅក្រោមថវិកាកម្មវិធីគាំពារសង្គម។

ផ្នែកខាងក្រោមបង្ហាញពីវិធីសាស្ត្រ និងមធ្យោបាយវិភាគដែលត្រូវបានប្រើដើម្បីកំណត់ និងប៉ាន់ស្មានផលប៉ះពាល់ទាំងនេះ។



[៤] នៅក្នុងគំរូរបស់សិក្សានេះ ក្រុមគ្រួសារគឺមិនមែនអាស្រ័យលើសកម្មភាពផលិតភាពនោះទេ ប៉ុន្តែវាអាស្រ័យលើទីតាំងភូមិសាស្ត្រ និងគម្លាតទៅនឹងបន្ទាត់នៃភាពទីទាល់ក្រ។ ដោយហេតុផលនេះ ការផ្តល់ដីគឺមានភាពខុសៗគ្នាទៅតាមគ្រួសារគោលដៅ។ ការផ្តល់ជម្រើសទ្រព្យ អាចធ្វើឱ្យគ្រួសារគោលដៅដែលមិនមានដី ធ្វើការជ្រើសរើសបាននូវធនធានផលិតភាពណាដែលឆ្លើយតបទៅកត្តាផ្តល់ឱ្យ និងសមត្ថភាពផលិតរបស់វា។

# ផ្នែកទី ២ ការរៀបចំគំរូបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ សម្រាប់គ្រួសារទីទាល់ក្រខ្លាំងក្នុងប្រទេសកម្ពុជា

ដើម្បីដឹងពីផលប៉ះពាល់នៃវិធានបញ្ចប់ភាពទីទាល់ក្រ មកលើផ្នែកសេដ្ឋកិច្ច យើងរៀបចំគំរូគណនាសមតាទូទៅមួយ (CGE) ដែលបង្ហាញពីសេដ្ឋកិច្ចប្រទេសកម្ពុជា និងបណ្តុំនៃសេណារីយ៉ូមួយតំណាងឲ្យអន្តរាគមន៍ ដែល យូអិនឌីភី ដាក់ចេញដើម្បីគាំទ្រដល់គ្រួសារគោលដៅ។ វិធីសាស្ត្រនេះមានគោលបំណងតាមដានលទ្ធផលនៃអន្តរាគមន៍ នៅក្នុងមូលដ្ឋាន វិភាគពីការជះឥទ្ធិពលរហ័ស និងបន្ទាប់បន្សំទៅលើទីផ្សារ និងពាណិជ្ជកម្ម និងការស្វែងយល់ពីផលប៉ះពាល់ទាំងនោះលើចំណែកប្រាក់ចំណូល និងចំណាយ ក្នុងលក្ខខណ្ឌនៃការកាត់បន្ថយភាពទីទាល់ក្រ។

## គំរូគណនាសមតាទូទៅ

គំរូគណនាសមតាទូទៅ (CGE) គឺជាគំរូសេដ្ឋកិច្ចដែលប្រើទិន្នន័យអំណះអំណាងរួមជាមួយទម្រង់ទ្រឹស្តីនៃសមតាទូទៅ ដើម្បីដឹងពីរបៀប ដែលសេដ្ឋកិច្ចមានប្រតិកម្មលើការផ្លាស់ប្តូរគោលនយោបាយ បច្ចេកវិទ្យា ឬ កត្តាខាងក្រៅផ្សេងទៀត។ គំរូគណនាសមតាទូទៅ គឺជាមធ្យោបាយនៃការអនុវត្តតាមមួយ ដែលគណនាជាតួរលេខនូវកម្រិតនៃការផ្គត់ផ្គង់ តម្រូវការ និងតម្លៃលើទីផ្សារក្នុងស្រុក ដែលកើតចេញពីការផ្លាស់ប្តូរគោលនយោបាយ ឬ ពីកត្តាវិបត្តហិរញ្ញវត្ថុ និងសេដ្ឋកិច្ចខាងក្រៅ។ គំរូគណនាសមតាទូទៅ គឺជាមធ្យោបាយស្តង់ដារ សម្រាប់ធ្វើការវិភាគរកអំណះអំណាងតាមរយៈការប៉ាន់ស្មាន។ គំរូទាំងនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីវិភាគសុខុមាលភាព និងផលប៉ះពាល់កើតឡើងពីគោលនយោបាយដែលមានតាមរយៈទីផ្សារ និងភ្នាក់ងារសេដ្ឋកិច្ច។ លំដាប់វិធានការដែលអាចត្រូវអនុវត្តតាម គឺមានភាពធំធេង និងមានបញ្ចូលនូវបម្រែបម្រួលពន្ធ ការឧបត្ថម្ភធន គោលនយោបាយពាណិជ្ជកម្ម និងវិធានការបែងចែកឡើងវិញ ដោយរាប់បញ្ចូលទាំងការឧបត្ថម្ភដល់គ្រួសារ និងគោលនយោបាយសង្គម។ ឧទាហរណ៍នៃការ



ប្រើប្រាស់គំរូនេះ អាចរកបាននៅក្នុងផ្នែកជាច្រើនផ្សេងៗគ្នា ដូចជា៖ ការរៀបចំផែនការកំណែទម្រង់ និងអភិវឌ្ឍន៍សារពើពន្ធ ពាណិជ្ជកម្មអន្តរជាតិ និងបទប្បញ្ញត្តិបរិស្ថាន។

ក្របខ័ណ្ឌគំរូគណនាសមតាទូទៅរួមមាន៖

១. ម៉ាទ្រីសគណនេយ្យសង្គម (SAM) ដែលជាសំណុំទិន្នន័យបង្ហាញពីលំហូរហិរញ្ញវត្ថុ និងការផ្ទេរសេដ្ឋកិច្ចរវាងភ្នាក់ងារទាំងអស់ក្នុងអំឡុងពេលជាក់លាក់ណាមួយ ដែលជាធម្មតាគឺមួយឆ្នាំ។ ទីផ្សារក្នុងស្រុកសម្រាប់ទំនិញ សេវា និងកត្តា ត្រូវបានតំណាង ក៏ដូចជាគ្រួសារ គ្រឹះស្ថានឯកជន ស្ថាប័នរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលដំណើរការក្នុងប្រទេស ក្នុងអំឡុងពេលដែលបានកំណត់តាមរយៈសកម្មភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ពួកគេ។ ម៉ាទ្រីសនេះ បង្ហាញពីទិដ្ឋភាពនៃសេដ្ឋកិច្ចទាំងមូលរបស់ប្រទេសមួយ (ឬរបស់ពិភពលោកទាំងមូល) ក្នុងពេល

រយៈវេលាមួយ។ វាបែងចែកចេញជាចំនួនវិស័យ ទំនិញ កត្តាផលិតកម្ម និងប្រភេទគ្រួសារ ព្រមទាំងមានតារាងជាតុចូល-ជាតុចេញ ដែលឆ្លុះបញ្ចាំងពីការប្រើប្រាស់ជាតុចូល និងកត្តាផលិតកម្មតាមវិស័យនីមួយៗ ដូច្នេះហើយវាឆ្លុះបញ្ចាំងឲ្យឃើញពីបច្ចេកវិទ្យាដែលត្រូវបានប្រើប្រាស់។ ការគ្រប់ដណ្តប់តាមវិស័យ ចាប់ផ្តើមពីការពន្យល់បែបសាមញ្ញបន្តិច អំពីដើមទុន ពលកម្ម និងអន្តរការី រហូតដល់ការពន្យល់លម្អិតទៅតាមអនុវិស័យជាក់លាក់។

២. គំរូពិជគណិតមួយ ដែលជាបណ្តុំសមីការ ឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងភ្នាក់ងារសេដ្ឋកិច្ចផ្សេងគ្នា ដែលកំណត់ដោយផ្អែកលើលំហូរ ដែលមានក្នុងម៉ាទ្រីសគណនេយ្យសង្គម។ ឧទាហរណ៍សមីការទាំងនេះ អាចតំណាងឲ្យស្ថានភាពគ្រួសារតាមរយៈកម្រិតចំណាយរបស់ពួកគេ ឬ ការពង្រីកជាអតិបរមានូវប្រាក់ចំណេញរបស់ក្រុមហ៊ុនក្នុងវិស័យនីមួយៗ ទៅតាមបច្ចេកវិទ្យា និងការផ្គត់ផ្គង់កត្តាផលិតកម្មនាអំឡុងពេលសកម្មភាព។

**រូបភាពទី១៖** ប្លុកសេដ្ឋកិច្ច និងលំហូរហិរញ្ញវត្ថុ នៅក្នុងគំរូគណនាសមតាទូទៅមួយ ( Lofgren et al. ឆ្នាំ២០០១ )




*ការរួមបញ្ចូលគ្នារវាងម៉ាទ្រីសគណនេយ្យសង្គម និងគំរូពិជគណិត ធ្វើឲ្យការអនុវត្តតាមនៃអន្តរាគមន៍សាធារណៈ ឬ គោលនយោបាយ អាចកំណត់ និងតាមដានផលប៉ះពាល់ជាច្រើនរបស់វានៅក្នុងសេដ្ឋកិច្ច។*

## ទិន្នន័យដែលត្រូវបានប្រើប្រាស់ក្នុងការសិក្សានេះ

ម៉ាទ្រីសគណនេយ្យសង្គមដែលត្រូវបានប្រើប្រាស់នេះ គឺផ្អែកទៅលើប្រភពទិន្នន័យពីរសំខាន់គឺ៖ (១)ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចដែលចេញផ្សាយដោយរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិជាដៃគូរបស់ខ្លួន ដូចជា៖ មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និង អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច និង(២)ទិន្នន័យគ្រួសារដែលបានមកពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាថ្នាក់ជាតិនៅឆ្នាំ២០១១។

នៅឆ្នាំ២០១៦ អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច បានចេញផ្សាយតារាងជាតុចូល-ជាតុចេញដំបូង

បង្អស់សម្រាប់ប្រទេសកម្ពុជា (OECD ឆ្នាំ២០១៦)។ គិតរហូតមកដល់ការបោះពុម្ពផ្សាយនេះ មិនមានការប៉ាន់ស្មានណាមួយអំពីការប្រើប្រាស់អន្តរការីនៃទំនិញ និងសេវា ដែលប្រើប្រាស់ដោយវិស័យផលិតកម្មនៅប្រទេសកម្ពុជា ក្នុងកម្រិតវិស័យពីរខ្ទង់ទេ។ តារាងនេះ ផ្តល់នូវការវាយតម្លៃលម្អិតអំពីអ្វីដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតកម្មតាមវិស័យនីមួយៗ។ វាផ្តល់នូវមេគុណបច្ចេកទេសសម្រាប់ការប្រើប្រាស់អន្តរការី និងកត្តាផលិតកម្មសម្រាប់សកម្មភាពផលិតភាពនីមួយៗ នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០១១[៥]។ ដូច្នេះ គំរូរបស់យើងគឺជាគំរូគណនាសមតាទូទៅដំបូងគេ ដែលផ្អែកលើទិន្នន័យដែលផលិតដោយ ឬ ប៉ាន់ស្មានសម្រាប់ប្រទេសកម្ពុជា។

ការសិក្សានេះ បានប្រើប្រាស់ទិន្នន័យរបស់អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជា ដើម្បីជាសមាសភាគផលិតកម្ម និងពាណិជ្ជកម្មនៅក្នុងម៉ាទ្រីសគណនេយ្យសង្គមរបស់យើង រួមជាមួយនឹងទិន្នន័យដែលបានចេញផ្សាយដោយរដ្ឋាភិបាលកម្ពុជា។ យើងក៏បានប្រើប្រាស់ផងដែរនូវការប៉ាន់ស្មានម៉ាក្រូសេដ្ឋកិច្ចរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF ឆ្នាំ២០១៦) និងធនាគារពិភពលោក (ធនាគារពិភពលោក ឆ្នាំ២០១៦) លើវិនិយោគសាធារណៈ វិនិយោគផ្ទាល់ពីបរទេស ការផ្ញើរប្រាក់ចេញ និងការផ្ទេរពីក្រៅប្រទេសក្នុងឆ្នាំ២០១១ ដែលជាឆ្នាំនៃតារាងធាតុចូល-ធាតុចេញ និងម៉ាក្រូសេដ្ឋកិច្ចសរុប។

ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (CSES) ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១១ បានប្រមូលទិន្នន័យពីមនុស្សជាង ១៦,០០០នាក់ នៅក្នុង ៣,៦០០គ្រួសារ។ វាផ្តល់នូវព័ត៌មានលម្អិតអំពីការងារ ចំណូល ការប្រើប្រាស់ និងប្រាក់សន្សំក្នុងគ្រួសារ ព្រមទាំងរបាយការណ៍អំពីទ្រព្យផលិតរបស់ពួកគេ ដូចជា៖ ដី ជាដើម។ អង្កេតនេះត្រូវបានប្រើប្រាស់ ដើម្បីបែងចែកក្រុមគ្រួសារទៅតាមក្របខណ្ឌ និងសំណុំទិន្នន័យរបស់គំរូ។

ដោយយោងទៅលើគោលបំណងនៃការសិក្សានេះ ក្រុមគ្រួសារត្រូវបានគេចាត់ថ្នាក់ដោយប្រើលក្ខណៈវិនិច្ឆ័យ ២ គឺ៖ ទីតាំងភូមិសាស្ត្ររបស់ពួកគេ (ទីប្រជុំជន/ជនបទ) និងការប្រើប្រាស់របស់ពួកគេដែលស្ថិតនៅលើ ឬ ក្រោមបន្ទាត់នៃភាពទីទាល់ក្រ ដែលត្រូវបានប៉ាន់ស្មានកាលពីឆ្នាំ២០១១។

ដើម្បីបង្ហាញពីទំហំគ្រួសារ និងសមាមាត្រប្រជាសាស្ត្រ សមមូលនៃការប្រើប្រាស់របស់មនុស្សពេញវ័យ ត្រូវបានប៉ាន់ស្មានដោយប្រើខ្នាតវិធីសាស្ត្ររបស់ អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច[៦]។ វាធ្វើឲ្យការសិក្សានេះ អាចបង្ហាញបាននូវការពិត ដែលថាកុមារត្រូវការអាហារច្រើនជាងមនុស្សពេញវ័យ និងដែលថាការប្រើប្រាស់របស់គ្រួសារមិនកើនឡើងមានសមាមាត្រទៅនឹងកំណើនចំនួនសមាជិកគ្រួសារ ដូចជា៖ ថ្លៃឈ្នួល ជាដើម។ ការប៉ាន់ស្មានលើសមមូលនៃការប្រើប្រាស់របស់មនុស្សពេញវ័យនេះ អាចឲ្យអ្នកស្រាវជ្រាវកំណត់បានថាគួរចាត់ទុកគ្រួសារមួយស្ថិតនៅក្រោមបន្ទាត់នៃភាពទីទាល់ក្រ ឬយ៉ាងណា (ឧទាហរណ៍៖ ចាត់ទុកថាទីទាល់ក្រខ្លាំង)។

បន្ទាត់នៃភាពទីទាល់ក្រ ត្រូវបានកំណត់ដោយផ្អែកលើម្ហូបអាហារដែលត្រូវការដើម្បីបំពេញតម្រូវការអាហារូបត្ថម្ភ ដូច្នេះ បន្ទាត់នៃភាពទីទាល់ក្រនេះ នឹងអាស្រ័យលើតម្លៃនៅមូលដ្ឋាន។ អាស្រ័យហេតុនេះ យើងប្រើប្រាស់ការប៉ាន់ស្មានបន្ទាត់នៃភាពទីទាល់ក្រនេះ ដែលឆ្លើយតបទៅនឹងទីតាំងភូមិសាស្ត្រនៃគ្រួសារនីមួយៗនៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ដើម្បីកំណត់ពីស្ថានភាពទីទាល់ក្ររបស់ពួកគេ (តារាងទី១)។ បន្ទាត់នៃភាពទីទាល់ក្រទាំងនេះ ត្រូវបានធ្វើបច្ចុប្បន្នភាពដោយការបង្ហាញពីបម្រែបម្រួលនៃតម្លៃរវាងឆ្នាំ២០០៩ (នៅពេលដែលបន្ទាត់ទាំងនេះត្រូវបានប៉ាន់ស្មាន) និងឆ្នាំ២០១១ (ឆ្នាំគោលក្នុងការអង្កេត)។ យោងតាម មូលនិធិរូបិយវត្ថុអន្តរជាតិ (ឆ្នាំ២០១៦) សន្ទស្សន៍តម្លៃទំនិញរបស់កម្ពុជា បានកើនឡើង៩,៦% ក្នុងចន្លោះឆ្នាំ២០០៩ និង ឆ្នាំ២០១១។

---

៥ នេះគឺជាមូលហេតុពន្យល់ពីការដែលគ្មានគំរូគណនាសមតាទូទៅ ត្រូវបានបង្កើតឡើង ដើម្បីប្រទេសកម្ពុជាធ្វើបច្ចុប្បន្នភាពដោយផ្អែកទាំងស្រុងលើការប៉ាន់ស្មានរបស់ប្រទេសកម្ពុជា។

៦ សូមមើល Haughton និង Khandler (ឆ្នាំ២០០៩) សម្រាប់ការវាយតម្លៃវិធីសាស្ត្រនេះ។

**តារាងទី១៖** បន្ទាត់នៃភាពទីទាល់ក្រគិតជាប្រាក់រៀល (KHR) ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១១

| បន្ទាត់ភាពទីទាល់ក្រ | ភ្នំពេញ | ទីប្រជុំជនដទៃទៀត | ជនបទ | ប្រទេសកម្ពុជា |
|---|---|---|---|---|
| បន្ទាត់នៃភាពទីទាល់ក្រនៅឆ្នាំ២០០៩ | ៦,៣៤៧.០ | ៤,៣៥២.០ | ៣,៥០៨.០ | ៣,៨៧១.០ |
| បន្ទាត់នៃភាពទីទាល់ក្រនៅឆ្នាំ២០១១ | ៦,៩៦០.៦ | ៤,៧៧២.៧ | ៣,៨៤១.៦ | ៤,២៤៥.២ |

*ប្រភព៖ ក្រសួងផែនការ ឆ្នាំ២០១៤ និងការគណនារបស់អ្នកស្រាវជ្រាវ*

តារាងទី២ បង្ហាញពីចំនួនប្រជាជននៃក្រុមគ្រួសារនីមួយៗ និងការឆ្លើយតបនៃការប្រើប្រាស់ជាមធ្យមសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំគោល។

**តារាងទី២៖** ចំនួនប្រជាជន និងការប្រើប្រាស់ជាមធ្យមសម្រាប់ក្រុមគ្រួសារមួយ

| | ជនមិនក្រីក្រនៅទីប្រជុំជន | ជនក្រីក្រនៅទីប្រជុំជន | ជនក្រីក្រមិនមែនគោលដៅនៅជនបទ | ជនក្រីក្រគោលដៅនៅជនបទ | ជនមិនក្រីក្រនៅជនបទ |
|---|---|---|---|---|---|
| ចំនួនប្រជាជន | ២,៥៧១,២៥៧ | ៤០៦,៩៦៩ | ១,៣៤៦,៥០១ | ៩៩៩,៩៧៤ | ៩,២៨៥,២៩៩ |
| ចំនួនគ្រួសារ | ៥៦៦,៤៤២ | ៧២,០២១ | ២៥៧,០២៣ | ១៩៣,៩១៦ | ២,១៣៨,០៦៤ |
| ទំហំគ្រួសារជាមធ្យម | ៤.៥ | ៥.៧ | ៥.២ | ៥.២ | ៤.៣ |
| ការប្រើប្រាស់សម្រាប់មនុស្សម្នាក់ (ប្រាក់រៀល) | ៣៦,៥១៨.១ | ៤,២៨៩.៩ | ៣,១៣២.៣ | ៣,០៣៦.៣ | ១៨,៨៥៦.១ |

ជាការប្រើប្រាស់ខ្នាតតំណាងគ្រួសារ យើងបង្កើតគ្រួសារដំបូងចំនួន៤ក្រុម នៅក្នុងម៉ាទ្រីស គណនេយ្យសង្គម (SAM)។ ដោយកំណត់ជនទីទាល់ក្រនៅតាមទីជនបទចំនួនត្រឹមតែ ១ លាននាក់ជាគោលដៅ (ប្រហែល ៤៣% នៃចំនួនជនក្រីក្រសរុប) ជនក្រីក្រនៅទីជនបទត្រូវបានបំបែកទៅជា ២ ប្រភេទ៖ មួយប្រភេទ គឺជាជនគោលដៅនៃអន្តរាគមន៍ក្នុងការអនុវត្តតាមរបស់យើង និងមួយប្រភេទទៀត គឺជាជនមិនមែនគោលដៅ។ ដើម្បីជៀសវាងភាពលម្អៀង គ្រួសារគោលដៅត្រូវបានជ្រើសរើសដោយចៃដន្យ ក្នុងចំណោមជនក្រីក្រនៅតាមទីជនបទ។ ការប្រើប្រាស់ជាមធ្យមសម្រាប់មនុស្សម្នាក់ក្នុងក្រុមនីមួយៗ ត្រូវបានបង្ហាញក្នុងតារាងទី២ និងក្រាហ្វិកទី២។ ដោយរួមបញ្ចូលជាមួយគំរូការអនុវត្តតាមខ្នាតតូចដែលនឹងត្រូវបង្ហាញនៅផ្នែកបន្ទាប់ យុទ្ធសាស្ត្រនេះអាចឲ្យយើងប៉ាន់ស្មានបានពីផលប៉ះពាល់នៃអន្តរាគមន៍នីមួយៗ លើការបែងចែកនៅក្នុងគ្រួសារទាំងមូល ដែលផ្ទុយទៅនឹងផលប៉ះពាល់ជាមធ្យមនៅក្នុងក្រុមនីមួយៗ។

**ក្រាហ្វិកទី១៖** សមាមាត្រនៃប្រជាជននៅជនបទ និងទីប្រជុំជនក្នុងក្រុមគ្រួសារនីមួយៗ



ផ្អែកលើវិធីសាស្ត្រនេះ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា អាចឲ្យយើងប៉ាន់ស្មានបានពីចំនួនជនក្រីក្រ និងស្ថានភាពភាពទីទាល់ក្រនៅក្នុងក្រុមគ្រួសារនីមួយៗបាន។ យើងបានរកឃើញថាប្រជាជនកម្ពុជាចំនួន ២.៧៥ លាននាក់ រស់នៅក្រោមបន្ទាត់នៃភាពទីទាល់ក្រខ្លាំងក្នុងឆ្នាំ២០១១ ដែលក្នុងចំណោមនោះមាន២០.២% រស់នៅតាមជនបទ និង ១៣.៦% រស់នៅតាមទីប្រជុំជន (ក្រាហ្វិកទី១)។

**តារាងទី៣៖** អត្រាភាពទីទាល់ក្រតាមក្រុមគ្រួសារ

| អត្រាភាពទីទាល់ក្រ – ឆ្នាំគោល | | | |
|---|---|---|---|
| ទីប្រជុំជន | គោលដៅ | ជនបទ | សរុប |
| ១៣.៦៦% | ១០០% | ២០.១៧% | ១៨.៩% |

**ក្រាហ្វិកទី២៖** ការប្រើប្រាស់សម្រាប់មនុស្សម្នាក់ក្នុងក្រុមគ្រួសារមួយ




ការអង្កេតនេះ បង្ហាញពីរាល់សកម្មភាពផលិតកម្ម និងការរកចំណូលនៅកម្រិតគ្រួសារក្នុងមួយឆ្នាំ ដោយរួមបញ្ចូលទាំងបៀវត្សរ៍ និងចំណូលទាំងអស់ពីការងារតាមរដូវកាល និងអាចឲ្យយើងដឹងពីផលប៉ះពាល់ចំណូលប្រចាំឆ្នាំ ពីការធ្វើចំណាកស្រុករបស់គ្រួសារតាមរដូវកាល។

ម៉ាទ្រីសគណនេយ្យសង្គមនេះ ត្រូវបានបែងចែកចេញជាវិស័យផលិតកម្មចំនួន២២ ទំនិញចំនួន២១ កត្តាផលិតកម្មចំនួន៧ ពន្ធចំនួន៣ និងក្រុមគ្រួសារចំនួន៥ ចំណែកឯស្ថាប័នគឺរួមបញ្ចូលទាំងរដ្ឋាភិបាល និងរដ្ឋបាលសាធារណៈ ក៏ដូចជាស្ថាប័នខាងក្រៅ (ទូទាំងពិភពលោក) (តារាង ក១ នៅក្នុងឧបសម្ព័ន្ធ)។

**ម៉ាទ្រីសគណនេយ្យភាពសង្គមត្រូវបានបែងចែកចេញជា៖**

- **២២** វិស័យផលិតកម្ម
- **២១** ទំនិញ
- **៧** កត្តាផលិតកម្ម
- **៣** ពន្ធ
- **៥** ក្រុមនៃគ្រួសារ
- ស្ថាប័នទាំងឡាយរួមបញ្ចូលទាំងរដ្ឋាភិបាល រដ្ឋបាល-សាធារណៈ និងពិភពលោក (ឧបសម្ព័ន្ធ តារាង A1)

## ការផ្សារភ្ជាប់គ្រួសារទៅនឹងសេដ្ឋកិច្ច ក្នុងមូលដ្ឋានរបស់ពួកគេ៖ ភាពច្នៃប្រឌិតនៃការធ្វើសំណាក

គោលបំណងនៃការធ្វើសំណាករបស់យើង គឺដើម្បីឆ្លុះបញ្ចាំងនូវផលប៉ះពាល់នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រដែលរួមមាន៖ ការផ្តល់សាច់ប្រាក់ ជំនាញ និងទ្រព្យផលិត ទោះជាយ៉ាងណាក៏ដោយគំរូគណនាសមតាទូទៅ ដែលអាចគណនាបាន មិនអាចឲ្យយើងតាមដានពីផលប៉ះពាល់នៃវិនិយោគធនធានមនុស្ស និងសម្ភារៈ ដល់គ្រួសារគោលដៅបានទេ ក្រៅពីឥទ្ធិពលរបស់វា ទៅលើផលិតកម្មដែលត្រូវបានប្រើប្រាស់នៅកម្រិតបែងចែកតាមវិស័យ។ ម្យ៉ាងទៀតកត្តាពលកម្ម និងទុនផលិតកម្ម ត្រូវបានប្រមូលផ្តុំ និងចាត់ថ្នាក់ដោយយោងទៅតាមប្រភេទរបស់វាតែប៉ុណ្ណោះ។ គំរូគណនាសមតាទូទៅ ធ្វើការបែងចែកកត្តាទីផ្សារទៅតាមក្រុមគ្រួសារ និងប្លុកផលិតកម្មដោយផ្អែកលើវិស័យ។ គ្រួសារផ្គត់ផ្គង់ពលកម្មដោយផ្អែកលើ ចំណែកទីផ្សារពលកម្មជាក់លាក់របស់ពួកគេ (ឧទាហរណ៍មានជំនាញ ឬ គ្មានជំនាញ រស់នៅតាមទីប្រជុំជន ឬ ជនបទ អាស្រ័យទៅតាមឆ្នាំនៃការអប់រំ ឬ ការ

បណ្តុះបណ្តាល)។ សម្រាប់ប្រភេទកត្តានីមួយៗ ដើម្បីឲ្យតុល្យភាពទីផ្សារមានលំនឹង វាទាមទារឲ្យបរិមាណការផ្គត់ផ្គង់ស្មើទៅនឹងតម្រូវការដោយកត្តាបៀវត្សរ៍ ឬ កត្តាចំណូលឲ្យស្មើទៅនឹងផលិតភាព។

ជាលទ្ធផល យើងមិនអាចធ្វើការតាមដានផលប៉ះពាល់នៃកំណើនផលិតភាពកម្មករ ឲ្យលើសពីការផ្គត់ផ្គង់ពលកម្មទាំងមូលនោះទេ។ ស្រដៀងគ្នានេះដែរ ការផ្តល់ទ្រព្យផលិតទៅកាន់គ្រួសារគោលដៅ មិនអាចធ្វើឡើងតាមរយៈផលប៉ះពាល់របស់វាទៅលើចំណូលជាក់លាក់របស់គ្រួសារ ក្រៅពីកត្តាចំណូលដែលចូលរួមចំណែក ក្នុងផលិតកម្មបានឡើយ។ អាស្រ័យហេតុនេះ គ្រួសារមិនផលិតទំនិញនិងសេវាទេផ្ទុយទៅវិញពួកគេ ផ្តល់កត្តាផលិតកម្មដល់កត្តាទីផ្សារ ហើយវិស័យផលិតកម្មប្រើប្រាស់កត្តាទាំងនេះ នឹងបែងចែកចំណែកប្រាក់ចំណូលទៅតាមសហគ្រាស និងគ្រួសារ។ ដូចដែលបានឃើញនៅលើរូបភាពទី១ មិនមានព្រួញណាភ្ជាប់ "គ្រួសារ" ទៅនឹង "សកម្មភាព" ក្នុងក្របខ័ណ្ឌគណនាសមតាទូទៅ នោះទេ។

នេះជាបញ្ហាសំខាន់សម្រាប់ការសិក្សានេះ ព្រោះស្តង់ដារនៃគំរូគណនាសមតាទូទៅ មាននូវកត្តាផលិតកម្មពីគ្រប់គ្រួសារទាំងអស់តាមប្រភេទនៅកម្រិតវិស័យ។ ទម្រង់បែបនេះ ធ្វើឲ្យអ្នកស្រាវជ្រាវមិនអាចតាមដាន ផលប៉ះពាល់ពីការផ្តល់ទ្រព្យផលិតដល់គ្រួសារអ្នកទទួលផល លើសកម្មភាពផលិតកម្មផ្ទាល់ខ្លួនរបស់ពួកគេបានទេ។ ដើម្បីគណនាផលប៉ះពាល់នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រលើសកម្មភាព ផលិតភាពរបស់អ្នកទទួលផលបាន ការសិក្សានេះបានបង្កើតគណនីផលិតកម្មកសិកម្មមួយ និងកត្តាផលិតភាពដែលជាក់លាក់សម្រាប់គ្រួសារក្នុងក្រុមគោលដៅរបស់យើង ដោយមានការញែកពីគ្នានូវផលិតកម្មកសិកម្ម ពលកម្មកសិកម្មមិនមានជំនាញ និងដើមទុនកសិកម្ម (ដើម្បីបែងចែកសកម្មភាព និងកត្តាដែលជាក់លាក់សម្រាប់ក្រុមគោលដៅរបស់យើង)។

វិធីសាស្ត្រនេះ អនុញ្ញាតឲ្យគំរូគណនាសមតាទូទៅរបស់ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច មានដំណើរការការអនុវត្តតាមខ្នាតតូចដែលពឹងផ្អែកលើលក្ខណៈនៃក្រុមគ្រួសារគោលដៅសំខាន់ ដោយដោះស្រាយនូវផលិតភាព និងកត្តាជម្រុញរបស់ពួកគេ សម្រាប់ប្រភពចំណូល និងការពឹងផ្អែករបស់ពួកគេលើទីផ្សារជនបទ។

ជាមួយនឹងក្របខ័ណ្ឌការធ្វើសំណាកថ្មីនេះ ការចូលរួមក្នុងសកម្មភាពមានផលិតភាពរបស់គ្រួសារគោលដៅ អាចត្រូវបានធ្វើគ្រាប់តាមវិធី ២ របៀប៖ (១) ការចូលរួមចំណែករបស់ពួកគេទៅក្នុងទីផ្សារពលកម្មជនបទ និងផលិតកម្មទំនិញនិងសេវា រួមបញ្ចូលនឹងការចូលរួមចំណែកពីគ្រួសារក្នុងក្រុមផ្សេងទៀត និង (២)ផលិតកម្មទំនិញកសិកម្មដោយផ្ទាល់របស់ពួកគេ មិនថាសម្រាប់លក់ ឬ សម្រាប់ប្រើប្រាស់នៅផ្ទះ ដែលបង្កើតឡើងដោយពលកម្ម ឬ ដើមទុន ដែលពួកគេមានស្រាប់ ឬ ទទួលបានពីការឧបត្ថម្ភ។ ដោយការបំបែកសកម្មភាពផលិតកម្មជាក់លាក់ទៅកាន់គ្រួសារគោលដៅ ការសិក្សានេះ គឺអាចតាមដាន និងវាស់ផលប៉ះពាល់នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រលើចំណូល និងការប្រើប្រាស់ ទន្ទឹមនឹងការទទួលខុសត្រូវលើផលប៉ះពាល់លើសេដ្ឋកិច្ចក្នុងមូលដ្ឋាន។

ភាពជាក់លាក់នៃការធ្វើសំណាកថ្មីនេះ អនុញ្ញាតឲ្យអ្នកចូលរួមក្នុងកម្មវិធីបញ្ចប់ភាពទីទាល់ក្រ ដើម្បីបង្កើតផលិតផលសម្រាប់ការប្រើប្រាស់ដោយខ្លួនគេ ឬ សម្រាប់យកទៅលក់ក្នុងទីផ្សារតាមមូលដ្ឋាន។ ក្នុងន័យនេះ វាពិតជាមានភាពខុសគ្នាពីការធ្វើសំណាកផលិតកម្មតាមផ្ទះ ដែលអាចផលិត និងប្រើប្រាស់ដោយគ្រួសារ ដែលមិនយកទៅលក់នៅទីផ្សារក្នុងស្រុក (លក្ខណៈធម្មតាសម្រាប់គំរូគណនាសមតាទូទៅតំណាងឲ្យសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍ)។ ភាពជាក់លាក់នៃគំរូនេះធ្វើឲ្យផលិតកម្មត្រូវបានបង្កើតឡើង ដោយបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដែលប្រើប្រាស់ការផ្តល់ជាធនធានមនុស្ស និងធនធានសម្ភារៈ សម្រាប់លក់ ឬ សម្រាប់ប្រើប្រាស់នៅតាមផ្ទះ។ សំខាន់បំផុត គឺផលប៉ះពាល់លើចំណូលរបស់អ្នកទទួលផលឥឡូវនេះអាចត្រូវបានកំណត់ តាមដាន និងវាស់វែងបាន។

ការបន្តអនុវត្តក្របខ័ណ្ឌគណនាសមតាទូទៅ ដែលអាចគណនាបានបូករួមនឹង៖ (ក) ការបែងចែកក្រុមនៃគ្រួសារដែលឆ្លើយតបទៅនឹងយុទ្ធសាស្ត្រគោលដៅរបស់យើង និង (ខ) លំហាត់អនុវត្តតាមខ្នាតតូចដែលទទួលខុសត្រូវចំពោះគម្លាតនៃគ្រួសារក្រីក្រទាំងអស់ ធៀបជាមួយនឹងបន្ទាត់នៃភាពទីទាល់ក្រ អនុញ្ញាតឲ្យយើងអាចធ្វើការអង្កេតនូវផលប៉ះពាល់នៃភាពទីទាល់ក្រក្នុងកម្រិតគ្រួសារ ក៏ដូចជាសក្តានុពលផលប៉ះពាល់ម៉ាក្រូសេដ្ឋកិច្ចនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ។

៣ ផ្នែកទី

# លទ្ធផលនៃលំហាត់អនុវត្តតាមលើ ផលប៉ះពាល់ និងលទ្ធភាពបញ្ចប់ភាពទីទាល់ក្រ

អន្តរាគមន៍មានសមាសភាគបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រនៅក្នុងសមាមាត្រផ្សេងៗគ្នា។ ការប្រៀបធៀបនៅក្នុងទម្រង់ជាច្រើន អំពីឥទ្ធិពលអន្តរាគមន៍ដែលរួមបញ្ចូលបណ្តុំបញ្ចប់ភាពទីទាល់ក្រ អនុញ្ញាតឲ្យយើងអាចធ្វើការវិភាគ អំពីការបំពេញបន្ថែម និងសក្តានុពលដោះដូរ ដែលរួមជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍ជនបទផ្សេងទៀតបាន។

## សំណុំនៃលំហាត់អនុវត្តតាម

សេណារីយ៉ូទី១ មានកម្មវិធីផ្តល់សាច់ប្រាក់ដែលកំណត់យកគ្រួសារគោលដៅ ដូចគ្នាទៅនឹងសេណារីយ៉ូបន្តបន្ទាប់ទាំងអស់។ សាច់ប្រាក់ ដែលពួកគេទទួលបាន គឺស្មើនឹងថ្លៃចំណាយសរុបនៃបញ្ចប់ភាពទីទាល់ក្រ។ សេណារីយ៉ូនេះ ផ្តល់នូវចំណុចដៅមួយ ឬ ករណីជាក់ស្តែងមួយ ដើម្បីវាយតម្លៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ។ ក្រៅពីការប្រៀបធៀបផលប៉ះពាល់សេដ្ឋកិច្ចដោយផ្ទាល់ និងដោយប្រយោល យើងក៏អាចប្រៀបធៀបផលប៉ះពាល់លើភាពទីទាល់ក្រ រវាងការផ្តល់ទ្រព្យផលិត ឬ ការវិនិយោគសាធារណៈ ជាមួយនឹងការផ្តល់សាច់ប្រាក់បានផងដែរ។

ការអនុវត្តតាមបន្ទាប់ (សេណារីយ៉ូទី២ និងទី៣) គឺជាការធ្វើសំណាកអន្តរាគមន៍ ដោយបញ្ចូលគ្នារវាងការឧបត្ថម្ភសាច់ប្រាក់ជាមួយនឹងសមាសភាគបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ តាមសមាមាត្រខុសៗគ្នា។ សេណារីយ៉ូទី៥ និង ទី៦ មាន



បំណងដើម្បីសាកល្បង ការបំពេញបន្ថែមរវាងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ និងគោលនយោបាយអភិវឌ្ឍន៍ជនបទដែលជួយដល់ទីផ្សារជនបទនៅកម្ពុជា។ សមាសភាគនៃសេណារីយ៉ូនីមួយៗនេះ ត្រូវបានរៀបរាប់លម្អិតនៅក្នុងតារាងទី៤ ខាងក្រោម។

**តារាងទី៤៖** សមាសភាគគោលនយោបាយអន្តរាគមន៍ទៅតាមសេណារីយ៉ូនីមួយៗ

| សេណារីយ៉ូ | ការអន្តរាគមន៍ | សមាសភាគ | ចំណែកមូលនិធិសរុប |
|---|---|---|---|
| សេណារីយ៉ូទី១ | ការឧបត្ថម្ភសាច់ប្រាក់ | ការឧបត្ថម្ភសាច់ប្រាក់ | ១០០% |
| សេណារីយ៉ូទី២ | បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ក" | ការឧបត្ថម្ភសាច់ប្រាក់<br>ទ្រព្យផលិត | ៥០%<br>៥០% |
| សេណារីយ៉ូទី៣ | បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ខ" | ការឧបត្ថម្ភសាច់ប្រាក់<br>ទ្រព្យផលិត<br>ការបណ្តុះបណ្តាលវិជ្ជាជីវៈ | ៥០%<br>៣០%<br>២០% |
| សេណារីយ៉ូទី៤ | ផលប៉ះពាល់ពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ក" នៅអំឡុងពេលទី២ | | |
| សេណារីយ៉ូទី៥ | ផលប៉ះពាល់ពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ខ" នៅអំឡុងពេលទី២ | | |
| សេណារីយ៉ូទី៦ | បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ក" និងការវិនិយោគសាធារណៈលើប្រព័ន្ធផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន | ការឧបត្ថម្ភសាច់ប្រាក់<br>ទ្រព្យផលិត<br>ការវិនិយោគសាធារណៈលើប្រព័ន្ធផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន | ៤០%<br>៤០%<br>២០% |
| សេណារីយ៉ូទី៧ | បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ក" និងការវិនិយោគ សាធារណៈលើហេដ្ឋារចនាសម្ព័ន្ធកសិកម្ម | ការផ្តល់សាច់ប្រាក់<br>ទ្រព្យផលិត<br>ការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធកសិកម្ម | ៤០%<br>៤០%<br>២០% |

នៅក្នុងសេណារីយ៉ូទាំងអស់លើកលែងតែ សេណារីយ៉ូទី៤ និង ទី៥ មិនបញ្ជាក់អំពីអន្តរាគមន៍ថ្មីណាមួយនោះទេ គឺគ្រាន់តែធ្វើការតាមដានផលប៉ះពាល់យូរអង្វែង នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រប៉ុណ្ណោះ ដូច្នេះយើងសន្មតថា៖

- ចំណាយសាធារណៈសរុប (T) ដែលប្រើប្រាស់ជាហិរញ្ញប្បទានដល់អន្តរាគមន៍ គឺមានចំនួនដូចគ្នា។
- អន្តរាគមន៍ ត្រូវបានផ្តល់មូលនិធិដោយជំនួយបរទេស។ នេះ គឺដើម្បីញែក និងវិភាគផលប៉ះពាល់ដល់សេដ្ឋកិច្ចនៅពេលមានវិធានការតម្លើងពន្ធ។
- ការបែងចែកនូវការឧបត្ថម្ភទ្រព្យ និងសាច់ប្រាក់ បង្កើតថ្លៃចំណាយរដ្ឋបាលចំនួន ២៥% នៃតម្លៃដែលបានផ្តល់។
- ការមានសមាសភាគនៃការផ្តល់សាច់ប្រាក់ នៅគ្រប់សេណារីយ៉ូនីមួយៗ អ្នកទទួលផលក៏ត្រូវបានកំណត់ដូចៗគ្នានៅសេណារីយ៉ូនីមួយៗ ដូច្នេះមានន័យថា ក្រុមគ្រួសារគោលដៅក៏ដូចគ្នាដែរ នៅក្នុងអន្តរាគមន៍នីមួយៗ។
- សេណារីយ៉ូទាំងអស់ ខុសគ្នានៅត្រង់ចំណែកមូលនិធិសាធារណៈសរុប សម្រាប់សមាសភាគអន្តរាគមន៍នីមួយៗ។

សេណារីយ៉ូទី៤ និង ទី៥ ធ្វើការតាមដានផលប៉ះពាល់ពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ក" និង "ខ" (មានគំរូក្នុងសេណារីយ៉ូទី២ និង ទី៣) នៅក្នុងឆ្នាំដំបូងបន្ទាប់ពីការផ្តល់ ដូច្នេះសេណារីយ៉ូទាំងពីរនេះ មិនត្រូវការមូលនិធិថ្មីទេ ព្រោះការឧបត្ថម្ភសាច់ប្រាក់ និងការបណ្តុះបណ្តាល ត្រូវបានធ្វើឡើងរួចទៅហើយ។



គំរូនៃការឧបត្ថម្ភសាច់ប្រាក់ គឺមានលក្ខណៈចំគោលដៅចំពោះក្របខ័ណ្ឌវិភាគដោយយោងទៅតាមហេតុផលទាំងឡាយដែលបានពន្យល់ខាងលើ៖ រដ្ឋាភិបាលធ្វើការបែងចែក នូវការផ្តល់សាច់ប្រាក់ទៅដល់គ្រួសារគោលដៅ ដែលបានកំណត់ កម្មវិធីនេះត្រូវចំណាយបន្ថែមទៅលើសេវារដ្ឋបាល ២៥% នៃទំហំសាច់ប្រាក់ទាំងស្រុងដែលត្រូវផ្តល់ ហើយដែលការបង្កើតនូវកម្មវិធីនេះ គឺផ្អែកទាំងស្រុងទៅលើប្រព័ន្ធរដ្ឋបាលកម្ពុជា ដែលត្រូវប៉ាន់ប្រមាណ និងធ្វើគំរូ នៅក្នុងទិន្នន័យដែលមានស្រាប់ និងក្របខ័ណ្ឌគណនាសមតាទូទៅ (CGE)។

ការបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវធ្វើគំរូ ដោយផ្អែកលើប្រព័ន្ធអប់រំដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា។ ការប៉ាន់ប្រមាណថ្លៃចំណាយ និងផលប៉ះពាល់ ត្រូវបានយកគំរូតាមកម្មវិធីសាលាកសិករ (Farmers Field School, FFS) នៅប្រទេសបង់ក្លាដេស (Danida ឆ្នាំ២០១១)។ យើងសន្មតថា សេវាទាំងនេះប្រើប្រាស់កត្តា និងធាតុចូលដូចគ្នា ទៅនឹងសេវាអប់រំ និងការបណ្តុះបណ្តាលដែលមានស្រាប់នៅកម្ពុជា និងត្រូវបញ្ចូលទៅក្នុងម៉ាទ្រីសគណនេយ្យភាពសង្គម និងក្នុងការធ្វើគំរូ។ ការបណ្តុះបណ្តាលដែលផ្តល់ដោយបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ មានលក្ខណៈដូចទៅនឹងសេវាអប់រំដែលមានស្រាប់ គឺដោយផ្តោតលើការផ្តល់ជំនាញលេខ និងអក្ខរកម្ម ព្រមទាំងជំនាញវិជ្ជាជីវៈ និងគ្រប់គ្រងផងដែរ ហើយដែលការប៉ាន់ស្មានចំណាយ និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច នៃសកម្មភាពទាំងនេះ វាទាមទារនូវវិធីសាស្ត្រធ្វើគំរូមួយជាក់លាក់។ ការវិភាគចំណាយ និងផលចំណេញដែលមានស្រាប់ និងលទ្ធផលស្រាវជ្រាវអំពីឥទ្ធិពលសមាសភាគ ការបណ្តុះបណ្តាល គឺមានភាពកម្រនៅឡើយ ហើយក្នុងនោះការប៉ាន់ស្មានពីផលប៉ះពាល់របស់សមាសភាគទាំងនេះលើផលិតភាពការងារ និងបច្ចេកទេសផលិតកម្ម គឺស្ទើរតែមិនមានទាល់តែសោះ។ ប៉ុន្តែទោះបីជាបែបនេះក្តី កម្មវិធី FFS អាចផ្តល់ជាឧទាហរណ៍ឲ្យយើងនូវអ្វីដែលការបណ្តុះបណ្តាលវិជ្ជាជីវៈទាំងនេះអាចសម្រេចបាន ហើយយើងអាចធ្វើការប្រៀបធៀបជាមួយនឹងឧទាហរណ៍ទាំងនោះបាន។ កម្មវិធី FFS បានធ្វើការសាកល្បងនៅក្នុងប្រទេសបង់ក្លាដេស ដោយមានការសហការគ្នារវាងរដ្ឋាភិបាលបង់ក្លាដេស និងរដ្ឋាភិបាលដាណឺម៉ាក ដែលត្រូវបានកត់ត្រា និងវាយតម្លៃយ៉ាងល្អិតល្អន់ដោយ Danida (ឆ្នាំ២០១១) និងវាផ្តល់ជាឧទាហរណ៍យ៉ាងលម្អិតមួយ ដែលអាចយកមកប្រើបានសម្រាប់បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដែលយើងកំពុងអនុវត្តតាមក្នុងការសិក្សាមួយនេះ។ ដូច្នេះ យើងយករបៀបគណនាចំណាយ និងផលចំណេញរបស់ពួកគេ មកគណនាថ្លៃចំណាយក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់យើង ហើយយើងគណនាទិន្នផលផលប៉ះពាល់របស់យើង ដោយផ្អែកលើការប៉ាន់ស្មានបែបវិទ្យាសាស្ត្រវាស់វែងសេដ្ឋកិច្ចនៃផលប៉ះពាល់ទាំងនោះ។ យើងសន្មតថា ការផលិតសេវាទាំងនេះ ត្រូវការជំនួយសម្រាប់អ្នកទទួលផលមានកម្រិតស្មើគ្នាទៅនឹងកម្មវិធី FFS នៅក្នុងប្រទេសបង់ក្លាដេសដែរ។ ប៉ុន្តែដំណើរការផលិតកម្ម (ធាតុចូលកម្លាំងពលកម្ម ដើមទុន និងបច្ចេកវិទ្យា) គឺមានកម្រិតស្មើទៅនឹងសេវាអប់រំ និងបណ្តុះបណ្តាលដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា។

ការស្រាវជ្រាវអំពីបណ្ដុំយន្តការបញ្ចប់ភាពទីទាល់ក្រនៅប្រទេសបង់ក្លាដែស បានបង្ហាញថា អ្នកទទួលផលនឹងចំណាយពេលវេលាច្រើនបន្ថែមទៀត ទៅក្នុងសកម្មភាពផលិតកម្មរបស់ពួកគេ នៅពេលពួកគេទទួលបានទ្រព្យផលិត។ Banerjee et al. (ឆ្នាំ២០១៥) បានប៉ាន់ប្រមាណថា ការផ្គត់ផ្គង់កម្លាំងពលកម្មរបស់អ្នកចូលរួម ដែលជាមនុស្សពេញវ័យកើនឡើងជាមធ្យម ១៧.៥នាទីក្នុងមួយថ្ងៃ ក្នុងករណីសិក្សាទាំងអស់ទូទាំងប្រទេស។ ចំណែកឯ Blattman et al. (ឆ្នាំ២០១៤) វិញ បានប៉ាន់ស្មានថា ការឧបត្ថម្ភមិនមែនសាច់ប្រាក់បង្កើនម៉ោងធ្វើការជាមធ្យម១៧%។ ធ្វើការឆ្លុះបញ្ចាំងដោយផ្អែកទៅតាមឥរិយាបថ និងការស្រាវជ្រាវទាំងនេះ យើងសន្មតថា អ្នកដែលទទួលបានទ្រព្យផលិត នឹងបន្ថែមម៉ោងធ្វើការរបស់គេជាមធ្យមមួយម៉ោងថែមទៀតក្នុងមួយសប្ដាហ៍។ ម៉ោងធ្វើការបន្ថែមនេះ គឺសំដៅទៅលើសកម្មភាពផលិតកម្មដំណាំ និងការចិញ្ចឹមសត្វរបស់ពួកគេ។ បើយើងប្រៀបធៀបលទ្ធផលនៃការប៉ាន់ស្មាននេះ ទៅនឹងលទ្ធផលប៉ាន់ស្មានខាងលើ ចំនួនម៉ោងបន្ថែមនេះ គឺនៅមានកម្រិតខ្សោយនៅឡើយ។

សេណារីយ៉ូទី៦ និង ទី៧ មានបំណងវិភាគការបំពេញគ្នារវាងបណ្ដុំយន្តការបញ្ចប់ភាពទីទាល់ក្រ ទៅនឹងគោលនយោបាយអភិវឌ្ឍន៍ជនបទដែលការបំពេញគ្នានេះជួយដល់ដំណើរការទីផ្សារ និងសមត្ថភាពផលិតកម្មកសិកម្មតាមមូលដ្ឋាន។ ដូច្នេះ យើងរៀបចំការអនុវត្តតាមក្នុងសេណារីយ៉ូទាំងពីរនេះ ដោយដាក់ការឧបត្ថម្ភសាច់ប្រាក់ និងទ្រព្យផលិតបញ្ចូលគ្នាជាមួយនឹងការវិនិយោគសាធារណៈតាមជនបទ។

នៅក្នុងសេណារីយ៉ូទី៦ មូលនិធិសរុបត្រូវបានបែងចែកដោយ ៤០% ទៅក្នុងការផ្ដល់សាច់ប្រាក់ ៤០%ទៅក្នុងការផ្ដល់ទ្រព្យផលិត និង២០%ទៅក្នុងការវិនិយោគសាធារណៈលើប្រព័ន្ធផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។ ខណៈដែលគំរូគណនាសមតាទូទៅ (CGE) របស់យើងនៅពេលនេះ គឺជាការធ្វើសំណាកទៅលើការបង្កើនវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដោយផ្អែកទៅលើការរៀបចំថវិកាសាធារណៈ និងការអនុវត្តដែលមានស្រាប់ យើងក៏ចង់ឆ្លុះបញ្ចាំងផងដែរពីផលប៉ះពាល់នៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ទៅលើដំណើរការទីផ្សារក្នុងមូលដ្ឋានផងដែរ។ ដើម្បីធ្វើដូច្នេះបាន យើងសន្មតលើផលប៉ះពាល់ដែលកើតមានដល់កត្តាផលិតភាពទាំងអស់នៃវិស័យពាណិជ្ជកម្ម និងដឹកជញ្ជូន។ យើងធ្វើការប៉ាន់ស្មាននេះ ដោយផ្អែកលើឯកសារធំៗដែលមានស្រាប់[៧] ដែលប៉ាន់ស្មានតាមបែបវិទ្យាសាស្ត្រ វាស់វែងសេដ្ឋកិច្ចលើផលរបរពីការវិនិយោគសាធារណៈទាំងនេះ ក្នុងចន្លោះពី ០.២ ទៅ ០.៤ ក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច (ក្នុងន័យកំណើនសេដ្ឋកិច្ច) និងក្នុងកម្រិតនៃកត្តាផលិតកម្មតាមវិស័យ។ នៅប្រទេសកម្ពុជា កង្វះប្រព័ន្ធផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ធ្វើឲ្យរាំងស្ទះដល់ដំណើរការទីផ្សារតាមមូលដ្ឋានជនបទ។ ភាពខ្វះខាតបទប្បញ្ញត្តិសម្រាប់ពាណិជ្ជកម្មក្នុងមូលដ្ឋាន ធ្វើឲ្យគម្លាតនៃតម្លៃរវាងទីផ្សារមួយទៅមួយ នៅតែមានភាពខុសគ្នា ហើយទីផ្សារទាំងនេះ គឺកំណត់ដោយឈ្មួញកណ្ដាល។ យោងតាមបរិបទនេះ តម្លៃផលរបរពីការវិនិយោគក្នុងការអនុវត្តតាមរបស់យើង អាចចាត់ទុកថាមានភាពអភិរក្ស (ឧ. ០.២)។

សេណារីយ៉ូទី៧ គឺផ្អែកលើការបែងចែកដូចគ្នានឹងសេណារីយ៉ូទី៥ លើកលែងតែការវិនិយោគសាធារណៈ ដែលប្ដូរពីហេដ្ឋារចនាសម្ព័ន្ធទៅជាទំនិញកសិកម្មវិញ ឧទាហរណ៍៖ ប្រព័ន្ធធារាសាស្ត្រ។ ដូច្នេះ ជំនួសឲ្យការតាមដានការបំពេញបន្ថែមនៃបណ្ដុំយន្តការបញ្ចប់ភាពទីទាល់ក្រ ទៅលើប្រព័ន្ធផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ដូចក្នុងសេណារីយោទី៥) សេណារីយ៉ូទី៧ ធ្វើការតាមដានទៅលើការគាំទ្រសាធារណៈផលិតភាពកសិកម្ម និងទិន្នផលផលិតកម្មវិញ។ យុទ្ធសាស្ត្រគំរូដូចគ្នា ត្រូវបានគេប្រើនៅទីនេះ៖ ការវិនិយោគសាធារណៈលើទំនិញកសិកម្ម បង្កើនផលិតភាពផលិតកម្មកសិកម្ម និងផលរបរនៃការវិនិយោគនេះ ត្រូវបានកំណត់ស្មើនឹង ០.២។ ទិន្នផលកសិកម្មកម្ពុជា ដើរក្រោយប្រទេសជិតខាងរបស់ខ្លួន។ តម្រូវការការវិនិយោគដើម្បីបង្កើនដើមទុនផលិតភាព កត្តាផលិតភាព និងបច្ចេកវិទ្យាប្រើប្រាស់ដោយកសិករទាំងខ្នាតតូច និងខ្នាតធំ ត្រូវបានចងក្រងជាឯកសារបានយ៉ាងល្អដោយអ្នកអនុវត្ត អ្នកបង្កើតគោលនយោបាយ និងដៃគូអភិវឌ្ឍន៍នៅកម្ពុជា។ ជាថ្មីម្ដងទៀតយើងចាត់ទុកថា ផលរបរពីការវិនិយោគវិស័យកសិកម្មក្នុងការអនុវត្តតាមរបស់យើង គឺមានកម្រិតមធ្យម។

៧ សូមមើល Anderson et al. (ឆ្នាំ២០០៦) សម្រាប់ការវាយតម្លៃលទ្ធផលនិងវិធីសាស្ត្រនេះ

## លំហាត់អនុវត្តតាមខ្នាតតូច និងផលប៉ះពាល់មកលើភាពទីទាល់ក្រ

ដើម្បីធ្វើការវិភាគផលប៉ះពាល់នៃសេណារីយ៉ូនីមួយៗទៅលើភាពទីទាល់ក្រ ការអនុវត្តតាមខ្នាតតូចដោយផ្អែកលើការប្រើប្រាស់របស់គ្រួសារទាំងអស់ ត្រូវបានគូសគ្រោងឡើង និងប្រើប្រាស់នៅរាល់ការធ្វើអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា។ ដោយសារតែជម្រើន បង្ហាញលម្អិតពីការចំណាយលើចំណីអាហារ និងមិនមែនចំណីអាហាររបស់គ្រួសារនីមួយៗ យើងគណនាការប្រើប្រាស់របស់សមាជិកគ្រួសារនីមួយៗ ដោយគិតជា "ការប្រើប្រាស់សម្រាប់មនុស្សពេញវ័យម្នាក់ក្នុងមួយថ្ងៃ"។ ការធ្វើបែបនេះ អាចឲ្យយើងកំណត់បាននូវគម្លាត (គម្លាតការប្រើប្រាស់) របស់គ្រួសារទៅនឹងបន្ទាត់ភាពទីទាល់ក្រ ព្រមទាំងអាចកំណត់បាននូវស្ថានភាពនៃភាពទីទាល់ក្ររបស់ពួកគេ។ ការប្រើប្រាស់ខ្នាត តំណាងឲ្យស្ថានភាពគ្រួសារដោយផ្អែកលើចំណូល ចំណាយរបស់ពួកគេ និងការឧបត្ថម្ភដែលពួកគេទទួលបានពីគ្រួសារដទៃ និងពីបរទេសក្នុងកម្រិតប្រទេស៖ ខ្នាតតំណាងនេះ គឺជាគោលដើម្បីរៀបចំថវិកាសម្រាប់ក្រុមគ្រួសារនីមួយៗ ក្នុងម៉ាទ្រីសគណនេយ្យសង្គម។

ការអនុវត្តតាមទាំងអស់ ធ្វើការប៉ាន់ស្មានថ្មីលើការប្រើប្រាស់សរុបជាក់ស្តែងរបស់គ្រួសារនីមួយៗ។ មធ្យោបាយការអនុវត្តតាមខ្នាតតូច អាចឲ្យក្រុមអ្នកស្រាវជ្រាវអនុវត្តការផ្លាស់ប្តូរទាំងនេះ ចំពោះការបែងចំណែកទាំងមូលក្នុងការអង្កេតសម្រាប់គ្រួសារនីមួយៗ។ ដូច្នេះ គម្លាតគ្រួសារនីមួយៗទៅនឹងបន្ទាត់ភាពទីទាល់ក្រ នឹងត្រូវបានកែប្រែ។ ជាមួយកម្រិតថ្មីនេះ យើងអាចប៉ាន់ស្មានគម្លាតភាពទីទាល់ក្រ និងចំនួនជនក្រីក្របាននៅថ្នាក់ក្រុម។ ការអនុវត្តតាមខ្នាតតូចទាំងនេះ ប្រើប្រាស់លទ្ធផលការប្រើប្រាស់ និងចំណូលពីសេណារីយ៉ូនីមួយៗ ដើម្បីប៉ាន់ស្មានផលប៉ះពាល់មីក្រូសេដ្ឋកិច្ចនៅកម្រិតគ្រួសារ និងគណនាចំណែកនៃការប្រើប្រាស់ និងចំណូលថ្មីទាំងមុន និងក្រោយសេណារីយ៉ូ។

លទ្ធផលនៃវិធីសាស្ត្រនេះ ត្រូវបានគេកែលម្អនៅកម្រិតមីក្រូសេដ្ឋកិច្ច។ ក្រៅពីការវាយតម្លៃលើបម្រែបម្រួលជាមធ្យមក្នុងមនុស្សម្នាក់ៗនៅកម្រិតក្រុមគ្រួសារ លទ្ធផលនៃវិធីសាស្ត្រនេះក៏ផ្តល់នូវការវាយតម្លៃច្បាស់លាស់ និងលម្អិតអំពីគំរូបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រផងដែរ។ តាមរយៈការកំណត់ក្រុមគ្រួសារគោលដៅ និងការបង្កើតដំណើរការផលិតកម្មឧបករណ៍នេះ រួមជាមួយនឹងយុទ្ធសាស្ត្រកំណត់ក្រុមគោលដៅដែលបានផ្សារភ្ជាប់នៅក្នុងម៉ាទ្រីសគណនេយ្យសង្គម និងគំរូគណនាសមតាទូទៅ ផ្តល់នូវការប៉ាន់ស្មានផលប៉ះពាល់របស់អន្តរាគមន៍ទាំងនេះ លើចំណែកនៃការប្រើប្រាស់របស់គ្រួសារ និងអាចធ្វើការប្រៀបធៀបអត្ថប្រយោជន៍ និងការថ្លឹងថ្លែងរវាងអន្តរាគមន៍ដែលបានបង្កើត។

## លទ្ធផលពីលំហាត់អនុវត្តតាម

### *ចំណុចដៅនៅក្នុងសេណារីយ៉ូ៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់*

ដើម្បីវាយតម្លៃអត្ថប្រយោជន៍ប្រៀបធៀបនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ យើងបានរៀបចំឲ្យមានជាចំណុចដៅមួយរបស់សេណារីយ៉ូ ដែលនៅក្នុងនោះមានការផ្តល់សាច់ប្រាក់ចំនួន ២៥ដុល្លារក្នុងមួយខែ នៅក្នុងទម្រង់ជាការវេរលុយដោយផ្ទាល់ទៅឲ្យក្រុមគ្រួសារគោលដៅដូចៗគ្នា សម្រាប់យកមកវិភាគនៅគ្រប់សេណារីយ៉ូទាំងអស់។ ក្រុមគោលដៅនេះ មានប្រជាជនកម្ពុជាទីទល់ក្រចំនួន ១ លាននាក់ ឬស្មើនឹងចំនួន ១៩៣,៩១៥ គ្រួសារ ហើយទឹកប្រាក់ផ្តល់ដែលពួកគេបានទទួលនៅក្រោមចំណុចដៅនេះ គឺមានចំនួនស្មើគ្នានឹងតម្លៃនៃកញ្ចប់ដែលបានបែងចែកសម្រាប់សេណារីយ៉ូទី២ និង ទី៣។ ដូច្នេះហើយ សេណារីយ៉ូទី១ គឺជាកម្មវិធីផ្ទេរប្រាក់ដែលមានគុណភាពខ្ពស់ បើធៀបនឹងសេណារីយ៉ូផ្សេងៗទៀតនៅពេលក្រោយ ដោយសារវាពាក់ព័ន្ធជាមួយនឹងការរួមបញ្ចូលគ្នានូវការឧបត្ថម្ភសាច់ប្រាក់ និងអន្តរាគមន៍ជាគោលនយោបាយ នៅក្នុងចំនួនសមាមាត្រផ្សេងៗគ្នា។

តារាងទី៥ ធ្វើការសង្ខេបនូវលទ្ធផលសំខាន់ៗមួយចំនួនដែលដកស្រង់ចេញពីចំណុចដៅ នៅក្នុងសេណារីយ៉ូរបស់យើង។ នៅក្នុងដំណាក់កាលដំបូង ការឧបត្ថម្ភប្រាក់ធ្វើឲ្យការប្រើប្រាស់ពិតរបស់អ្នកទទួលផល កើនឡើងរហូតដល់ ២៥% នៅក្នុងឆ្នាំដំបូងនៃអន្តរាគមន៍ ដូច្នេះ៤០%នៃប្រជាជនគោលដៅ នឹងងើបផុតពីបន្ទាត់នៃភាពទីទាល់ក្រខាងស្បៀងអាហារ។ នៅក្នុងចំណោមប្រជាជនកម្ពុជាចំនួន ១លាននាក់ ដែលជាគោលដៅនៅក្នុងសេណារីយ៉ូនេះ មានប្រជាជនក្រីក្រ

នៅជនបទលើសពី ៤៤៣,០០០នាក់ នឹងបង្កើននូវការប្រើប្រាស់របស់ពួកគេបានគ្រប់គ្រាន់ ដើម្បីបំពេញបាននូវលក្ខខណ្ឌតម្រូវបឋមផ្នែកស្បៀងអាហាររបស់ពួកគេ ដូច្នេះហើយអាចត្រូវបានចាត់ទុកថាមិនមែនជាអ្នកក្រីក្រទៀតទេ នៅក្នុងរយៈពេលអនុវត្តកម្មវិធីនេះ។ ផលប៉ះពាល់នៃការផ្តល់សាច់ប្រាក់មកលើអត្រានៃភាពទីទាល់ក្រ គឺវាអាស្រ័យទៅលើគម្លាតដំបូង ដែលមានចម្ងាយពីបន្ទាត់នៃភាពទីទាល់ក្រ សម្រាប់គ្រួសារទទួលផលនីមួយៗ។ យោងទៅលើគម្លាតនៃភាពទីទាល់ក្រីដំបូងនេះ និងរបាយការណ៍នៃការប្រើប្រាស់ប្រាក់ឧបត្ថម្ភ នៅក្នុងចំណោមអ្នកក្រីក្រជនបទ បានឲ្យដឹងថា ផលប៉ះពាល់នៃកម្មវិធីផ្តល់សាច់ប្រាក់នេះ មានកម្រិតខុសៗគ្នា។ ដើម្បីឱ្យយើងជៀសវាងការលម្អៀងក្នុងការជ្រើសរើស ដែលអាចធ្វើឲ្យមានការវាយតម្លៃជ្រុលទៅលើផលប៉ះពាល់នៃកម្មវិធី ដូច្នេះយើងបានធ្វើការជ្រើសរើសបែបឥតព្រាងទុក នូវអ្នកទទួលផលក្នុងចំណោមអ្នកក្រីក្របំផុត។ យើងក៏បានបង្កើតនូវប្រភេទគ្រួសារ នៅក្នុងម៉ាទ្រីសគណនេយ្យសង្គម (Social Accounting Matrix) និងនៅក្នុងគំរូរបស់យើងផងដែរ ដែលមានតែអ្នកទទួលផលទាំងនោះប៉ុណ្ណោះ ដែលការប្រើប្រាស់ការសន្សំ និងប្រាក់ចំណូលរបស់ពួកគាត់ត្រូវបានព្យាករណ៍ដោយផ្អែកលើមូលដ្ឋានការអង្កេតគ្រួសារ។ ការបង្កើតជាប្រភេទគ្រួសារ និងលំហាត់អនុវត្តតាមខ្នាតតូចនេះ ធានាបានថា ផលប៉ះពាល់មកលើភាពទីទាល់ក្រ នឹងត្រូវបានព្យាករណ៍ទៅលើរបាយក្រុមគោលដៅទាំងអស់របស់យើង បើធៀបនឹងមធ្យមភាគសម្រាប់គ្រួសារនីមួយៗ នៅក្នុងក្រុមគោលដៅ។ យើងរកឃើញថាចំនួនអត្រាភាពទីទាល់ក្រ បានធ្លាក់ចុះចំនួន ៤៤% នៅក្នុងចំណោមក្រុមគោលដៅ ហើយធ្លាក់ចុះ១៩% នៅក្នុងចំណោមអ្នកក្រីក្រជនបទទាំងអស់ និង១៦% នៅក្នុងកម្រិតថ្នាក់ប្រទេស (តារាងទី៦ និងទី៧)។ លទ្ធផលភាពទីទាល់ក្រទាំងនេះ បានផ្តល់ឲ្យយើងខ្ញុំនូវចំណុចដៅមួយ ដើម្បីវាយតម្លៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដោយហេតុថាការផ្តល់ជាសាច់ប្រាក់ធ្វើឲ្យអ្នកទទួលផលអាចជ្រើសរើស និងប្រើប្រាស់ដោយផ្ទាល់ ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់ពួកគេ និងដោយហេតុថា បន្ទាត់នៃភាពទីទាល់ក្រត្រូវបានកំណត់សន្ទស្សន៍ ទៅលើតែការប្រើប្រាស់ប៉ុណ្ណោះ។

ការកើនឡើងនូវតម្រូវការទៅលើទំនិញចុងក្រោយ និងសេវានានាពីសំណាក់អ្នកទទួលផល ធ្វើឲ្យមានផលប៉ះពាល់ខាងសេដ្ឋកិច្ច ដូចដែលបានរៀបរាប់នៅក្នុងតារាងA២ នៅក្នុងឧបសម្ព័ន្ធ និងដែលបានសង្ខេបនៅក្នុងតារាងទី៥ ខាងក្រោមនេះ។ ជាក់ស្តែង ផលិតកម្មកសិកម្មរបស់ប្រជាកសិករកម្ពុជា កើនឡើងត្រឹមតែ០.២៣% ប៉ុណ្ណោះ ខណៈដែលការនាំចេញផលិតផលកសិកម្ម ត្រូវបានបង្វែរទិសដៅមករកទីផ្សារក្នុងស្រុក ដើម្បីបំពេញនូវតម្រូវការថ្មីរបស់អ្នកទទួលផលនេះវិញ។ បរិមាណនៃការនាំចូលផលិតផលកសិកម្ម បានកើនឡើងជាមធ្យមនៅក្នុងសេណារីយ៉ូនេះ (ហើយត្រូវនឹងចំនួន ២.៧% ដោយមានការកើនឡើង បើធៀបទៅនឹងឆ្នាំគោល)។ យើងរកឃើញថា មានការកើនឡើងជាមធ្យមពិតប្រាកដនៅក្នុងសន្ទស្សន៍តម្លៃទំនិញនៅក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច ដោយបានប៉ាន់ស្មានថាមានចំនួន០.០២% ។ មូលហេតុដែលការនាំចេញត្រូវបានបង្វែរទិសដៅឆ្ពោះមករកទីផ្សារក្នុងស្រុក និងកត្តាផលិតកម្មត្រូវបានបង្វែរទិសមករកវិស័យកសិកម្មវិញ ដើម្បីធ្វើឲ្យមានផលិតកម្មច្រើនឡើង បានពន្យល់ថា ហេតុអ្វីបានជាយើងរកមិនឃើញការកើនឡើងនៅក្នុង ផ.ស.ស ពិតនៅក្នុងសេណារីយ៉ូនេះ បើទោះជាមិនមានការកើនឡើងជាបង្គួរនូវសមត្ថភាពផលិតកម្មក្នុងស្រុកក៏ដោយ។

**តារាងទី៥៖** លទ្ធផលដែលបានជ្រើសរើសពីសេណារីយ៉ូទី១ នៅក្នុងបម្រែបម្រួលជាភាគរយ

| ការប្រើប្រាស់ពិតរបស់គ្រួសារ | | | ផលិតកម្មកសិកម្ម | ការនាំចូលកសិកម្ម | ការនាំចេញកសិកម្ម | សន្ទស្សន៍តម្លៃទំនិញ | ផ.ស.ស ពិត |
|---|---|---|---|---|---|---|---|
| អ្នកទទួលផល | អ្នកក្រីក្រទាំងអស់ | គ្រួសារទាំងអស់ | ០.២៣% | ២.៧% | -០.២៣% | ០.០២% | ០.០% |
| ២៥.១% | ៨.១% | ០.៧% | | | | | |

លទ្ធផលទាំងនេះ គឺស្រដៀងគ្នាទៅនឹងលទ្ធផលរកឃើញដោយ Levy និង Robinson (២០១៣) ដែលបានធ្វើអង្កេតទៅលើផលប៉ះពាល់ដល់សក្ដានុពលសេដ្ឋកិច្ច នៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់នៅក្នុងប្រទេសកម្ពុជា ជាមួយគ្នានេះ ក៏បានប្រើប្រាស់នូវគំរូគណនាសមតាទូទៅផងដែរ។ បើធៀបទៅនឹងគំរូ CGE ដែលប្រើប្រាស់ដោយ Levy និង Robinson គំរូបច្ចុប្បន្នរបស់យើង គឺផ្អែកទាំងស្រុងទៅលើទិន្នន័យកម្ពុជា ដោយបានផ្ដល់នូវការបំបែកផលិតកម្មគ្រួសារ និងការបំបែកអង្គផ្សំនៃគ្រួសារដែលធ្វើឲ្យការវាយតម្លៃទៅលើផលប៉ះពាល់បានលម្អិត និងសុក្រឹតនៅក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច។ ការប្រៀបធៀបរវាងសំណុំទាំងពីរនៃលទ្ធផលគំរូនេះ បានបង្ហាញនូវសេដ្ឋកិច្ចកម្ពុជាដែលមានភាពធន់កាន់តែខ្លាំងឡើងនៅក្នុងឆ្នាំ២០១១ ដោយវិស័យកសិកម្មអាចប្រកួតប្រជែងកាន់តែខ្លាំងឡើង បើធៀបទៅនឹងប្រទេសជិតខាង និងដៃគូពាណិជ្ជកម្ម ដែលមានសមត្ថភាពខ្លាំងជាងក្នុងការឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការ និងដែលមានអត្រាភាពទីទាល់ក្រទាបជាងខ្លាំង។ ខណៈពេលដែលផលប៉ះពាល់មកលើតម្លៃក្នុងស្រុកទំនងជាមានចំនួនមធ្យមនៅក្នុងការអនុវត្តតាមនាបច្ចុប្បន្ន យើងក៏បានរកឃើញថា កម្មវិធីគាំពារសង្គម ដែលផ្អែកទាំងស្រុងទៅលើអន្តរាគមន៍ដែលគាំទ្រការប្រើប្រាស់របស់អ្នកក្រីក្រ ហាក់ដូចជាមិនគ្រប់គ្រាន់ដើម្បីជម្រុញសេដ្ឋកិច្ចមូលដ្ឋាននៅឡើយ បន្ទាប់ពីរយៈពេលមួយឆ្នាំនៃការអនុវត្តកម្មវិធី។

គួរឲ្យកត់សម្គាល់ផងដែរថា កម្រិតកាន់តែខ្ពស់នៃការឧបត្ថម្ភប្រាក់នៅក្នុងមួយគ្រួសារ អាចនាំឲ្យមានសំណុំលទ្ធផលផ្សេងៗគ្នា ទាំងទៅលើផលប៉ះពាល់ដល់សេដ្ឋកិច្ចមូលដ្ឋាន និងប្រសិទ្ធភាពកំណើនកាន់តែធំ។ បើមើលទៅលើទំហំគ្រួសារជាមធ្យមនៅក្នុងចំនួនប្រជាជនគោលដៅ ការផ្ដល់សាច់ប្រាក់ជាប្រចាំខែក្នុងចំនួន ២៥ដុល្លារ គឺស្មើនឹងចំនួនក្រោម ០.១៥ ដុល្លារ ក្នុងមួយថ្ងៃប៉ុណ្ណោះ ចំពោះអ្នកទទួលផលម្នាក់។ សម្រាប់ប្រជាជនកម្ពុជាដែលរស់នៅក្នុងភាពទីទាល់ក្រ ជាការសមហេតុផលក្នុងការសន្មតថា ជាក់ស្ដែងប្រាក់ផ្ដល់ឲ្យទាំងអស់ដែលបានទទួលនឹងត្រូវបានប្រើប្រាស់ ហើយថាមានការវិនិយោគតិចតួចណាស់ត្រូវបានចាប់ផ្ដើមធ្វើឡើង ដោយផ្អែកលើមូលដ្ឋាននោះ។ Davis និង Handa (២០១៥) បានព្យាករណ៍ថា ការផ្ដល់សាច់ប្រាក់ដែលត្រូវនឹងចំនួនតិចជាង ២០% នៃការប្រើប្រាស់ជាមធ្យមរបស់អ្នកទទួលផល គឺមិនទំនងជាអាចប្រើប្រាស់បានទៅលើអ្វីផ្សេងទៀតក្រៅពីសម្រាប់ការប្រើប្រាស់ជាមូលដ្ឋាននោះឡើយ។ ដូច្នេះ លទ្ធផលរបស់យើង គឺវាស្របគ្នាជាមួយនឹងលទ្ធផលរបស់ពួកគេ ប៉ុន្តែយើងអាចព្យាករណ៍ទុកថា នៅក្នុងកម្រិតដែលមានការឧបត្ថម្ភប្រាក់កម្រិតខ្ពស់ជាងនេះ នោះផលប៉ះពាល់ពីវិធានការសំណាញ់សុវត្ថិភាពសង្គមនេះ មកលើការវិនិយោគ និងមកលើសេដ្ឋកិច្ចមូលដ្ឋាននឹងប្រសើរឡើង។

**តារាងទី៦៖** ចំនួនអ្នកក្រនៅក្នុងសេណារីយ៉ូទី១

| បម្រែបម្រួលចំនួនអ្នកក្រីក្របំផុត | | | ចំនួនអ្នកក្រីក្របំផុត | | | |
|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ០ | ៤៤៣,២៣០ | ៤៤៣,២៣០ | ៤០៦,៩៦៩ | ៥៥៦,៧៤៤ | ១,៩០៣,២៤៥ | ២,៣១០,២១៤ |

**តារាងទី៧៖** អត្រាភាពទីទាល់ក្រថ្មីនៅក្នុងសេណារីយ៉ូទី១

| អត្រាភាពទីទាល់ក្រ | | | | បម្រែបម្រួលអត្រាភាពទីទាល់ក្រ | | | |
|---|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | ជនបទ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ១៣.៦៦% | ៥៥.៦៨% | ១៦.៣៦% | ១៥.៨១% | ០% | -៤៤.៣២% | -១៨.៨៩% | -១៦.១០% |

លទ្ធផលទាំងនេះ ផ្តល់នូវចំណុចដៅមួយសម្រាប់វាយតម្លៃសេណារីយ៉ូក្រោយៗទៀត ទាំងទៅលើផលប៉ះពាល់របស់វាមកលើទីផ្សារក្នុងស្រុក ផលិតកម្ម ការជួញដូរពាណិជ្ជកម្ម និងទៅលើការប្រើប្រាស់ពិតរបស់គ្រួសារ អត្រាភាពទីទាល់ក្រ និងវិសមភាព បើមើលពីទិដ្ឋភាពខាងម៉ាក្រូសេដ្ឋកិច្ចវិញ។

### *បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ*

សេណារីយ៉ូទី២ និង ទី៣ តំណាងឲ្យបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ (ដែលយើងហៅដោយឡែកពីគ្នាថា កញ្ចប់ "ក" និង "ខ" ដែលផ្តោតគោលដៅទៅលើប្រជាជនកម្ពុជាក្រីក្របំផុតនៅជនបទចំនួន ១លាននាក់ ដោយមានការផ្តល់ឲ្យនូវទឹកប្រាក់សមមូលនឹងចំនួន ២៥ដុល្លារក្នុងមួយខែ សម្រាប់មួយគ្រួសារ ដែលស្ថិតនៅក្នុងវិសាលភាពនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ហើយដែលត្រូវបានអនុវត្តជាទូទៅនៅទីកន្លែងផ្សេងទៀតនៅក្នុងទ្វីបអាស៊ី។

### *សេណារីយ៉ូទី២៖ ការផ្តល់សាច់ប្រាក់ (៥០%) និងការផ្តល់ទ្រព្យផលិត (៥០%)*

សេណារីយ៉ូទី២ មានការផ្តល់ជាទ្រព្យផលិត ដែលមានតម្លៃសមមូលទៅនឹងទឹកប្រាក់ចំនួន ៣០០ ដុល្លារអាមេរិក នៅក្នុងមួយគ្រួសារក្នុងមួយឆ្នាំ ដែលបែងចែកស្មើគ្នារវាងសាច់ប្រាក់សុទ្ធ និងទ្រព្យផលិត។ យើងសន្មតថា ទ្រព្យផលិត គឺស្រដៀងគ្នាទៅនឹងដើមទុនកសិកម្មដូច្នេះដែរ រួមមានប្រព័ន្ធជាពសាស្ត្រ និងប្រព័ន្ធគ្រប់គ្រងទឹក និងបសុសត្វ ដែលមានដូចជា៖ បក្សី និងគោក្របី ជាដើម ដែលត្រូវបានទិញនៅតាមមូលដ្ឋានដោយរដ្ឋាភិបាល (បើទោះបីជាទ្រព្យទាំងនោះអាចយកចេញពីប្រភពនាំចូលក៏ដោយ) និងផ្អែកទៅតាមជម្រើសរបស់គ្រួសារទទួលផល[៨]។ គំរូរបស់យើងអាចអនុញ្ញាតឲ្យទ្រព្យផលិតទាំងនេះនាំចូលបាន ប្រសិនបើ និងនៅក្នុងករណីដែលត្រូវការចាំបាច់ ហើយតម្លៃនៅមូលដ្ឋាន គឺជាកត្តាដ៏សំខាន់សម្រាប់ការជួញដូរ និងជាសមាសភាគផ្គត់ផ្គង់នៅក្នុងស្រុកនូវទំនិញដែលឆ្លើយតបទីផ្សារ។ យើងក៏បានសន្មតផងដែរថា ការអនុវត្តនូវអន្តរាគមន៍នេះ គឺពាក់ព័ន្ធជាមួយនឹងចំណាយរដ្ឋបាលបន្ថែមចំនួន ២៥% ទៀត។ ការផ្តល់ថវិកាសរុប ដែលចាំបាច់សម្រាប់រ៉ាប់រងចំណាយនៅក្នុងអន្តរាគមន៍នេះ គឺមានទឹកប្រាក់ចំនួន ៥៨លានដុល្លារអាមេរិក ដែលត្រូវនឹង០.៦% នៃ ផ.ស.ស របស់ប្រទេសកម្ពុជានៅក្នុងឆ្នាំនោះ។

តារាងទី៨ ធ្វើការសង្ខេបអំពីផលប៉ះពាល់សំខាន់ៗដល់សេដ្ឋកិច្ចនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដែលបានសិក្សានៅក្នុងសេណារីយ៉ូទី២។ ជាលទ្ធផលនៃសមាសភាគសាច់ប្រាក់ នោះតម្រូវការទំនិញ និងសេវាពីសំណាក់គ្រួសារទទួលផលបានកើនឡើង គឺជម្រុញឲ្យមានផលិតកម្មក្នុងស្រុក។ ដោយហេតុថា អន្តរាគមន៍ផ្តោតគោលដៅទៅលើតែអ្នកទីទាល់ក្រដូច្នេះអំណាចទិញថ្មីនេះ ជម្រុញលើសលុបឲ្យមានតម្រូវការនូវផលិតផលកសិកម្ម ដូចជា៖ អង្ករ គ្រាប់ធញ្ញជាតិ បន្លែ និងត្រីសាច់ ក៏ដូចជាអាហារកែច្នៃ ដូចជា៖ ប្រេងឆា ជាដើម។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការថ្មីនេះ ការនាំចេញផលិតផលកសិកម្ម ក៏ត្រូវបានបង្វែរទិសដៅមួយផ្នែកមករកទីផ្សារក្នុងស្រុកផងដែរ ហើយការនាំចូលស្បៀងអាហារបានកើនឡើងជាមធ្យម។ ទោះបីជាសមាសភាគនៃលទ្ធផលពីការអនុវត្តតាមនេះ គឺដូចគ្នាទៅនឹងសមាសភាគនៅក្នុងចំណុចដៅនៃការឧបត្ថម្ភប្រាក់ក៏ដោយ ក៏ផលប៉ះពាល់ទាំងស្រុងមានភាពខុសគ្នាដែរ។ ការផ្តល់ទ្រព្យផលិត ធ្វើឲ្យសេដ្ឋកិច្ចមូលដ្ឋានអាចឆ្លើយតបដោយផ្ទាល់ ទៅនឹងការកើនឡើងនូវតម្រូវការបាន។

សមាសភាគការផ្តល់ដើមទុននៅក្នុងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ មានផលប៉ះពាល់ចំនួនពីរផ្ទុយគ្នាមកលើវិស័យកសិកម្ម។ ផលប៉ះពាល់នៅលើជ្រុងម្ខាង គឺវាជួយពង្រឹងនូវតម្រូវការទៅលើត្រីសាច់ និងកសិផលនៅលើទីផ្សារតាមមូលដ្ឋាន នៅក្នុងករណីដែលទ្រព្យទាំងនេះត្រូវបានទិញ។ ផលិតកម្មតាមមូលដ្ឋានត្រូវបានជម្រុញឡើង ការនាំចេញក្នុងចំណែកតូចត្រូវបានបង្វែរទិសដៅមករកទីផ្សារក្នុងស្រុក ហើយការនាំចូលកសិផលបានកើនឡើង (ទោះបីជាមានចំនួនមធ្យមក៏ដោយ)។ ផលប៉ះពាល់មួយទៀត វាគាំទ្រដល់ផលិតកម្មនៅតាមគ្រួសារទៅលើកសិផលទាំងនោះ ដោយគ្រួសារទាំងឡាយ

---

[៨] ការសិក្សាអំពីជម្រើសទៅលើទ្រព្យសម្បត្តិគឺវាហួសពីវិសាលភាពនៃការសិក្សារបស់យើងហើយ ប៉ុន្តែការសម្រេចចិត្តរបស់ពួកគាត់នឹងមិនប៉ះពាល់ដល់លទ្ធផលរបស់យើងទេ ដោយគិតទៅលើការបំបែកអង្គផ្សំវិស័យផលិតកម្ម និងឲ្យតែជម្រើសដែលបានផ្តល់ជូននៅតែស្ថិតនៅក្នុងចំណោមទ្រព្យសម្បត្តិកសិកម្ម និងទ្រព្យសម្បត្តិផលិតបសុសត្វ។

នៅក្នុងក្រុមគោលដៅ។ ប៉ុន្តែជាសំខាន់ ពីព្រោះតែការផ្គត់ផ្គង់ និងតម្រូវការទៅលើកសិផលកើនឡើងដំណាលគ្នា ដូច្នេះការផ្គត់ផ្គង់ និងតម្រូវការនេះនឹងជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច ហើយយើងរកឃើញថាកម្រិតនៃ ផ.ស.ស បានកើនឡើង ០.២%។ ការកើនឡើងនេះ បង្ហាញឲ្យឃើញនូវផលផ្លែសំខាន់ៗពីការវិនិយោគ ទោះបីជាថវិកាសរុបដែលត្រូវការសម្រាប់ផ្ដល់ហិរញ្ញប្បទានដល់អន្តរាគមន៍នេះ មានចំនួនត្រឹមតែ០.៦% នៃ ផ.ស.ស ក៏ដោយ ក៏ផលប៉ះពាល់ទៅលើកំណើនត្រូវបានគេព្យាករណ៍ទុកថា មានចំនួន០.២% បន្ទាប់ពីរយៈពេលមួយឆ្នាំកន្លងទៅ។ ការណ៍នេះ បង្ហាញឲ្យឃើញនូវផលផ្លែពីការវិនិយោគ ដែលមានចំនួន០.៣៣ បន្ទាប់ពីរយៈពេលមួយឆ្នាំនៃការអនុវត្ត ដែលអាចចាត់ទុកថាជាតួលេខខ្ពស់គ្រាន់បើ ជាពិសេស ដោយហេតុថាមានតែពាក់កណ្ដាលនៃថវិកាដែលបានបែងចែកប៉ុណ្ណោះ ត្រូវបានវិនិយោគជាក់ស្ដែងជាដើមទុន ហើយមានទឹកប្រាក់ត្រឹមតែចំនួន២៥% ប៉ុណ្ណោះ ត្រូវបានប្រើប្រាស់ដើម្បីរ៉ាប់រងចំណាយរដ្ឋបាល។

**តារាងទី៨៖** លទ្ធផលដែលបានសម្រាំងជ្រើសរើសពីសេណារីយ៉ូទី២ នៅក្នុងបម្រែបម្រួលជាភាគរយ

| ការប្រើប្រាស់ពិតរបស់គ្រួសារ | | | ផលិតកម្មកសិកម្ម | ការនាំចេញកសិកម្ម | សន្ទស្សន៍តម្លៃទំនិញ | ផ.ស.ស ពិត |
|---|---|---|---|---|---|---|
| អ្នកទទួលផល | អ្នកក្រីក្រទាំងអស់ | គ្រួសារទាំងអស់ | ១.២៥% | -០.១៩% | -០.០១% | ០.២៣% |
| ២០.៧% | ៦.៧% | ០.៦% | | | | |

ផលប៉ះពាល់នៃអន្តរាគមន៍នេះមកលើភាពទីទាល់ក្រ គឺមានចំនួនតិចតួចជាងការឧបត្ថម្ភប្រាក់សុទ្ធ ប៉ុន្តែនៅតែមានសារសំខាន់ ដោយនៅក្នុងនោះគ្រួសារគោលដៅចំនួន ៤ នៅក្នុងចំណោម ១០គ្រួសារ បានងើបផុតពីភាពទីទាល់ក្រនៅដំណាច់ដំណាក់កាលទីមួយ។ (តារាងទី៩ និង ទី១០)។ បណ្ដុំយន្តការបញ្ចប់ភាពទីទាល់ក្រ បានបង្កើតនូវធនធានគ្រប់គ្រាន់សម្រាប់ប្រជាជនចំនួន ៤០០,៥៩៤នាក់ នៅក្នុងចំណោមប្រជាជនគោលដៅចំនួន ១លាននាក់ ដើម្បីបង្កើននូវការប្រើប្រាស់របស់ពួកគេឲ្យនៅលើបន្ទាត់នៃភាពទីទាល់ក្របំផុត។ ការធ្វើជំរឿនថ្មីទៅលើភាពទីទាល់ក្របានឆ្លុះបញ្ចាំងឲ្យឃើញ នូវការប្រែប្រួលនូវចំនួនអ្នកក្រីក្របំផុតនេះ ដែលមានចំនួនប្រមាណជា ១% ទាបជាងចំណុចដៅនៃកម្មវិធីផ្ដល់សាច់ប្រាក់ (សេណារីយ៉ូទី១)។

**តារាងទី៩៖** ចំនួនអ្នកក្រីក្រនៅក្នុងសេណារីយ៉ូទី២

| បម្រែបម្រួលចំនួនអ្នកក្រីក្របំផុត | | | ចំនួនអ្នកក្រីក្របំផុត | | | |
|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ០ | ៤០០,៥៩៤ | ៤០០,៥៩៤ | ៤០៦,៩៦៩ | ៥៩៩,៣៨០ | ១,៩៤៥,៨៨១ | ២,៣៥២,៨៥១ |

**តារាងទី១០៖** អត្រាភាពទីទាល់ក្រថ្មីនៅក្នុងសេណារីយ៉ូទី២

| អត្រាភាពទីទាល់ក្រ | | | | បម្រែបម្រួលអត្រាភាពទីទាល់ក្រ | | | |
|---|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | ជនបទ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ១៣.៦៦% | ៥៩.៩៤% | ១៦.៧៣% | ១៦.១០% | ០% | -៤០.០៦% | -១៧.០៧% | -១៤.៥៥% |

ភាពខុសគ្នាដាច់ស្រឡះទៅលើចំណុចដៅ នៅក្នុងសេណារីយ៉ូផ្ទេរប្រាក់ គឺថាការប្រើប្រាស់ក្នុងចំនួនប្រហែលជាពាក់កណ្តាល គឺទទួលបានថវិកាពីប្រាក់ចំណូលផ្ទាល់របស់អ្នកទទួលផល ដែលបង្កើតឡើងដោយសកម្មភាពផលិតផ្ទាល់របស់ពួកគេ។ លទ្ធផលនេះ កំពុងតែបង្ហាញឲ្យឃើញយ៉ាងជាក់លាក់នូវផលប៉ះពាល់អំណោយផលនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ៖ ផលប៉ះពាល់ទាំងនេះ ធ្វើឲ្យមានការប្រសើរឡើងនូវប្រាក់ចំណូលរបស់គ្រួសារគោលដៅ ទន្ទឹមនឹងធ្វើឲ្យគ្រួសារគោលដៅចំនួន៤ ក្នុងចំណោម១០គ្រួសារ បានរួចចាកផុតពីភាពទីទាល់ក្រ បន្ទាប់ពីរយៈពេលមួយឆ្នាំ។ ការណ៍នេះ ក៏បានបង្ហាញនូវសក្តានុពលបង្ហូរនៃកម្មវិធីទាំងនេះផងដែរ ដើម្បីជម្រុញឲ្យមានកំណើនក្នុងស្រុក ទន្ទឹមនឹងកាត់បន្ថយនូវភាពទីទាល់ក្រនៅតាមទីជនបទ។ សេណារីយ៉ូខាងក្រោមទាំងនេះ នឹងបង្ហាញនូវទិដ្ឋភាពផ្សេងៗទៀតនៃអត្ថប្រយោជន៍ជាច្រើន នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រដើម្បីលើកកម្ពស់ជីវភាពនៅជនបទ។

### *សេណារីយ៉ូទី៣៖ ការផ្តល់សាច់ប្រាក់ (៥០%) ការផ្តល់ទ្រព្យសម្បត្តិផលិត (៣០%) និងការបណ្តុះបណ្តាលជំនាញ (២០%)*

សេណារីយ៉ូទី៣ ខុសពីសេណារីយ៉ូទី២ នៅត្រង់សមាសភាគមួយ៖ នោះគឺថាទឹកប្រាក់ចំនួន២៥% នៃថវិកាសរុប (T) នៅក្នុងពេលឥឡូវនេះ ត្រូវបានបែងចែកសម្រាប់ការបណ្តុះបណ្តាលជំនាញ ជាជាងការផ្តល់ឲ្យនូវទ្រព្យផលិត។ យើងសន្មតថា សមាសភាគនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រនេះ មានផលប៉ះពាល់ដោយផ្ទាល់ទៅលើផលិតភាពពលកម្មដែលអ្នកទទួលផលប្តេជ្ញា អនុវត្តសកម្មភាពផលិតផ្ទាល់របស់ពួកគាត់ឲ្យបាន។ មានភស្តុតាងតិចតួចណាស់រហូតដល់សព្វថ្ងៃនេះ ទាក់ទងនឹងផលផ្លែពីការវិនិយោគទៅលើធនធានមនុស្សនៅក្នុងបរិបទនៃគំរូបញ្ចប់ភាពទីទាល់ក្រ ប៉ុន្តែខ្លឹមសារ និងទម្រង់ដែលបានគ្រោងទុក ដែលដោយបានផ្តល់ជាមេរៀនប្រចាំសប្តាហ៍ នៅក្នុងការបណ្តុះបណ្តាលជំនាញដល់កសិករ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងកម្មវិធីបណ្តុះបណ្តាលកសិករដែលមានស្រាប់ ដូចជា៖ កម្មវិធី FFS ជាដើម។ ការវាយតម្លៃផលប៉ះពាល់មួយរបស់ Danida (២០១១) បានព្យាករណ៍ទុកថា ផលផ្លែនៃកម្មវិធី FFS នៅក្នុងប្រទេសបង់ក្លាដេស បានធ្វើឲ្យប្រសើរឡើងនូវទិន្នផលផលិតកម្មកសិកម្មចំនួន ១០% នៅក្នុងឆ្នាំដំបូងនៃការអនុវត្ត។ ការសិក្សានេះ ក៏បានប្រើប្រាស់នូវការវិភាគចំណាយ-ផលប្រយោជន៍ និងការព្យាករណ៍ការវាស់វែងផលផ្លែនៃការវិនិយោគ ដើម្បីប៉ាន់ប្រមាណនូវសក្តានុពលផលប៉ះពាល់មកលើផលិតភាពរបស់គ្រួសារកម្ពុជាដែរ។ ការបណ្តុះបណ្តាលលើការរៀបចំគម្រោងថវិកា ចំនួនអ្នកទទួលផលដែលនឹងទទួលបានការបណ្តុះបណ្តាល នៅក្នុងរយៈពេលនៃឆ្នាំអន្តរាគមន៍ និងបច្ចេកវិទ្យាដែលមានស្រាប់ដែលកសិករបានប្រើប្រាស់នៅក្នុងឆ្នាំគោល ត្រូវបានបញ្ជាក់លម្អិត និងយកធ្វើជាគំរូ។ ការអនុវត្តតាមសម្រាប់សេណារីយ៉ូទី៣ ត្រូវបានកំណត់ព្រំដែនវា ដោយផ្អែកលើមូលដ្ឋាននៃការព្យាករណ៍ទាំងនេះ ដោយបានធ្វើការបូកបញ្ចូលគ្នារវាងការបណ្តុះបណ្តាលដែលរួមនឹងការផ្តល់សាច់ប្រាក់ និងទ្រព្យនៅក្នុងចំនួនសមាមាត្រ ដូចបានរៀបរាប់នៅក្នុងតារាងទី៤។ ផលប៉ះពាល់សំខាន់ៗ មកលើសេដ្ឋកិច្ចនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រនេះ មានបង្ហាញនៅក្នុងតារាងទី១១។

លទ្ធផលទាំងនេះ គឺស្រដៀងគ្នាទៅនឹងសេណារីយ៉ូទី២ ដោយឃើញមានការកើនឡើងនូវផលិតកម្មក្នុងស្រុកនៃកសិផល ការបង្វែរទិសដៅពីទីផ្សារនាំចេញមករកទីផ្សារក្នុងស្រុកវិញ និងការកើនឡើងជាមធ្យមនូវការនាំចូលកសិផល ដើម្បីបំពេញនូវតម្រូវការថ្មីៗពីគ្រួសារទទួលផល។ ការផ្តល់ទ្រព្យផលិតបូករួមជាមួយនឹងការលើកកម្ពស់ផលិតភាពរបស់កសិករ ដែលកើតចេញពីសមាសភាគបណ្តុះបណ្តាលនេះ ធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើប្រាក់ចំណូល និងការប្រើប្រាស់របស់អ្នកទីទាល់ក្រ។

ផ្អែកលើការព្យាករណ៍ដែលមានស្រាប់ នៅក្នុងការវិភាគចំណាយ-ផលប្រយោជន៍ ទៅលើការបណ្តុះបណ្តាលជំនាញដល់កសិករក្រីក្រ និងការប្រើប្រាស់ផលប៉ះពាល់ពីសំណាក់កសិករមកលើទិន្នផលនៅក្នុងបរិបទ បើប្រៀបធៀបនឹងការសិក្សានេះ បានរកឃើញថា ផលប៉ះពាល់ពីការវិនិយោគលើធនធានមនុស្សនេះ មកលើសមត្ថភាពផលិតរបស់អ្នកទទួលផល គឺទទួលបានលទ្ធផលមធ្យម ច្រើនជាងការផ្តល់ឲ្យនូវទ្រព្យផលិតនៅក្នុងដំណាក់កាលដំបូង។ យ៉ាងនេះក្តី អាច

លើកជាសម្មិតកម្មបានថា ទោះបីជាធនធានសម្ភារៈរំលស់តម្លៃរបស់វាបន្តិចម្តងៗក្នុងរយៈពេលយូរ ក៏ជំនាញរបស់កសិករទំនងជាប្រសើរឡើងដោយសារការអនុវត្ត និងហាក់ដូចជាមានប្រសិទ្ធភាពយូរអង្វែងថែមទៀតផង។

**តារាងទី១១៖** លទ្ធផលដែលបានជ្រើសរើសពីសេណារីយ៉ូទី៣ ដែលមានបម្រែបម្រួលជាភាគរយ

| ការប្រើប្រាស់ពិតរបស់គ្រួសារ | | | ផលិតកម្មកសិកម្ម | ការនាំចេញកសិកម្ម | សន្ទស្សន៍តម្លៃទំនិញ | ផ.ស.ស ពិត |
|---|---|---|---|---|---|---|
| អ្នកទទួលផល | អ្នកក្រីក្រទាំងអស់ | គ្រួសារទាំងអស់ | ០.៨៧% | -០.២៩% | -០.០៣% | ០.១៦% |
| ១៨.៦% | ៦.០% | ០.៥% | | | | |

ការប្រែប្រួលនានាដែលមាននៅក្នុងសូចនាករភាពទីទាល់ក្រនេះ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងបម្រែបម្រួលដែលកើតចេញពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រនៅក្នុងសេណារីយ៉ូមុន៖ អត្រាភាពទីទាល់ក្រត្រូវបានកាត់បន្ថយប្រមាណជា ១៣.៥% ដែលមានចំនួនតិចជាង ប៉ុន្តែខិតកាន់តែទៅជិតលទ្ធផលដែលទទួលបានពីការផ្តល់ជាប្រាក់សុទ្ធ (តារាងទី១២ និង ទី១៣)។ ការព្យាករណ៍ទាំងនេះ បង្ហាញថា ផលប៉ះពាល់លើសពីពាក់កណ្តាល គឺកើតឡើងដោយសារសមាសភាគមិនមែនសាច់ប្រាក់របស់កញ្ចប់ ហេតុដូច្នេះហើយ វាកើតចេញពីប្រាក់ចំណូលដែលបង្កើតឡើង ដោយសកម្មភាពផលិតនានារបស់អ្នកទទួលផល។

**តារាងទី១២៖** ចំនួនអ្នកក្រីក្រនៅក្នុងសេណារីយ៉ូទី៣

| បម្រែបម្រួលចំនួនអ្នកក្រីក្របំផុត | | | ចំនួនអ្នកក្រីក្របំផុត | | | |
|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ០ | ៣៦៩,៧៦៥ | ៣៦៩,៧៦៥ | ៤០៦,៩៦៩ | ៦៣០,២០៩ | ១,៩៧៦,៧១០ | ២,៣៨៣,៦៧៩ |

**តារាងទី១៣៖** អត្រាភាពទីទាល់ក្រថ្មីនៅក្នុងសេណារីយ៉ូទី៣

| អត្រាភាពទីទាល់ក្រ | | | | បម្រែបម្រួលអត្រាភាពទីទាល់ក្រ | | | |
|---|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | ជនបទ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ១៣.៦៦% | ៦៣.០២% | ១៦.៩៩% | ១៦.៣២% | ០% | -៣៦.៩៨% | -១៥.៧៦% | -១៣.៤៣% |

លទ្ធផលទាំងនេះ គូសបញ្ជាក់ឲ្យឃើញនូវផលប៉ះពាល់ដែលជាចលករនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រដែលអាចមើលឃើញបាន បន្ទាប់ពីឆ្នាំទីមួយនៃការអនុវត្តអន្តរាគមន៍នោះ។ ការវិនិយោគលើមនុស្ស និងលើរូបវ័ន្ត ដែលបានធ្វើឡើងនៅក្នុងអំឡុងឆ្នាំទីមួយនៃការអនុវត្ត នឹងបន្តលើកកម្ពស់សមត្ថភាពផលិតរបស់អ្នកទទួលផលហួសពីជុំទីមួយ នៃការអនុវត្តបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រទៀត។ សំណុំបន្ទាប់ដែលមាននៅក្នុងការអនុវត្តនេះ នឹងបង្ហាញថា ហេតុដូចម្តេចបានជាការពិចារណានេះ ចាំបាច់ត្រូវលើកយកមកពន្យល់នៅក្នុងការវាយតម្លៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ និងនៅក្នុងការវិភាគផលប៉ះពាល់ដល់ផ្នែកសេដ្ឋកិច្ចពេញលេញរបស់វា។

## ការពន្យល់អំពីប្រសិទ្ធភាពរយៈពេលវែងនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ

ខណៈដែលសមាសភាគឧបត្ថម្ភសាច់ប្រាក់ អាចធ្វើឲ្យមានការបំពេញបានភ្លាមៗ នូវតម្រូវការមូលដ្ឋានរបស់គ្រួសារ ការប្រើប្រាស់ស្បៀងអាហារបឋម និងទំនិញសំខាន់ៗ ដែលអាចដោះស្រាយនូវទុរ្ភិក្ស និងលើកកម្ពស់អាហារូបត្ថម្ភគ្រួសារ បាននៅក្នុងរយៈពេលខ្លីនោះ ការបណ្តុះបណ្តាល និងសមាសភាគឧបត្ថម្ភដើមទុន បានគាំទ្រដល់សមត្ថភាពរបស់អ្នកទទួលផលក្នុងការបង្កើតនូវប្រាក់ចំណូលហួសពីឆ្នាំដំបូងនៃកម្មវិធីទៅទៀត។ ទោះបីជាលទ្ធផលនៃការអនុវត្តតាម ផ្តល់នូវការព្យាករណ៍អំពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃអន្តរាគមន៍ទាំងនេះនៅតាមគ្រួសារនីមួយៗ និងនៅក្នុងកម្រិតទីផ្សារក៏ដោយ ក៏លទ្ធផលនេះមិនបានគិតទៅលើប្រសិទ្ធភាពយូរអង្វែងទៅលើសមត្ថភាពរបស់អ្នកទទួលផល ក្នុងការស្វែងរកប្រាក់ចំណូលឡើយ និងខិតកាន់តែទៅជិតបន្ទាត់នៃភាពទីទាល់ក្រធ្ងន់ធ្ងរ។ សម្រាប់មូលហេតុនេះ អ្នកស្រាវជ្រាវបានដាក់ឲ្យដំណើរការសំណុំទី២ នៃការអនុវត្តដែលមានគោលដៅព្យាករណ៍ទៅលើផលប៉ះពាល់ពីសមាសភាគមិនមែនថវិកានៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រនៅក្នុងរយៈពេលវែង។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា ការផ្តល់ដើមទុន (ធនធាន) នៅក្នុងសេណារីយ៉ូពីមុន បានរំលស់តម្លៃ១០% បន្ទាប់ពីឆ្នាំទីមួយនៃការផ្តល់ឲ្យ ការសន្មតបែបអភិរក្សបំផុតសម្រាប់ទ្រព្យប្រភេទនេះ ជាពិសេសសម្រាប់បសុសត្វ ដែលតម្លៃរបស់វាអាចកើនឡើងវិញ ដែលជំនួសបាន នៅពេលដែលសត្វគោក្របីធំឡើង។ មួយវិញទៀត សម្រាប់ផ្នែកធនធានមនុស្ស យើងពិចារណាថា ផលចំណេញជាផលិតភាពដែលទទួលបានពីការបណ្តុះបណ្តាលជំនាញនៅតែបន្តមានជាដដែល នៅក្នុងឆ្នាំបន្ទាប់ពីការអនុវត្តកម្មវិធី។ នេះក៏ជាការសន្មតមធ្យមបំផុតដែរ ដោយសារការអនុវត្តវាជួយពង្រឹងជំនាញរបស់កសិករ តាមរយៈ "ការរៀនដោយអនុវត្តជាក់ស្តែង"។

ទោះបីជាសេណារីយ៉ូទាំងពីរនេះ មិនពាក់ព័ន្ធជាមួយនឹងការផ្តល់ថវិកាបន្ថែមណាមួយក៏ដោយ ក៏លទ្ធផលទាំងនេះបង្ហាញនូវប្រសិទ្ធភាពរយៈពេលយូរទៅលើការកាត់បន្ថយភាពទីទាល់ក្រទាំងទៅលើចំនួន និងអត្រា (តារាងទី១៥ និង ទី១៦) និងកំណើនសេដ្ឋកិច្ច (តារាងទី១៤) ដែលកើតចេញពីផលប៉ះពាល់រយៈពេលយូរនៃមនុស្ស និងការផ្តល់ធនធានសម្ភារៈជាមួយនឹងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រទាំងនេះ។

បើមើលពីទិដ្ឋភាពផ្នែកសេដ្ឋកិច្ច ទ្រព្យផលិតទាំងនោះទំនងជាបង្កើតឲ្យមានផលប៉ះពាល់យ៉ាងធំធេងមកលើផលិតកម្មកសិកម្ម រហូតដល់កម្រិតមួយដែលថាកំណើន០.១៦% នៅក្នុង ផ.ស.ស អាចកំណត់បានថាអាចកើតឡើង ដោយសារប្រសិទ្ធភាពនៃកម្មវិធីនេះប៉ុណ្ណោះ នៅក្នុងឆ្នាំក្រោយពីការអនុវត្ត។ ផលប៉ះពាល់ពីការបណ្តុះបណ្តាលជំនាញទៅលើសេណារីយ៉ូទាំងពីរ គឺមានចំនួនលើសពីមធ្យមបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែទំនងជាមានប្រសិទ្ធភាពច្រើនជាងបន្តិចម្តងៗក្នុងរយៈពេលយូរ។

**តារាងទី១៤៖** លទ្ធផលដែលបានជ្រើសរើសពីសេណារីយ៉ូទី៤ និង ទី៥ ដែលមានបម្រែបម្រួលជាភាគរយ

| សេណារីយ៉ូ | ការប្រើប្រាស់ពិតរបស់គ្រួសារ | | | ផលិតកម្មកសិកម្ម | ការនាំចេញកសិកម្ម | សន្ទស្សន៍តម្លៃទំនិញ | ផ.ស.ស ពិត |
|---|---|---|---|---|---|---|---|
| | អ្នកទទួលផល | អ្នកក្រីក្រទាំងអស់ | គ្រួសារទាំងអស់ | | | | |
| សេណារីយ៉ូទី៤ | ៧.៣% | ២.៤% | ០.៣% | ០.៧៦% | ០.៩៧% | -០.០៩% | ០.២២% |
| សេណារីយ៉ូទី៥ | ៥.៤% | ១.៨% | ០.២% | ០.៥៥% | ០.៩២% | -០.០៦% | ០.១៦% |

ប្រសិនបើ ផលប៉ះពាល់ទៅលើការកាត់បន្ថយភាពទីទាល់ក្រនៅក្នុងឆ្នាំទីមួយ និងទីពីរ នៃជុំអនុវត្តន៍ដែលមានតែមួយនោះបានកើនឡើង នោះប្រសិទ្ធភាពនៃគំរូបញ្ចប់ភាពទីទាល់ក្រនេះ នឹងមានចំនួនលើសពីប្រសិទ្ធភាពនៃចំណុចដៅ នៅក្នុងអន្តរាគមន៍ផ្តល់សាច់ប្រាក់ធម្មតាទៅទៀត (ក្រាហ្វទី៣)។

**តារាងទី១៥៖** ចំនួនអ្នកក្រីក្រនៅក្នុងសេណារីយ៉ូទី៤ និងទី៥

| សេណារីយ៉ូ | បម្រែបម្រួលចំនួនអ្នកក្រីក្របំផុត | | | ចំនួនអ្នកក្រីក្របំផុត | | | |
|---|---|---|---|---|---|---|---|
| | ទីក្រុង | គោលដៅ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| សេណារីយ៉ូទី៤ | 0 | ១៦៦,៨៧០ | ១៦៦,៨៧០ | ៤០៦,៩៦៩ | ៨៣៣,១០៤ | ២,១៧៩,៦០៥ | ២,៥៨៦,៥៧៤ |
| សេណារីយ៉ូទី៥ | 0 | ១៣២,៤៦៩ | ១៣២,៤៦៩ | ៤០៦,៩៦៩ | ៨៦៧,៥០៥ | ២,២១៤,០០៧ | ២,៦២០,៩៧៦ |

**តារាងទី១៦៖** អត្រាភាពទីទាល់ក្រថ្មីនៅក្នុងសេណារីយ៉ូទី៤ និង ទី៥

| សេណារីយ៉ូ | អត្រាភាពទីទាល់ក្រ | | | | បម្រែបម្រួលអត្រានៃភាពទីទាល់ក្រ | | | |
|---|---|---|---|---|---|---|---|---|
| | ទីក្រុង | គោលដៅ | ជនបទ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| សេណារីយ៉ូទី ៤ | ១៣.៦៦% | ៨៣.៣១% | ១៨.៧៤% | ១៧.៧០% | 0.00% | -១៦.៦៩% | -៧.១១% | ៦.០៦% |
| សេណារីយ៉ូទី ៥ | ១៣.៦៦% | ៨៦.៧៥% | ១៩.០៣% | ១៧.៩៤% | 0% | -១៣.២៥% | -៥.៦៥% | ៤.៨១% |

ទោះបីជាតម្លៃនៃទ្រព្យសម្បត្តិផលិតដែលបានផ្តល់ឲ្យនោះ ទំនងជារំលស់តម្លៃតាមពេលវេលាក៏ដោយ ក៏ផលប៉ះពាល់មកលើសមត្ថភាពរបស់គ្រួសារទទួលផល ក្នុងការបង្កើតនូវប្រាក់ចំណូលផ្ទាល់របស់ពួកគេ គឺទំនងជាមានប្រសិទ្ធភាពយូរជាងពីរឆ្នាំបើពិចារណានៅទីនេះ។ ពាក់ព័ន្ធនឹងការធ្វើឲ្យប្រសើរនូវធនធានមនុស្សតាមរយៈជំនាញ និងផលិតភាពនោះ ប្រសិទ្ធភាពទាំងនេះ គឺជាក់ស្តែងទំនងជាកើនឡើងជាលំដាប់បន្តិចម្តងៗក្នុងរយៈពេលយូរ។ ការពន្យល់អំពីផលប៉ះពាល់ដែលនៅបន្តរយៈពេល ដែលកើតចេញពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រទាំងនេះ គឺមានសារសំខាន់ណាស់សម្រាប់ចាប់យកអត្ថប្រយោជន៍ប្រៀបធៀបពីអន្តរាគមន៍នានា បើធៀបទៅនឹងវិធានការគាំពារសង្គមធម្មតានោះ។ ចំណាយដើមដំបូងដែលខ្ពស់ជាងនៃអន្តរាគមន៍ទាំងនេះ គួរយកមកពិចារណាទាក់ទងជាមួយនឹងផលប្រយោជន៍របស់វាបន្តិចម្តងៗក្នុងរយៈពេលយូរ។

បើទោះជាបែបនេះក៏ដោយ នៅពេលប្រៀបធៀបផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃអន្តរាគមន៍ខុសៗគ្នាទាំងនេះ នៅក្នុងរយៈពេលយូរ នោះគួរកត់សម្គាល់ផងដែរថា ប្រសិទ្ធភាពរយៈពេលយូរនៃការផ្តល់សាច់ប្រាក់មកលើការសិក្សារបស់កុមារ មិនអាចកត់ត្រាបាននៅក្នុងគំរូរបស់យើងទេ ដោយសារតែក្របខ័ណ្ឌពេលវេលា។ ទោះបីជាការផ្តល់សាច់ប្រាក់ទំនងជាបង្កើននូវតម្រូវការ និងការប្រើប្រាស់នូវសេវាអប់រំដោយគ្រួសារទទួលផលក៏ដោយ ក៏ប្រសិទ្ធភាពយូរអង្វែងនៃការវិនិយោគទៅលើធនធានមនុស្សនេះ មិនអាចយកមកបូកសរុបបាននៅក្នុងក្របខ័ណ្ឌរបស់យើងដែរ។ ហេតុដូច្នេះហើយ ផលប៉ះពាល់របស់វាទៅលើប្រាក់ចំណូលក្នុងពេលខាងមុខ ផលិតភាព និងការងារមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការប្រៀបធៀបរវាងលទ្ធផលនៃការអនុវត្តតាម ជាមួយនឹងការវិភាគថ្លឹងថ្លែង។ យ៉ាងនេះក្តីប្រសិនបើអន្តរាគមន៍បញ្ចប់ភាពទីទាល់ក្រ បង្កើននូវប្រាក់ចំណូល និងលទ្ធភាពការប្រើប្រាស់ ចំពោះវិសាលភាពដែលបានព្យាករណ៍ នោះផលប៉ះពាល់នៃអន្តរាគមន៍ទាំងនោះមកលើការសិក្សា និងការវិនិយោគមកលើធនធានមនុស្ស គឺទំនងជាត់ទិសដៅខិតជិតចូលដូចផលប៉ះពាល់ទាំងឡាយ ដែលទទួលបានពីការផ្តល់សាច់ប្រាក់។

**ក្រាហ្វទី៣៖** ចំនួនអ្នកក្រីក្រគោលដៅដែលបានងើបផុតពីភាពទីទាល់ក្រកាលពីឆ្នាំទី១ និង ទី២




ក្រៅពីផលប៉ះពាល់លើភាពទីទាល់ក្រ និងលើកំណើនសេដ្ឋកិច្ច យន្តការបញ្ចប់ភាពទីទាល់ក្រនេះ ក៏នឹងធ្វើឲ្យអ្នកទទួលផល អាចវិញខ្លួនបញ្ចូលទៅក្នុងអន្តរកម្មសង្គម នៅក្នុងសហគមន៍របស់ពួកគេបានដែរ ក្នុងឋានៈជាអ្នកចូលរួមសកម្មនៅក្នុងសេដ្ឋកិច្ចមូលដ្ឋាន។ ទោះបីមិនស្ថិតនៅក្នុងវិសាលភាពនៃការសិក្សានេះក៏ដោយ ក៏ផលប៉ះពាល់មកលើសង្គមនេះ ត្រូវដាក់បញ្ចូលទៅក្នុងការពន្យល់អំពី ផលប្រយោជន៍នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដូចដែលបានរៀបរាប់ពីខាងលើ។

### *ការបំពេញឲ្យគ្នារវាងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ និងគោលនយោបាយអភិវឌ្ឍន៍ជនបទ*

សក្តានុពលនៃកំណើនកសិកម្មសម្រាប់ការកាត់បន្ថយភាពទីទាល់ក្រនៅក្នុងប្រទេសកម្ពុជា បានបង្ហាញថាមានចំនួនយ៉ាងច្រើនចាប់តាំងពីឆ្នាំ២០០២ ហើយត្រូវបានកត់ត្រាទុកជាឯកសារយ៉ាងទូលំទូលាយ និងទទួលស្គាល់ដោយភាគីពាក់ព័ន្ធ និងអ្នកវិភាគគោលនយោបាយ។ ខណៈដែលអត្រានៃភាពទីទាល់ក្រត្រូវបានព្យាករណ៍ថា បានថយចុះពាក់កណ្តាលនៅក្នុងទសវត្សរ៍កន្លងមក នោះការថយចុះ៦០% នេះត្រូវបានគេគិតថាកើតចេញភាគច្រើនពីកំណើននៃវិស័យកសិកម្ម ដែលតាមរយៈការលើកកម្ពស់លទ្ធភាពចំណេញ កម្រិតប្រាក់ចំណេញ ការងារ ប្រាក់ឈ្នួល និងឱកាសពាណិជ្ជកម្មក្នុងតំបន់ (ធនាគារពិភពលោក ២០១៥)។ ដូច្នេះហើយ វាហាក់ដូចជាថា អន្តរាគមន៍កាត់បន្ថយភាពទីទាល់ក្រ និងគោលនយោបាយនានា ដែលគាំទ្រដល់កំណើនកសិកម្ម នឹងបំពេញឲ្យគ្នាទៅវិញទៅមកនៅក្នុងការលើកកម្ពស់ជីវភាពជនបទ។ សេណារីយ៉ូទី៦ និង ទី៧ អង្កេតទៅលើភាពបំពេញឲ្យគ្នារវាងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ និងគោល-នយោបាយកំណើនកសិកម្ម នៅពេលដែលដាក់ឲ្យអនុវត្តដំណាលគ្នា។

### *សេណារីយ៉ូទី៦៖ ការផ្តល់សាច់ប្រាក់ (៤០%) ការផ្តល់ទ្រព្យផលិត (៤០%) និង ការវិនិយោគសាធារណៈទៅលើផ្លូវថ្នល់ (២០%)*

សេណារីយ៉ូទី៦ ផ្តោតទៅលើការអភិវឌ្ឍផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើម្បីផ្តល់នូវលក្ខខណ្ឌអំណោយផលដល់ការធ្វើពាណិជ្ជកម្មក្នុងស្រុក និងលើកកម្ពស់ការធ្វើសមាហរណកម្មទីផ្សារជនបទទៅក្នុងសេដ្ឋកិច្ចកម្ពុជា។ កង្វះផ្លូវជនបទ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន បានរារាំងដល់មុខងារនៃទីផ្សារជនបទ និងទប់មិនឲ្យមាននិយ័តកម្មតម្លៃ ជាពិសេសរវាងខេត្តដែលមានអតិរេកផលិតកម្មកសិកម្ម និងខេត្តដែលមានឱនភាពផលិតកម្មកសិកម្ម។ កង្វះនេះក៏បានបន្ទុចបង្អាក់ដល់ការធ្វើសមាហរណកម្មទីផ្សារជនបទ ទៅក្នុងសេដ្ឋកិច្ចក្នុងស្រុក និងការធ្វើពាណិជ្ជកម្មក្នុងតំបន់ផងដែរ (ធនាគារពិភពលោក ឆ្នាំ២០១៥)។ កង្វះហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទ ក៏រាប់បញ្ចូលចំណាយដឹកជញ្ជូនខ្ពស់នៅក្នុងប្រទេសកម្ពុជាផងដែរ ដូចបរិយាយលម្អិតនៅក្នុងតារាងទី១៧ ដែលបានធ្វើការប្រៀបធៀបក្នុងតំបន់ជាមួយនឹងប្រទេសវៀតណាម និងប្រទេសថៃ។ យោងតាមការអង្កេតរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទៅលើឃុំចំនួន១៨ នៅក្នុងខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តតាកែវ បានឲ្យដឹងថា មានតែឃុំចំនួនមួយប៉ុណ្ណោះ ដែលមានផ្លូវចាក់កៅស៊ូ នៅក្នុងឆ្នាំ២០១៣ (ADB ២០១៤a)។

**តារាងទី១៧៖** ចំណាយដឹកជញ្ជូនផ្លូវគោកនៅក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាង គិតជា ១០០ដុល្លារ/គីឡូម៉ែត/តោន




*ប្រភព៖ ធនាគារពិភពលោក (ឆ្នាំ២០១៥)*

សេណារីយ៉ូទី៦ បរិយាយអំពីការបញ្ចូលគ្នារវាងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ក" ជាមួយនឹងអន្តរាគមន៍សាធារណៈ ដែលមានការវិនិយោគទៅលើផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។ ថវិកាសរុបត្រូវបានបែងចែករវាងវិធានការទាំងពីរដាច់ដោយឡែកពីគ្នានេះ គឺក្នុងអត្រា ៨០/២០។ មានការស្រាវជ្រាវជាទ្រង់ទ្រាយធំតាមបែបទ្រឹស្តី និងតាមបែបពិសោធន៍ជាក់ស្តែងអំពីផលប៉ះពាល់នៃការវិនិយោគសាធារណៈទៅលើសេដ្ឋកិច្ច។ នៅក្នុងអត្ថបទសិក្ខាសាលាមួយ Aschauer (ឆ្នាំ១៩៨៩) បានអង្កេតទៅលើផលចំណេញផ្នែកផលិតភាពពីការវិនិយោគសាធារណៈបែបនេះ នៅក្នុងសហរដ្ឋអាមេរិករវាងឆ្នាំ១៩៥០ និងឆ្នាំ១៩៨៥ ដែលគាត់បានព្យាករណ៍ថាមានចំនួនច្រើនទៅលើកត្តាផលិតភាពសរុបជាតិ (TFP)។ Anderson និងអ្នកស្រាវជ្រាវផ្សេងទៀត (២០០៦) បានពិនិត្យមើលវិធីសាស្ត្រស្រាវជ្រាវ និងលទ្ធផលពីការស្រាវជ្រាវទៅលើប្រធានបទនេះ ដោយបានគូសបញ្ជាក់នូវផលប៉ះពាល់វិជ្ជមាន និងសំខាន់ៗ នៃប្រភេទការវិនិយោគសាធារណៈនេះមកលើ TFP នៅក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច។ នៅក្នុងសេណារីយ៉ូនេះ យើងអាចសន្នតថា ការវិនិយោគសាធារណៈទៅលើផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ពិតជាបានលើកកម្ពស់ TFP នៅក្នុងវិស័យពាណិជ្ជកម្ម និងការដឹកជញ្ជូន ជាមួយនឹងផ្លែផលពីការវិនិយោគនេះ មានចំនួនស្មើនឹង០.២។ ការសន្នតនេះ មានលក្ខណៈមធ្យមបើធៀបទៅនឹងអត្ថបទស្រាវជ្រាវដទៃទៀត ដែលបានបោះពុម្ពនៅក្រោមមូលហេតុចំនួនបី៖

- ទីមួយ៖ ការសិក្សានេះយល់ឃើញថាការធ្វើពាណិជ្ជកម្ម និងវិស័យដឹកជញ្ជូនតែមួយមុខ ទទួលបានផលប្រយោជន៍ពីការកើនឡើងនូវផលិតភាព ដែលកើតចេញពីអន្តរាគមន៍វិនិយោគសាធារណៈនេះ។
- ទីពីរ៖ ការកំណត់តម្លៃបែបបុរាណបំផុតទៅលើផ្លែផលពីការវិនិយោគ ត្រូវបានយកមកប្រើប្រាស់ បើធៀបទៅនឹងលទ្ធផលនានា ដែលផ្អែកលើការពិសោធន៍ (ដូចជា Anderson រួមនឹងអ្នកស្រាវជ្រាវផ្សេងទៀត ឆ្នាំ២០០៦)។
- ទីបី៖ កម្រិតទាប និងនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍផ្លូវថ្នល់ និងបណ្តាញដឹកជញ្ជូននៅក្នុងប្រទេសកម្ពុជា បានបង្ហាញថាផ្លែផលទទួលបាន គឺស្ថិតនៅក្នុងកម្រិតខ្ពស់ជាងនៅក្នុងការព្យាករណ៍ដែលមានស្រាប់នេះ ជាពិសេសបើប្រៀបធៀបជាមួយនឹងក្រុមប្រទេសដែលបានសិក្សានៅក្នុងអត្ថបទស្រាវជ្រាវដែលបានបោះពុម្ពដែរនោះ។

តារាងទី១៨ បង្ហាញអំពីលទ្ធផលមួយចំនួននៅក្នុងចំណោមលទ្ធផលសំខាន់ៗពីសេណារីយ៉ូទី៦។ ការតភ្ជាប់ទៅកាន់ទីផ្សារ និងការកាត់បន្ថយចំណាយដឹកជញ្ជូន បានផ្តល់នូវអត្ថប្រយោជន៍ដល់វិស័យជាច្រើននៅក្នុងសេដ្ឋកិច្ច ជួយសម្របសម្រួលពាណិជ្ជកម្មក្នុងស្រុក និងតំបន់ និងសម្រាលនូវសំពាធអតិផរណា និងកម្រិតការកើនឡើងនៃសន្ទស្សន៍តម្លៃទំនិញ (CPI)។ នៅក្រោមសេណារីយ៉ូនេះ ការប្រើប្រាស់របស់គ្រួសារនៅទីជនបទ និងទីក្រុង បានទទួលអត្ថប្រយោជន៍ពីសមត្ថភាពប្រសើរឡើងនៃវិស័យកសិកម្ម ដែលវាកើតចេញពីសមាសភាគផ្តល់ទ្រព្យផលិត នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ (តារាងទី១៩ និង ទី២០)។

**តារាងទី១៨៖** លទ្ធផលដែលបានស្រង់ចេញពីសេណារីយ៉ូទី៦ នៅក្នុងបម្រែបម្រួលជាភាគរយ

| ការប្រើប្រាស់ពិតរបស់គ្រួសារ | | | ផលិតកម្មកសិកម្ម | ការនាំចេញកសិកម្ម | សន្ទស្សន៍តម្លៃទំនិញ | ផ.ស.ស ពិត |
|---|---|---|---|---|---|---|
| អ្នកទទួលផល | អ្នកក្រីក្រទាំងអស់ | គ្រួសារទាំងអស់ | ០.៨១% | -០.០៤% | ០.០០% | ០.២២% |
| ១៧.៨% | ៥.៨% | ០.៦% | | | | |

ការរួមបញ្ចូលគ្នាបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រជាមួយនឹងការវិនិយោគសាធារណៈនេះ ទំនងជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពមួយ ក្នុងការគាំទ្រដំណាលគ្នាដល់តម្រូវការ និងការផ្គត់ផ្គង់នៅតាមតំបន់ទីទាល់ក្របំផុតនៅក្នុងប្រទេសកម្ពុជា។ ការបំពេញឲ្យគ្នាទៅវិញទៅមកនូវយុទ្ធសាស្ត្រអភិវឌ្ឍជនបទទាំងពីរសំណុំនេះ នឹងនាំឲ្យមានការរួមបញ្ចូលគ្នាខ្លាំង ទៅលើការកាត់បន្ថយភាពទីទាល់ក្រ និងកំណើនសេដ្ឋកិច្ច ដោយមានលទ្ធផលអាចប្រៀបធៀបបានទៅនឹងលទ្ធផល នៅក្នុងសេណារីយ៉ូទី២ (បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រតែមួយ) នៅក្នុងទិដ្ឋភាពទាំងពីរ។

**តារាងទី១៩៖** ចំនួនអ្នកក្រីក្រ នៅក្នុងសេណារីយ៉ូទី៦

| បម្រែបម្រួលចំនួនអ្នកក្រីក្របំផុត | | | ចំនួនអ្នកក្រីក្របំផុត | | | |
|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ២,៣៨៤ | ៣៦០,១៣០ | ៣៦២,៤៧៥ | ៤០៤,៦២៥ | ៦៣៩,៨៤៤ | ១,៩៨៦,៣៤៥ | ២,៣៩០,៩៧០ |

**តារាងទី២០៖** អត្រាភាពទីទាល់ក្រថ្មីនៅក្នុងសេណារីយ៉ូទី៦

| អត្រាភាពទីទាល់ក្រ | | | | បម្រែបម្រួលអត្រាភាពទីទាល់ក្រ | | | |
|---|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | ជនបទ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ១៣.៥៩% | ៦៣.៩៩% | ១៧.០៨% | ១៦.៣៧% | -០.៥៨% | -៣៦.០១% | -១៥.៣៥% | -១៣.១៦% |

***សេណារីយ៉ូទី៧៖ ការផ្តល់សាច់ប្រាក់ (៤០%) ការផ្តល់ទ្រព្យផលិត (៤០%) និង ការវិនិយោគសាធារណៈទៅលើហេដ្ឋារចនាសម្ព័ន្ធកសិកម្ម (២០%)***

សេណារីយ៉ូទី៧ ផ្តោតទៅលើការវិនិយោគសាធារណៈ ដែលគាំទ្រដល់ផលិតភាពកសិកម្ម តាមរយៈទ្រព្យផលិតប្រព័ន្ធគ្រប់គ្រងទឹក និងហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលផលប៉ះពាល់របស់វាបានបង្ហាញថា មានចំនួនយ៉ាងច្រើននៅក្នុងប្រទេសកម្ពុជាក្នុងទសវត្សរ៍កន្លងមក។ ក្នុងឋានៈជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំងបួន ដែលបានកំណត់ថាអាចជួយផ្លាស់ប្តូររចនាសម្ព័ន្ធនៃវិស័យកសិកម្ម នោះការវិនិយោគ

នេះត្រូវបានចាត់ទុកថាមានសារសំខាន់ខ្លាំងណាស់នៅក្នុងការរក្សាបាននូវសមិទ្ធិផលបច្ចុប្បន្នរបស់ប្រទេសកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០១៥)។ សមាសភាគការវិនិយោគសាធារណៈនៃសេណារីយ៉ូនេះ ដើរតាមខ្សែបន្ទាត់ទាំងនេះ ដោយមានបញ្ចូលការវិនិយោគថែមទៀតទៅលើផ្នែកកសិកម្ម ដែលបម្រើឲ្យ "ទំនិញសាធារណៈ" ជាពិសេសតាមរយៈប្រព័ន្ធធារាសាស្ត្រ ការស្តារឡើងវិញនូវប្រព័ន្ធគ្រប់គ្រងទឹក ការផ្សព្វផ្សាយកសិកម្ម ការគ្រប់គ្រងដីជាតិដីដែលវិធានការទាំងអស់នេះមានបរិយាយលម្អិត និងរៀបរាប់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) សម្រាប់ឆ្នាំ២០១៤-២០១៨។

ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក គឺនៅខ្វះខាតខ្លាំងណាស់នៅតាមទីជនបទនៅក្នុងប្រទេសកម្ពុជា ដោយដីបង្កបង្កើនផលត្រឹមតែ៨%ប៉ុណ្ណោះ ត្រូវបានព្យាករណ៍ទុកថា មានទឹកស្រោចស្រពនៅក្នុងរដូវប្រាំង ដែលនេះធ្វើឲ្យផលិតកម្មកសិកម្មពឹងផ្អែកយ៉ាងខ្លាំង ទៅលើការធ្លាក់ភ្លៀងជារៀងរាល់ឆ្នាំ។ អត្រាការមានទឹកសម្រាប់ផ្គត់ផ្គង់ដល់ដីបង្កបង្កើនផលនេះ គឺស្ថិតនៅកម្រិតទាបបំផុតនៅក្នុងទ្វីបអាស៊ី (តារាងទី២១)។

**តារាងទី២១៖** តំបន់ដែលមានធារាសាស្ត្រ និងដីបង្កបង្កើនផលនៅក្នុងទ្វីបអាស៊ី

| ប្រទេស | តំបន់មានទឹកស្រោចស្រពជាក់ស្តែង (ហត) ២០១១-២០១២ | ដីបង្កបង្កើនផល (ហត) ២០១១ | ផ្នែកនៃតំបន់មានទឹកស្រោចស្រពដែលស្ថិតនៅក្នុងដីបង្កបង្កើនផល (%) |
|---|---|---|---|
| កម្ពុជា | ៣១៧,២២៥ | ៤,០០០,០០០ | ៧.៩ |
| ចិន | ៥៤,២១៨,៩៧៦ | ១១១,៥៩៨,៥០០ | ៤៨.៦ |
| ឥណ្ឌូនេស៊ី * | ៦,៧២២,២៩៩ | ២៣,៥០០,០០០ | ២៨.៦ |
| ម៉ាឡេស៊ី * | ៣៤០,៧១៧ | ១,៨០០,០០០ | ១៨.៩ |
| ភូមា * | ២,០៨៣,០០០ | ១០,៧៨៦,០០០ | ១៩.៣ |
| ហ្វីលីពីន * | ១,៨៧៩,០៨៤ | ៥,៤០០,០០០ | ៣៤.៨ |
| កូរ៉េខាងត្បូង | ៨៨០,៤០០ | ១,៤៩២,០០០ | ៥៩.០ |
| ថៃ | ៥,០៥៩,៩១៤ | ១៥,៧៦០,០០០ | ៣២.១ |
| វៀតណាម * | ៤,៥៨៥,៥០០ | ៦,៥០០,០០០ | ៧០.៥ |

*ប្រភព ៖ ធនាគារពិភពលោក ឆ្នាំ២០១៥*

លទ្ធផលពីសេណារីយ៉ូទី៧ គួរឲ្យចាប់អារម្មណ៍ណាស់។ នៅពេលការវិនិយោគបែបនេះ ត្រូវបានបូករួមបញ្ចូលគ្នាជាមួយនឹងបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ "ក" នោះផលិតកម្មកសិកម្មមានការកើនឡើងចំនួន១.៣៥% នៅក្នុងឆ្នាំដំបូងនៃការអនុវត្ត។ ការបង្វែរទិសដៅពីការនាំចេញកសិកម្ម មកបំពេញឲ្យតម្រូវការថ្មីរបស់អ្នកទទួលផល គឺមានកម្រិតជាមធ្យមខ្លាំងជាងសេណារីយ៉ូផ្សេងៗទៀត ដែលមានពីមុនទាំងអស់ ហើយសន្ទស្សន៍តម្លៃទំនិញបានធ្លាក់ចុះចំនួន០.០៩%ទូទាំងសេដ្ឋកិច្ចទាំងអស់ (តារាងទី២២)។ ផ.ស.ស ពិតបានកើនឡើងចំនួន០.៣៥% ដែលនេះបង្ហាញឲ្យឃើញនូវផលផ្លែសំខាន់ៗ ពីការវិនិយោគសាធារណៈនៅទាំងទៅលើទំនិញសាធារណៈ និងទំនិញឯកជន និងមានកម្រិតខ្ពស់បំផុតជាងសេណារីយ៉ូផ្សេងទៀតទាំងអស់។ ការណ៍នេះ បង្ហាញឲ្យឃើញនូវថាមពលផ្គុំគ្នាដ៏រឹងមាំរវាងអន្តរាគមន៍នានា ដែលគាំទ្រវិស័យកសិកម្ម ទាំងនៅក្នុងកម្រិតមីក្រូសេដ្ឋកិច្ច និងទាំងនៅក្នុងទ្រង់ទ្រាយកាន់តែធំជាង តាមរយៈការផ្លាស់ប្តូររចនាសម្ព័ន្ធ។

**តារាងទី២២៖** លទ្ធផលដែលបានស្រង់ចេញពីសេណារីយ៉ូទី៧ ដែលមានបម្រែបម្រួលជាភាគរយ

| ការប្រើប្រាស់ពិតរបស់គ្រួសារ | | | ផលិតកម្ម កសិកម្ម | ការនាំចេញ កសិកម្ម | សន្ទស្សន៍តម្លៃទំនិញ | ផ.ស.ស ពិត |
|---|---|---|---|---|---|---|
| អ្នកទទួលផល | អ្នកក្រីក្រទាំងអស់ | គ្រួសារទាំងអស់ | | | | |
| ១៧.៩% | ៦.០% | ០.៨% | ១.៣៥% | -០.០៨% | -០.០៩% | ០.៣៥% |

កាន់តែគួរឲ្យភ្ញាក់ផ្អើល លទ្ធផលពីការអនុវត្តមខ្នាតតូចនេះ បានបង្ហាញនូវការកាត់បន្ថយភាពទីទាល់ក្របានចំនួន៣៦% នៅក្នុងចំណោមក្រុមគោលដៅ៖ សូចនាករដដែលនោះ បានកើនឡើងប្រមាណជា៣៧%នៅក្នុងសេណារីយ៉ូទី២ ដែលមានគ្រួសារគោលដៅបានទទួលការផ្តល់សាច់ប្រាក់ក្នុងពេលបច្ចុប្បន្នរហូតដល់ពីរដង (តារាងទី២៣ និង ទី២៤)។ ការណ៍នេះ បញ្ជាក់ឲ្យឃើញនូវសក្តានុពលដ៏រឹងមាំនៃការអភិវឌ្ឍជនបទនៅក្នុងប្រទេសកម្ពុជា ដែលជាចលករទាំងសម្រាប់កាត់បន្ថយភាពទីទាល់ក្រផង និងកំណើនម៉ាក្រូសេដ្ឋកិច្ចផង ដូចមានរៀបរាប់នៅក្នុងផ្នែកទី១។

**តារាងទី២៣៖** ចំនួនអ្នកក្រីក្រនៅក្នុងសេណារីយ៉ូទី៧

| បម្រែបម្រួលចំនួនអ្នកទីទាល់ក្រ | | | ចំនួនអ្នកទីទាល់ | | | |
|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ២,៣៤៤ | ៣៦០,១៣០ | ៣៦២,៤៧៥ | ៤០៤,៦២៥ | ៦៣៩,៨៤៤ | ១,៩៨៦,៣៤៥ | ២,៣៩០,៩៧០ |

គួរឲ្យកត់សម្គាល់ អន្តរាគមន៍នេះ ក៏បានបង្កើតឲ្យមានផលទៅដល់អ្នកមិនទទួលផល តាមរយៈការបង្កើននូវផលិតកម្មកសិកម្ម និងការធ្លាក់ចុះនូវសន្ទស្សន៍តម្លៃទំនិញ ហើយជាលទ្ធផល ភាពទីទាល់ក្រនៅទីក្រុងត្រូវបានកាត់បន្ថយចំនួន ០.៦% បន្ទាប់ពីរយៈពេលមួយឆ្នាំនៃការអនុវត្តកម្មវិធី។

**តារាងទី២៤៖** អត្រាភាពទីទាល់ក្រថ្មីនៅក្នុងសេណារីយ៉ូទី៧

| អត្រាភាពទីទាល់ក្រ | | | | បម្រែបម្រួលអត្រាភាពទីទាល់ក្រ | | | |
|---|---|---|---|---|---|---|---|
| ទីក្រុង | គោលដៅ | ជនបទ | សរុប | ទីក្រុង | គោលដៅ | ជនបទ | សរុប |
| ១៣.៥៩% | ៦៣.៩៩% | ១៧.០៨% | ១៦.៣៧% | -០.៥៨% | -៣៦.០១% | -១៥.៣៥% | -១៣.១៦% |

ប្រភេទនៃការវិនិយោគសាធារណៈ ដែលបានអនុវត្តនៅក្នុងសេណារីយ៉ូទី៦ និង ទី៧ មានលក្ខណៈជាក់លាក់របស់វាចំនួនពីរ៖ ទីមួយ ដោយសារចំណាយរបស់វា នោះផលផ្លែនៅក្នុងរយៈពេលយូរ និងសមត្ថភាពស្ថាប័ន ដែលអន្តរាគមន៍នោះតម្រូវឲ្យមានអន្តរាគមន៍ទាំងនោះ អាចផ្តល់ថវិកា និងអាចអនុវត្តបានតែដោយស្ថាប័នសាធារណៈប៉ុណ្ណោះ ដោយយោងតាមនិយមន័យរបស់ទំនិញសាធារណៈ។ អន្តរាគមន៍ទាំងនោះ ទំនងជាផ្តល់ផលប្រយោជន៍ក្នុងរយៈពេលយូរអង្វែងដល់សេដ្ឋកិច្ចសហគមន៍មូលដ្ឋាន និងនៅក្នុងរយៈពេលវែងបង្គួរជាងការវិនិយោគជាឯកជនទូទៅ និងទីពីរ វាជួយធ្វើឲ្យប្រសើរឡើង នូវសុខមាលភាពសាធារណៈគ្រប់ផ្នែកទាំងអស់ ព្រមទាំងផ្តល់នូវផលប្រយោជន៍ច្រើនបំផុត ដល់អ្នកទាំងឡាយណាដែលស្ថិតនៅបាតខាងក្រោម នៃការបែងចែកប្រាក់ចំណូល។ លទ្ធផលរបស់យើង បញ្ជាក់ឲ្យឃើញនូវសក្តានុពលសំខាន់ៗរបស់វា មិនត្រឹមតែសម្រាប់ជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកាត់បន្ថយនូវភាពទីទាល់ក្រផងដែរ

ជាពិសេស នៅពេលច្របាច់រួមបញ្ចូលគ្នាជាមួយនឹងអន្តរាគមន៍នានា ដែលផ្តោតគោលដៅដោយផ្ទាល់ទៅលើអ្នកក្រីក្របំផុត ហើយនិងធ្វើឲ្យពួកគេមានលទ្ធភាពចូលប្រឡូកនៅក្នុងសកម្មភាពផលិតកសិកម្ម។ នៅក្នុងរយៈពេលខ្លី សេណារីយ៉ូទី៦ និងទី៧ បង្កើតបាននូវផលប៉ះពាល់ ប្រកបដោយសក្តានុពលរឹងមាំបំផុតមកលើកំណើនសេដ្ឋកិច្ច។ ដូចជានៅក្នុងករណីនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ("ក" និង "ខ") ជាដើម ផលផ្លែពីការវិនិយោគត្រូវធ្វើការវាយតម្លៃ និងវិភាគនៅក្នុងរយៈពេលយូរអង្វែង ដើម្បីស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីក្តីសង្ឃឹមពេញលេញ សម្រាប់គ្រួសារជនបទនៅប្រទេសកម្ពុជា។ ពាក់ព័ន្ធជាមួយនឹងករណីនៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ វាទំនងថាផលប្រយោជន៍ដែលបង្កឡើងពីកម្មវិធីទាំងនេះ នឹងមានចំនួនលើសពីចំណាយរបស់វា ប៉ុន្តែជាមួយគ្នានេះផងដែរ យើងអាចរំពឹងបានថានឹងមានផលប៉ះពាល់សំខាន់ៗមកលើគន្លងកំណើនកសិកម្មប្រទេសកម្ពុជា ដែលត្រូវការជាចាំបាច់សម្រាប់រក្សាបានការកាត់បន្ថយភាពទីទាល់ក្រ។

## គន្លឹះពិចារណាសំខាន់ៗ និងមធ្យោបាយសម្រាប់ការស្រាវជ្រាវបន្ត

លទ្ធផលនៃអត្ថប្រយោជន៍សក្តានុពល របស់បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រនេះ មានភាពវិជ្ជមាន និងការសន្យាគួរឲ្យកត់សម្គាល់ ប៉ុន្តែតម្រូវឲ្យមានការប្រុងប្រយ័ត្នក្នុងការបកស្រាយអំពីវា។ ទោះបីជាផ្អែកទៅលើទិន្នន័យជាក់លាក់ពីកម្ពុជាដែលយកចេញពីការអង្កេតគ្រួសារនានា ស្ថិតិផ្លូវការ និងគណនីជាតិក៏ដោយ ក៏ការរកឃើញទាំងនេះ ត្រូវបានបង្កើតឡើងដោយលំហាត់អនុវត្តតាម ដែលផ្អែកទៅលើសមាសភាគតែទ្រឹស្តីប៉ុណ្ណោះ។ បើទោះបីជាបែបនេះក្តី លទ្ធផលទាំងនេះ ស្របគ្នាយ៉ាងត្រឹមត្រូវជាមួយនឹងការព្យាការណ៍មីក្រូសេដ្ឋកិច្ច ដែលមានស្រាប់ស្តីពី អត្ថប្រយោជន៍នានានៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ សម្រាប់គ្រួសារដែលរស់នៅក្នុងភាពទីទាល់ក្របំផុតនេះ (Balboni et al., 2015)។ វាក៏បានផ្តល់ឲ្យនូវទស្សនវិស័យអំពីសមតាទូទៅ ទៅលើសក្តានុពលនៃការពង្រីកទំហំអន្តរាគមន៍ប្រភេទនេះ ដើម្បីបង្កើនការចូលរួមរបស់ក្រុមគ្រួសារឲ្យកាន់តែច្រើន នៅទូទាំងប្រទេស។ នេះ គឺជាការវិភាគម៉ាក្រូសេដ្ឋកិច្ចទីមួយនៃអន្តរាគមន៍ប្រភេទនេះ ហើយការរកឃើញនៅក្នុងការវិភាគនេះ បានបង្ហាញឲ្យឃើញនូវផលចែកសំខាន់ៗ ប្រកបដោយសក្តានុពលមកលើសេដ្ឋកិច្ចកម្រិតមូលដ្ឋាន និងសេដ្ឋកិច្ចកម្រិតទូលំទូលាយជាងនេះ រហូតដល់កម្រិតមួយដែលលើសពីការព្យាករណ៍មានស្រាប់ដែលផ្អែកលើពិសោធន៍ ទៅលើប្រសិទ្ធភាពមេគុណនៃអន្តរាគមន៍ឧបត្ថម្ភសាច់ប្រាក់។

ជាការពាក់ព័ន្ធដោយផ្ទាល់ និងមានតម្លៃផងដែរ ក្នុងការបំពេញឲ្យវិធីសាស្រ្តវិភាគនេះ នូវការធ្វើតេស្តតាមរយៈការពិសោធន៍នៅមូលដ្ឋាន និងការសាកល្បង។ ជាដំបូង គឺធ្វើឲ្យមានសុពលភាព និងសម្រាំងសម្មតិកម្មមួយចំនួនរបស់យើងស្តីពីអាកប្បកិរិយាគ្រួសារ និងទីពីរ ធ្វើការវិភាគភាពមិនដំណើរការនៃទីផ្សារ និងភាពជាក់លាក់សេដ្ឋកិច្ច ដោយផ្តល់នូវហេតុផលសមស្រប សម្រាប់ការប្រើប្រាស់ការផ្តល់សាច់ប្រាក់រួមបញ្ចូលជាមួយសម្ភារៈ ធៀបជាមួយនឹងការផ្តល់សាច់ប្រាក់តែមួយមុខគត់ ដែលការផ្តល់ទាំងពីរប្រភេទនេះ មានតម្លៃសមមូលគ្នា។ វាក៏អាចចាត់ទុកថា ជាគោលនយោបាយប្រសើរផងដែរ ក្នុងការអង្កេតថាតើ ផលចំណេញពីបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ ដែលពាក់ព័ន្ធជាមួយនឹងការផ្តល់សាច់ប្រាក់ ធ្វើឲ្យមានភាពលំបាកដល់គ្រួសារ ឬ ធ្វើឲ្យប្រសើរឡើងនូវការបែងចែកប្រាក់ចំណូល។



រូបភាព ៖ ចេង យ៉ុងស្រេង

ផ្នែកទី ៤

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍គោលនយោបាយ

ការសិក្សានេះបានផ្តល់នូវភស្តុតាងផ្អែកលើពិសោធន៍ នូវអត្ថប្រយោជន៍នានា នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រគាំពារសង្គម ដែលពាក់ព័ន្ធជាមួយនឹងកម្មវិធីសំណាញ់សុវត្ថិភាពធម្មតា។ តាមរយៈការបង្កើនធនធានមនុស្ស និងធនធានរូបវន្ត កម្មវិធីទាំងនេះធ្វើឲ្យអ្នកចូលរួមអាចពង្រីកនូវសកម្មភាពផលិតរបស់ពួកគេបាន ហេតុដូច្នេះហើយ ផលិតភាពរបស់ពួកគេអាចបង្កើតបាននូវប្រាក់ចំណូលពីការងារធ្វើដោយខ្លួនឯង និងចូលរួមនៅក្នុងសេដ្ឋកិច្ចមូលដ្ឋាន ក្នុងពេលដែលអាចជួយគ្រួសារក្រីក្រ ឲ្យបំពេញបាននូវសេចក្តីត្រូវការសំខាន់ៗរបស់ពួកគេ។ ជាក់ច្បាស់ជាងនេះទៅទៀតលទ្ធផលបង្ហាញថា ចំណែកសំខាន់ៗនៃចំណូលថ្មីៗ បានមកពីសកម្មភាពផលិតភាពដែលលើកកម្ពស់ដោយកម្មវិធីបញ្ចប់ភាពទីទាល់ក្រ។

នៅក្នុងករណីប្រទេសកម្ពុជា អន្តរាគមន៍ទាំងនេះទំនងជាទទួលបានជោគជ័យ បើគិតទៅលើទិន្នន័យភាពទីទាល់ក្រ និងសក្តានុពលដែលបានរៀបចំយ៉ាងល្អលើការគាំទ្រ ដោយផ្ទាល់ដល់វិស័យកសិកម្ម។ នៅក្នុងពេលដែលអន្តរាគមន៍សំណាញ់សុវត្ថិភាពសង្គមធម្មតា មិនបានបង្ហាញថា អាចជម្រុញកំណើនសេដ្ឋកិច្ចក្នុងស្រុកបានឡើយ ប៉ុន្តែវាល់បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ និងអន្តរាគមន៍ដែលផ្អែកលើការបញ្ចប់ឲ្យបាននូវភាពទីទាល់ក្រនេះ បែរជាសម្រេចបាននូវការជម្រុញឲ្យមានកំណើនទៅវិញ។

ការប្រៀបធៀបរវាងលទ្ធផលពី លំហាត់អនុវត្តតាមនានា បង្ហាញឲ្យឃើញថា កម្មវិធីដែលធ្វើឲ្យមានការកាត់បន្ថយភាពទីទាល់ក្របានខ្ពស់បំផុតនៅក្នុងឆ្នាំទីមួយ គឺការផ្តល់សាច់ប្រាក់សុទ្ធ ប៉ុន្តែវាគឺជាវិធានការដែលមានផលប៉ះពាល់ទាបបំផុត



មកលើកំណើនសេដ្ឋកិច្ចផងដែរ (សេណារីយ៉ូទី១)។ ផ្ទុយមកវិញ គ្រប់សេណារីយ៉ូទាំងអស់ ដែលបានដាក់បញ្ចូលសមាសភាគបញ្ចប់ភាពទីទាល់ក្រ ទំនងជាជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច ឲ្យដល់កម្រិតបង្កើតភាពប្រែប្រួល។ តារាងទី២៥ ពន្យល់លម្អិត អំពីការវិភាគផលចំណេញពីការកាត់បន្ថយចំណាយ ដែលអ្នករៀបចំគោលនយោបាយអាចនឹងជួបប្រទះ នៅពេលតាក់តែងកម្មវិធីគាំពារសង្គមគ្រប់ជ្រុងជ្រោយដែលពឹងផ្អែកលើវិធីសាស្រ្តបញ្ចប់ភាពទីទាល់ក្រ។

**តារាងទី២៥៖** ភាគរយបម្រែបម្រួលនៅក្នុងការកាត់បន្ថយភាពទីទាល់ក្រ និង ផ.ស.ស ពិត នៅគ្រប់សេណារីយ៉ូ




លទ្ធផលនៃលំហាត់អនុវត្តតាម ដែលបានរាយការណ៍នៅទីនេះ បង្ហាញឲ្យឃើញថា ផលប៉ះពាល់មកលើភាពទីទាល់ក្រ និងលើកំណើនសេដ្ឋកិច្ច ទំនងជាមានប្រសិទ្ធភាពហួសពីរយៈពេលអនុវត្តកម្មវិធីទៅទៀត ខណៈដែលប្រសិទ្ធភាពកាតាលីកនៃទ្រព្យផលិត និងការផ្តល់ជំនាញនៅតែបន្តមានយូរអង្វែង បន្ទាប់ពីកម្មវិធីបញ្ចប់។ ការសិក្សានេះ រកឃើញថា នៅក្នុងកម្រិតសមមូលគ្នានៃការផ្តល់ថវិកា ប្រសិទ្ធភាពបង្កើនរបស់វាមកលើ ការកាត់បន្ថយភាពទីទាល់ក្រ នៅក្នុងរយៈពេលពីរឆ្នាំ ទំនងជាមានលើសពីប្រសិទ្ធភាពនៃការផ្តល់សាច់ប្រាក់សុទ្ធ។

លទ្ធផលទាំងនេះ បញ្ជាក់ឲ្យឃើញនូវតម្រូវការក្នុងការយកមកប្រើប្រាស់នូវទស្សនវិស័យរឹងមាំ និងយូរអង្វែងនៅក្នុងការវាយតម្លៃចំណាយ-ផលប្រយោជន៍ និងការវាយតម្លៃផលប៉ះពាល់នៃបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ (Karlan និងអ្នកស្រាវជ្រាវផ្សេងទៀត ២០១៣) ជាពិសេស នៅពេលដែលចំណាយមុនរបស់វា ជាទូទៅខ្ពស់ជាងកម្មវិធីសំណាញ់សុវត្ថិភាពសង្គមធម្មតា។ គម្លាតភាពទីទាល់ក្រ ដែលមានជាទូទៅនៅពេលចាប់ផ្តើមកម្មវិធី គឺទំនងជាជះឥទ្ធិពលយ៉ាងខ្លាំងដល់ផលប៉ះពាល់របស់បណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រមកលើអត្រានៃភាពទីទាល់ក្រ។ ទោះបីជាការជះឥទ្ធិពលនេះ អាចនឹងពិតសម្រាប់កម្មវិធីសំណាញ់សុវត្ថិភាពក៏ដោយ ក៏ផលអមគោលនយោបាយសម្រាប់គំរូបញ្ចប់ភាពទីទាល់ក្រ គួរត្រូវបានទទួលស្គាល់ ព្រោះថាផលអមទាំងនោះអាចជះឥទ្ធិពលដល់ការជ្រើសរើស រវាងចំនួនអ្នកទទួលផល ទំហំការឧបត្ថម្ភដែលអ្នកទទួលផលនីមួយៗត្រូវទទួល និងរយៈពេលនៃកម្មវិធី។ ខណៈដែលអត្រាភាពទីទាល់ក្រ បានធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងសេណារីយ៉ូគំរូ ដែលបានដាក់បញ្ចូលនូវអន្តរាគមន៍បញ្ចប់ភាពទីទាល់ក្រ គឺហាក់ដូចជាបើទោះគម្លាតខិតទៅរកខ្សែបន្ទាត់ភាពទីទាល់ក្រនៃអ្នកចូលរួមទាំងឡាយ នៅមិនអាចទាន់បញ្ចប់ភាពទីទាល់ក្របាន បន្ទាប់ពីរយៈពេលមួយឆ្នាំក៏ដោយ ក៏យើងឃើញមានការកាត់បន្ថយអត្រាក្រីក្រយ៉ាងឆាប់រហ័សដែរ។ ឆ្នាំបន្តៗទៀតនៃការចូលរួមនៅក្នុងកម្មវិធី អាចនឹងជម្រុញឲ្យមានផលប៉ះពាល់មកលើភាពទីទាល់ក្រកាន់តែខ្ពស់ បើធៀបទៅនឹងឆ្នាំដំបូងនៃកម្មវិធី។ ហេតុដូច្នេះហើយ វាមិនមែនមានតែអត្រានៃភាពទីទាល់ក្រដំបូង ដែលត្រូវទទួលខុសត្រូវ នៅក្នុងការរៀបចំគោលនយោបាយប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងទៅលើគម្លាត (ចម្ងាយ) រវាងគ្រួសារក្រីក្រជាមួយនឹងបន្ទាត់នៃភាពទីទាល់ក្រផងដែរ។

ខណៈដែលបណ្តុំយន្តការបញ្ចប់ភាពទីទាល់ក្រ អាចដោះស្រាយដោយផ្ទាល់នូវកំហិតផ្នែកសេដ្ឋកិច្ច និងសង្គមមួយចំនួន ដែលប្រឈមដោយអ្នកទាំងឡាយណា ដែលអាចចូលរួមធ្វើសកម្មភាពផលិតបាន នោះក៏គួរយកចិត្តទុកដាក់ផងដែរថា វានៅតែត្រូវការសំណាញ់សុវត្ថិភាពសង្គមជានិច្ច សម្រាប់អ្នកទាំងឡាយណា (ដូចជាមនុស្សចាស់ កុមារ និងជនពិការ) ដែលមិនអាចចូលរួមធ្វើសកម្មភាពផលិតបាន។ លទ្ធផលរបស់យើង បង្ហាញថាការផ្តល់ទ្រព្យផលិត អាចនាំមកនូវផលចំណេញខាងការប្រើប្រាស់កាន់តែច្រើនសម្រាប់គ្រួសារក្រីក្របំផុត ដូច្នេះហើយគួរចាត់ទុកវាជាអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព នៅក្នុងការរៀបចំកិច្ចគាំពារសង្គមគ្រប់ជ្រុងជ្រោយមួយ។

វាក៏សំខាន់ផងដែរក្នុងការគូសបញ្ជាក់ថា ការអនុវត្តដោយជោគជ័យនូវកម្មវិធីបញ្ចប់ភាពទីទាល់ក្របែបនេះ តែងតែតម្រូវឲ្យមាននូវការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងសមត្ថភាពរដ្ឋបាលរបស់ប្រទេសកម្ពុជា ប្រសិនបើមិនអាចរៀបចំរចនាសម្ព័ន្ធឡើងវិញទាំងស្រុងនោះទេ។ ខណៈដែលបញ្ហាទាំងនេះ វាហួសពីវិសាលភាពនៃការសិក្សានេះក៏ដោយ ក៏គួរធ្វើការកត់សម្គាល់ផងដែរថា ការផ្តល់ទ្រព្យផលិតទំនងជាមានសមាសភាគកញ្ចប់ជំនួយដែលធ្វើឡើងដោយមិនត្រង់ប៉ុន្មានទេ ជាពិសេសចំពោះអ្នកចាត់ចែង។ មធ្យោបាយមួយ ដើម្បីសម្របសម្រួល និងកាត់បន្ថយចំណាយនៃវិធានការនេះ គឺការឲ្យរដ្ឋាភិបាលអនុវត្តនូវផែនការមួយ ដែលផ្តល់ឲ្យអ្នកចូលរួមកម្មវិធីនូវការទទួលបានថវិកាសម្រាប់ការវិនិយោគរបស់ពួកគេ។ ភាពចាំបាច់នៃគោលនយោបាយទាំងនេះ និងជម្រើសនានា សម្រាប់អនុវត្តតម្រូវឲ្យមានការវិភាគ និងការស្រាវជ្រាវបន្ថែមទៀត។ ឯកសារនេះ បង្ហាញថា ក្តីសង្ឃឹម និងលទ្ធភាពក្នុងការបញ្ចូលវិធីសាស្ត្របញ្ចប់ភាពទីទាល់ក្រ ទៅក្នុងកម្មវិធីសំណាញ់សុវត្ថិភាពរបស់ប្រទេសកម្ពុជា គឺមានចំនួនច្រើន និងថាប្រកបដោយជោគជ័យទៀតផង។ ការបញ្ចូលវាទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជនបទ អាចកាន់តែសំខាន់ទៅទៀត បើមើលទៅលើថាមពលផ្តុំគ្នា និងប្រសិទ្ធភាពទ្វេរគុណ ដែលបានកំណត់នៅក្នុងការសិក្សានេះ។

ការដាក់ឲ្យអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPPF) និងការពង្រីកការអនុវត្តដែលពាក់ព័ន្ធនៅពេលធនធានមាន និងនៅក្នុងប្រព័ន្ធគាំពារសង្គម ធ្វើឲ្យការរកឃើញទាំងអស់ពីការសិក្សានេះ កាន់តែជាប់ពាក់ព័ន្ធជាមួយនឹងអ្នករៀបចំគោលនយោបាយ។ NSPPF ផ្តល់នូវឱកាសនៅក្នុងរយៈពេលខ្លី សម្រាប់ការធ្វើតេស្តនៅតាមមូលដ្ឋាន (ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍) និងនៅក្នុងរយៈពេលវែង តាមរយៈការដាក់ឲ្យដំណើរការកញ្ចប់ជំនួយដែលផ្អែកលើការញ្ចប់ភាពទីទាល់ក្រ ជាសមាសភាគគន្លឹះមួយនៃប្រព័ន្ធនៅពេលខាងមុខ៕



# គន្ថនិទ្ទេស


Anderson, E., de Renzio, P. and Levy, S., តួនាទីនៃការវិនិយោគសាធារណៈនៅក្នុងការកាត់បន្ថយភាពទីទាល់ក្រ៖ ទ្រឹស្តី ភស្តុតាង និងវិធីសាស្ត្រ, វិទ្យាស្ថានអភិវឌ្ឍក្រៅប្រទេស (ODI), ក្រុងឡុងដ៍ ប្រទេសអង់គ្លេស, ឆ្នាំ២០០៦, ទំព័រ២៦៣។

Aschauer, D., តើចំណាយសាធារណៈធ្វើឲ្យមានការផលិតដែរឬទេ? ទិន្នានុប្បវត្តិសេដ្ឋកិច្ចរូបិយវត្ថុ Elsevier, ខែមិនា ឆ្នាំ១៩៨៩, លេខ ២៣(២), ទំព័រ ១៧៧-២០០។

ធនាគារអភិវឌ្ឍន៍អាស៊ី, ការវិភាគភាពទីទាល់ក្ររបស់ប្រទេសកម្ពុជា, ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ២០១២។

Balboni, C., Bandiera, O., Burgess, R., & Kaul, U. (2015). ការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចរបស់ជនទីទាល់ក្រ IGC Growth Brief Series 004. London

Banerjee A., Duflo E., Goldberg N., Karlan D., Osei R., Parienté W., Shapiro J., Thuysbaert B. and Udry, C., កម្មវិធីដែលមានមុខព្រួញច្រើនដែលបណ្តាលឲ្យមានវឌ្ឍនភាពយូរអង្វែងសម្រាប់អ្នកក្រីក្របផុត៖ ភស្តុតាងពីប្រទេសចំនួនប្រាំមួយ, វិទ្យាសាស្ត្រ ៣៤៨ (៦២៣៦), ១២៦០៧៩៩, ឆ្នាំ២០១៥។

Blattman, C., Fiala, N., Martinez, S., ការបង្កើតការងារផ្ទាល់ខ្លួនដែលជាការងារជំនាញនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍៖ ភស្តុតាងពិសោធន៍ពីប្រទេសអ៊ូហ្គង់ដា, ទិន្នានុប្បវត្តិប្រចាំត្រីមាសស្តីពីសេដ្ឋកិច្ចលេខ ១២៩, ឆ្នាំ២០១៤, ទំព័រ៦៩៧–៧៥២។

Danida, ការវាយតម្លៃវិធីសាស្ត្រសាលាកសិករនៅក្នុងការគាំទ្រកម្មវិធីវិស័យកសិកម្មដំណាក់កាល ॥ ប្រទេសបង់ក្លាដេស, ក្រសួងការបរទេសដាណឺម៉ាក, ខែមិថុនា ឆ្នាំ២០១១។

Davis, B., and Handa, S., តើកម្មវិធីត្រូវចំណាយថវិកាអស់ប៉ុន្មាន? ទំហំនៃការផ្តល់ធនធាននៅក្នុងកម្មវិធីផ្តល់សាច់ប្រាក់ថ្នាក់ជាតិដែលបានសម្រាំងនៅក្នុងប្រទេសអាហ្វ្រិក, សេចក្តីសង្ខេបនៃការស្រាវជ្រាវគម្រោងផ្ទេរធនធាន, Chapel Hill, NC៖ មជ្ឈមណ្ឌលប្រជាសាស្ត្រដ្ឋការ៉ូឡាយណា, UNC-Chapel Hill, ឆ្នាំ២០១៥។

Haughton, J. and Khandker, S., សៀវភៅយោង ស្តីពី ភាពទីទាល់ក្រ និងវិសមភាព, ការបោះពុម្ពផ្សាយរបស់ធនាគារពិភពលោក, ធនាគារពិភពលោក, ក្រុងវ៉ាស៊ីនតោន D.C., លេខ ១១៩៨៥, ឆ្នាំ២០០៩។

Karlan, D. and Thuysbaert B., ការផ្តោតគោលដៅទៅលើគ្រួសារក្រីក្របំផុតនៅក្នុងប្រទេសហុងឌុយ ប្រទេសហ្គាស់ និងប្រទេសប៉េរូ, ឯកសារស្រាវជ្រាវ NBER លេខ ១៩៦៤៦, ខែវិច្ឆិកា ឆ្នាំ២០១៣។

Levy, S. and Robinson, S., តើការផ្តល់សាច់ប្រាក់អាចជម្រុញឲ្យមានសេដ្ឋកិច្ចមូលដ្ឋានបានដែរឬទេ? ករណីសិក្សារបស់ប្រទេសកម្ពុជា, ឯកសារពិគ្រោះ IFPRI លេខ ១៣៣៤, ក្រុងវ៉ាស៊ីនតោន DC, វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ, ឆ្នាំ២០១៤។

ក្រសួងផែនការ (MOP), ភាពទីទាល់ក្រនៅក្នុងប្រទេសកម្ពុជា៖ វិធីសាស្ត្រថ្មី, ភ្នំពេញ, រាជរដ្ឋាភិបាលកម្ពុជា, ខែមេសា ឆ្នាំ២០១៣។

ការព្យាករណ៍ភាពទីទាល់ក្រនៅក្នុងឆ្នាំ២០១២ នៅក្នុងប្រទេសកម្ពុជា, អគ្គនាយកដ្ឋានផែនការ, ខែមេសា ឆ្នាំ២០១៤។

http://www.mop.gov.kh/Projects/tabid/១៤៨/Default.aspx

ក្រសួងផែនការ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ, ការកាត់បន្ថយភាពទីទាល់ក្រតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ និងសង្កាត់ ដោយផ្អែកលើមូលដ្ឋានទិន្នន័យឃុំឆ្នាំ ២០០៤-២០១២, ភ្នំពេញ៖ MOP, ឆ្នាំ២០១២។

ក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ, ជំរឿនសេដ្ឋកិច្ច, ភ្នំពេញ៖ ក្រសួងផែនការ, ឆ្នាំ២០១៣។

វិទ្យាស្ថានជាតិស្ថិតិ (NIS), ការអង្កេតប្រជាសាស្ត្រចន្លោះជំរឿនកម្ពុជាឆ្នាំ២០១១, របាយការណ៍បណ្តោះអាសន្ន, ភ្នំពេញ៖ ក្រសួងផែនការ, ឆ្នាំ២០១៣។

រាជរដ្ឋាភិបាលកម្ពុជា, ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF), MEF, រាជធានីភ្នំពេញ, ឆ្នាំ២០១៧។

ធនាគារពិភពលោក, តើអ្នកក្រីក្រទៅណាអស់ហើយ? ការវាយតម្លៃភាពទីទាល់ក្រកម្ពុជា២០១៣, ក្រុងវ៉ាស៊ីនតោន DC: ធនាគារពិភពលោក, ឆ្នាំ២០១៣។

ធនាគារពិភពលោក, កសិកម្មកម្ពុជាក្នុងអន្តរកាល៖ ឱកាស និងហានិភ័យ, ធនាគារពិភពលោក, ក្រុងវ៉ាស៊ីនតោន DC. ធនាគារពិភពលោក, ឆ្នាំ២០១៥។

https://openknowledge.worldbank.org/handle/១០៩៨៦/២២៦៨០ License: CC BY ៣.0 IGO.

ធនាគារពិភពលោក, ការវិភាគប្រព័ន្ធប្រទេស៖ ការរក្សាបាននូវកំណើនរឹងមាំដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់គ្នា, ធនាគារពិភពលោក, ក្រុងវ៉ាស៊ីនតោន DC, វិលបេងគ្រុប, ឆ្នាំ២០១៧។ http://www.worldbank.org/en/country/cambodia/publication/Cambodia-Systematic-Country-Diagnostics

# ឧបសម្ព័ន្ធ

**តារាងA១៖** គណនីម៉ាទ្រីសគណនេយ្យសង្គម

| គណនីចម្បង | ពិពណ៌នាអំពីគណនីដែលបានបំបែកអង្គផ្សំ |
|---|---|
| **សកម្មភាពផលិតកម្ម** | កសិកម្ម ការបរបាញ់ ព្រៃឈើ និងនេសាទ<br>ផលិតកម្មកសិកម្មតាមគ្រួសារ ក្រុមទី៤<br>ការជីករ៉ែ<br>ផលិតផលស្បៀអាហារ ភេសជ្ជៈ និងថ្នាំជក់<br>វាយនភ័ណ្ឌ ផលិតផលវាយនភ័ណ្ឌ ស្បែកសត្វ និងស្បែកជើង<br>ឈើ លោហៈ កៅស៊ូ និងសម្ភារៈផ្សេងទៀត<br>ផលិតផលប្រេង<br>គ្រឿងម៉ាស៊ីន និងឧបករណ៍<br>កំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិក<br>ម៉ូតូ យានយន្ត និងឧបករណ៍ដឹកជញ្ជូន<br>កម្មន្តសាលផ្សេងៗ<br>អគ្គិសនី ឧស្ម័ន និងការផ្គត់ផ្គង់ទឹក<br>សំណង់<br>ការលក់ដុំ និងការលក់រាយ<br>សណ្ឋាគារ និងភោជនីយដ្ឋាន<br>ការដឹកជញ្ជូន និងសេវាពាណិជ្ជកម្ម<br>ប្រៃសណីយ៍ និងទូរគមនាគមន៍<br>សេវាអចលនទ្រព្យ និងអន្តរការីហិរញ្ញវត្ថុ<br>រដ្ឋបាលសាធារណៈ<br>សេវាអប់រំ<br>សេវាសុខាភិបាល<br>សេវាផ្សេងៗ |

| | |
|---|---|
| **មុខទំនិញ** | កសិកម្ម ការបរបាញ់ ព្រៃឈើ និងនេសាទ<br>ផលិតកម្មកសិកម្មតាមគ្រួសារ ក្រុមទី៤<br>ការជីករ៉ែ<br>ផលិតផលស្បៀអាហារ ភេសជ្ជៈ និងថ្នាំជក់<br>វាយនភ័ណ្ឌ ផលិតផលវាយនភ័ណ្ឌ ស្បែកសត្វ និងស្បែកជើង<br>ឈើ លោហៈ កៅស៊ូ និងសម្ភារៈផ្សេងទៀត<br>ផលិតផលប្រេង<br>គ្រឿងម៉ាស៊ីន និងឧបករណ៍<br>កំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិក<br>ម៉ូតូ យានយន្ត និងឧបករណ៍ដឹកជញ្ជូន<br>កម្មន្តសាលផ្សេងៗ<br>អគ្គិសនី ឧស្ម័ន និងការផ្គត់ផ្គង់ទឹក<br>សំណង់<br>ការលក់ដុំ និងការលក់រាយ<br>សណ្ឋាគារ និងភោជនីយដ្ឋាន<br>ការដឹកជញ្ជូន និងសេវាពាណិជ្ជកម្ម<br>ប្រៃសណីយ៍ និងទូរគមនាគមន៍<br>សេវាអចលនទ្រព្យ និងអន្តរការីហិរញ្ញវត្ថុ<br>រដ្ឋបាលសាធារណៈ<br>សេវាអប់រំ<br>សេវាសុខាភិបាល<br>សេវាផ្សេងៗ |
| **កត្តា** | ពលកម្មកសិកម្ម<br>គ្រួសារគោលដៅពលកម្មកសិកម្ម<br>ពលកម្មមិនមែនកសិកម្ម<br>ដើមទុនកសិកម្ម<br>គ្រួសារគោលដៅដើមទុនកសិកម្ម<br>ដើមទុនមិនមែនកសិកម្ម<br>ដី |

| | |
|---|---|
| **គ្រួសារ** | អ្នកមិនក្រីក្រនៅទីក្រុង<br>អ្នកក្រីក្រទីក្រុង<br>អ្នកមិនក្រីក្រជនបទ<br>អ្នកក្រីក្រជនបទ<br>អ្នកក្រីក្រជនបទជាគោលដៅ |
| **ស្ថាប័នផ្សេងៗ** | សហគ្រាស<br>សហគ្រាស-គ្រួសារគោលដៅ<br>គណនីរដ្ឋាភិបាល<br>គណនីពិភពលោកដទៃទៀត |
| **ពន្ធ** | ពន្ធសកម្មភាព<br>ពន្ធស្ថាប័ន<br>ពន្ធនាំចូល |
| **ផ្សេងៗ** | ការសន្សំសំចៃ និងគណនីវិនិយោគ<br>ការផ្លាស់ប្តូរហ៊ុន |

Empowered lives.
Resilient nations.


**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ( យូអិនឌីភី ) ប្រចាំប្រទេសកម្ពុជា**

អគារលេខ៥៣ វិថីប៉ាស្ទ័រ សង្កាត់បឹងកេងកង១ ក្រុងភ្នំពេញ
ព្រះរាជាណាចក្រ ប្រអប់សំបុត្រលេខ៖ ៨៧៧
ទូរស័ព្ទ៖ ( ៨៥៥ ) ២៣ ២១៦ ១៦៧
ទូរសារ៖ ( ៨៥៥ ) ២៣ ២១៦ ២៥៧ ឬ ៧២១ ០៤២
អ៊ីម៉ែល៖ registry.kh@undp.org
គេហទំព័រ៖ www.kh.undp.org